ការពន្យល់ ដើម ទំនៀននៃអក្សរសាស្ត្រ

វវ.84

808

# គឹម-សែត

## ការពន្យល់ នឹង ទំនៀនអក្សរសាស្ត្រ

នៅថ្នាក់ទី ៣ ទំនើប

នៃ

វិទ្យាល័យ និង អនុវិទ្យាល័យ

B. 129. 1581

446
80

★

ការផ្សាយរបស់:

បណ្ណាគារ-វង់ស៊ី

ផ្ទះលេខ ១៣ ផ្លូវព្រះកេតុមាលា - ក្រុងកំពង់ចាម

រក្សាសិទ្ធិ



# អ្វីដែលហៅថាវប្បធម៌ ?

មធ្យោបាយគ្រប់យ៉ាងដែលស្វែងរកនូវកុសល ( le bien ) សោភ័ណ ( le beau ) និងសុភមង្គល (le bonheur) ជូនមនុស្សជាតិហៅថាវប្បធម៌ ។ និយាយដល់វប្បធម៌ គឺត្រូវនិយាយពីសាសនា ទំនៀមទម្លាប់-ការសិក្សា ទស្សនវិជ្ជា-ចរិយា-សាស្ត្រ វិទ្យាសាស្ត្រនិងសិល្បៈ ។

តាមចលនន័យ (au point de vue du mouvement), វប្បធម៌កើតចេញមកពីការប្រយុទ្ធគ្នារវាងវណ្ណៈ មួយនិងវណ្ណៈមួយ នៃមនុស្សគ្រប់សម័យក្នុងលោកសន្និវាសនេះ ។ ព្រះបរមគោត្តមរបស់យើងបានបង្កើតពុទ្ធសាសនា ក្នុងពេលដែលវណ្ណៈព្រាហ្មណ៍ខំផ្សាយព្រាហ្មណ៍សាសនា របស់ខ្លួនក្នុងជម្ពូ-ទ្វីប ។ ពួកយើងជាពុទ្ធបរិស័ទបានដឹងច្បាស់ហើយថា ព្រះពុទ្ធជាម្ចាស់មិនយល់ព្រមថា មានអាទិទេពមានឫទ្ធិណាមួយអាចបង្កើតផែនដី, បង្កើតមនុស្ស, បង្កើតសត្វនិងរុក្ខជាតិ ដូចវណ្ណៈព្រាហ្មណ៍បានខំឃោសនានោះទេ ។

ពួកកសិករនឹងកម្មករ មិនពេញចិត្តនឹងនាយទុនលក់ទំនិញថ្លៃដើម្បីបានចំណេញកប់ក្ដោង, ក៏ស្រុះស្រួលបបួលគ្នាបង្កើតអង្គការមួយថ្មី សម្រាប់ឃិតយោងជាគោពរបស់ខ្លួន ៗ អង្គការថ្មីនោះ គឺសហករណ៍ ៗ ជនកសមាជិកនៃសហករណ៍នីមួយៗបានខំសរសេរនឹងបោះពុម្ពផ្សាយនូវសៀវភៅក្បួនច្បាប់និយាយអំពីផលប្រយោជន៍នៃសហករណ៍ នឹងរបៀបចាត់ចែងដំណើរការសហករណ៍ ដើម្បីឲ្យជនដទៃទៀតអនុវត្តន៍តាម ៗ

ព្រោះតែពុំព្រមជឿតាមការឃោសនារបស់អ្នកកាន់សា-សនាកាតូលិក, បណ្ឌិតហ្គាលីឡេ ខំបង្កើតបានកែវឆ្លុះមួយមើលឃើញផែនដីមានកងមូល ហើយវិលជុំវិញខ្លួនឯងផង នឹងវិលជុំវិញព្រះអាទិត្យផង ក្នុងគ្រិស្ដសករាជ ១៦៣២ ៗ

ឧទាហរណ៍ទាំងពីរខាងលើនេះ បញ្ជាក់យើងឲ្យឃើញថាវប្បធម៌មិនមែនកើតឡើងដោយឯងៗទេ គឺជាលទ្ធផលនៃការប្រយុទ្ធដ៏លំបាករវាងវណ្ណៈមួយនឹងវណ្ណៈមួយ ៗ ដោយហេតុថាវប្បធម៌កើតចេញមកពីការប្រយុទ្ធតទល់គ្នា រវាងវណ្ណៈមួយនឹង

វណ្ណៈមួយ , វប្បធម៌ក៏ជាក្បួនកសាងសង្គម , ក្បួនបដិវត្តន៍សង្គមអួនថយ ឲ្យបានជាសង្គមចំរើនជឿនលឿនសម្បូណ៌សប្បាយដែរ ការអនុវត្តន៍ផ្នែកនីមួយៗរបស់វប្បធម៌នាំឲ្យយើងបានផលផ្សេងៗអំពីគ្នា ៗ អនុវត្តតាមទំនាមទម្លាប់នៃសាសនាយើងបានទទួលនូវកុសល (LE BIEN) ៗ អនុវត្តតាមការសិក្សាវិទ្យាសាស្ត្រយើងបានទទួលនូវលោកិយសច្ចៈ (LE-VRAI) អនុវត្តតាមសិល្បៈយើងបានទទួលនូវសោភ័ណ ៗ

ការផ្សាយវប្បធម៌ទូទៅ នាំឲ្យមានសោភណភាពទូទៅ ៗ ការអនុវត្តន៍នូវវប្បធម៌ទូទៅ ដែលគេបានផ្សាយរួចហើយនាំឲ្យមានវឌ្ឍនភាពខាងសតិអារម្មណ៍នឹងខាងសម្ភារៈ គឺនាំឲ្យមានសេចក្ដីសុខសប្បាយក្នុងជីវិត , ក្នុងសង្គម ៗ សេចក្ដីសុខសប្បាយក្នុងជីវិតៈ , ក្នុងសង្គមនេះហើយដែលហៅថាៈ អរិយធម៌ ៗ

បុព្វបុរសយើង , ដោយលោកអនុវត្តទំនៀមទម្លាប់ , សាសនា ,បរិយាធម៌, ទស្សនវិជ្ជានឹងសិល្បៈ ទើបលោកកសាង

បាន ច្រាងប្រាសាទជាច្រើន មានប្រាសាទអង្គរវត្តជាដើម ទុកជាកេរ្តិ៍ដំណែលមកដល់យើងសព្វថ្ងៃនេះ ៗ ថ្មទាំងម៉ឺនផ្ទាំង ផ្គុំគ្នាបានជាអង្គរ ដោយសារតែការអនុវត្តន៍នូវវប្បធម៌ជាតិ ៗ អង្គរសព្វថ្ងៃនេះ ជានិមិត្តរូបនៃអរិយធម៌ជាតិ ៗ ដូច្នេះគេមិនអាចផ្តាច់វប្បធម៌នឹងអារ្យធម៌ឲ្យដាច់ពីគ្នាបានឡើយ ។ និយាយដល់វប្បធម៌នឹងអារ្យធម៌ខ្មែរ គេត្រូវនិយាយដល់ សម្ភកគូរ របស់ខ្មែរ, និយាយដល់រទេះគោ និយាយដល់បុកណាវត្តនឹង បុកណាផ្លូនទាំងអស់ ៗ

## វប្បធម៌នឹងជីវភាពមនុស្សជាតិ

មនុស្សទាំងអស់ក្នុងលោកនេះ រស់រានមានជីវិតបាន ដោយសារតែវប្បធម៌ ប៉ុន្តែមនុស្សភាគច្រើនៗតែមិនដឹងថាវប្បធម៌នេះជាអ្វី មិនខុសពីលោកហ្សូរដាំងក្នុងរឿង „អភិជនថ្មីសុភាព„ របស់ម៉ូលីយែរ ដែលចេះនិយាយពាក្យរាយធម្មតា ( PROSE ) រៀងរាល់ថ្ងៃតាំងពីតូច ប៉ុន្តែលោកពុំបានដឹងថាពាក្យដែលលោកនិយាយនោះជាពាក្យរាយធម្មតាឡើយ ។

ជីវិតយើងត្រូវការអាហារ ។ បើគ្មានអាហារទេ , យើងត្រូវតែស្លាប់ ។ អាហារជាលទ្ធផលនៃការអនុវត្តន៍វប្បធម៌ ។ បើគ្មានវប្បធម៌ក៏គ្មានអាហារដែរ ។

យើងចេះផ្សំអាហារនឹងចេះចំអិនអាហារបែបនេះបែបនោះ មកអំពីយើងបានទទួលវប្បធម៌ (ទំនៀមទម្លាប់របៀបស៊ីចុក) អំពីមាតាបិតាយើង ។ មាតាបិតាយើងឬស្គមយើង បានផ្សាយវប្បធម៌មកដល់យើង ។ បច្ចុប្បន្ននេះ ; អ្នកគ្រូសារឹដ នៅខេត្តបាត់ដំបងបានផ្សាយវប្បធម៌ ដែលមានលក្ខណៈល្អដល់យើងទៀតគឺសៀវភៅ „វិជ្ជាធ្វើម្ហូប„ នឹងបន្ថែមផ្សេងៗ ។ យើងអនុវត្តតាម „វិជ្ជាធ្វើម្ហូប” របស់អ្នកគ្រូ យើងនឹងបានអាហារឆ្ងាញ់ , យើងនឹងមានជីវិតប្រកបដោយសុខភាពល្អជាងមុន ព្រោះអាហារថ្មីនេះ បានផ្សំនឹងបានចំអិនតាមក្បួនអនាម័យ ។

អាហារដែលកើតចេញពីវប្បធម៌ ហើយដែលមនុស្សជាតិត្រូវការខានពុំបាននោះ យើងបានចែកជាពីរផ្នែក គឺកវលិង្កាហារ នឹងមនោសញ្ចេតនាហារ ។

## ១- កវលិង្ការាហារ

កវលិង្ការាហារ ជាអាហារទ្រទ្រង់កាយមនុស្សឲ្យមានមាឌមាំ មានកម្លាំងពលំ ។ អាហារជំពូកនេះគឺៈ បាយ, ទឹក, ម្ហូប, នំនែក, បេក, អំពៅជាដើម ។ កវលិង្ការាហារ បានចែកចេញជាពីរយ៉ាងទៀតគឺៈបណីតាហារនឹងលូខាហារ ។ បណីតាហារបានដល់អាហារណាដែលបរិភោគទៅមិនមានទោសគឺមិនចំពាស់ដល់សុខភាពៈ ដូចជាបាយឆ្អិន, ម្ហូបឆ្អិន, សាច់ល្អ, បន្លែស្អាត ។ល។ រីឯលូខាហារវិញ ជាអាហារសៅហ្មង កាលបើយើងបរិភោគទៅ ពនាំឲ្យយើងឈឺក្រពះ, ខូចសុខភាព, មានជម្ងឺផ្សេងៗ ។ លូខាហារមានជាអាទិ៍គឺៈ បាយឆៅ, នំផ្អូម, បន្លែស្អុយ, សុរាមេរ័យ ។ល។

បើកវលិង្ការាហារមានពីរបែបដូច្នេះតើយើងគួរទទួលទានអាហារជំពូកណា? ..។ ដើម្បីឲ្យមានសុខភាពបរិបូណ៌ យើងត្រូវទទួលទានបណីតាហារ ។ ប៉ុន្តែដើម្បីឲ្យបានបណីតាហារគ្រប់ពេលឃ្លាន ៈយើងត្រូវសាមគ្គីដោះស្រាយបញ្ហាក្រីក្ររបស់យើង

## ២ – មនោសញ្ចេតនាហារ

ពិតមែនតែវិទ្យាសាស្ត្រធម្មជាតិបានរាប់មនុស្សបញ្ចូលទៅក្នុងពពួកសត្វ មនុស្សយើងនៅតែមានឋានៈខ្ពស់ជាងសត្វជាដរាប ។ សត្វមានឋានៈអន់ជាងមនុស្ស ព្រោះវាគ្មានមនោ-សញ្ចេតនាហារ ។ គោ ក្របីមានតែស្មៅជាកវលិង្ការាហារទ្រទ្រង់រាងកាយតែប៉ុណ្ណោះ ។

មនោសញ្ចេតនាហារ គឺអាហាររបស់ខួរក្បាល ។ មនោសញ្ចេតនាហារនេះ មានសមត្ថកិច្ចខាងការទ្រទ្រង់, ពង្រីកសតិអារម្មណ៍របស់យើងឲ្យរីកចំរើន, មានប្រាជ្ញាគំនិតអាចយល់ច្បាស់នូវបញ្ហានានាក្នុងឆាកជីវិតបានដោយងាយ ។ មនោ-សញ្ចេតនាហារនេះ គេអាចស្វែងរកបានដោយមធ្យោបាយច្រើនយ៉ាង មានការមើល, ការអាននឹងការស្តាប់ជាអាទិ៍ ។ ប៉ុន្តែពិសេសបំផុតគឺការអានសៀវភៅ ព្រោះសៀវភៅជាឃ្លាំងនៃអក្សរសាស្ត្រ, ហើយអក្សរសាស្ត្រជាឃ្លាំងនៃវិជ្ជាគ្រប់ចំពូកដែលជាសាខារបស់វប្បធម៌ ។ ដូចនេះ បានអានសៀវភៅ

ឈ្មោះថា បានបំប៉នចំណីអាហារគឺតម្រេះវិជ្ជាឲ្យខួរក្បាល ឈ្មោះថាបានពង្រីកសតិអារម្មណ៍របស់យើងឲ្យមានប្រាជ្ញា ភ្លឺថ្លាវាងវៃ អាចយល់ច្បាស់បាននូវបញ្ហាសព្វសារពើក្នុងសង្សារវដ្តនេះ ។

ប៉ុន្តែ, យើងត្រូវយល់ថាៈ ដោយកវលិង្កាហារមានពីរយ៉ាង មនោសញ្ចេតនាហារក៏មានពីរបែបដែរ ។ មកដល់ចំណុចនេះ យើងត្រូវរំលឹកដល់ឥទ្ធិពលនៃអក្សរសាស្ត្រគ្រប់ចលនា នឹងគ្រប់និន្នាការ ដែលយើងអាចចែកចេញដោយសង្ខេបជាពីរប្រភេទគឺអក្សរសាស្ត្រជឿនលឿនមួយ, អក្សរសាស្ត្រប្រតិកិរិយាមួយ ។ អក្សរសាស្ត្រជឿនលឿន គឺអក្សរសាស្ត្រដែលជូននូវសេចក្តីពិត, បំភ្លឺខួរក្បាល , ពង្រីកសតិអារម្មណ៍ឲ្យរីកចំរើនជឿនលឿនតាមគន្លងវិទ្យាសាស្ត្រ, អក្សរសាស្ត្របែបនេះយើងចាត់ទុកជាបណីតាហារ សម្រាប់ខួរក្បាល ។ អក្សរសាស្ត្រប្រតិកិរិយា គឺអក្សរសាស្ត្រដែលជូនតែពីរឿងទេពនិយាយ, ជូនសេចក្តីប្រាសចាកការពិត , បំភាន់គំនិត, បង្អិលភ្នែក , បង្អិលខួរមនុស្សឲ្យវិលទៅកាន់អបិយជំនឿគ្រប់បែបគ្រប់យ៉ាង,

អក្សរសាស្ត្របែបនេះ យើងចាត់ទុកជាល្បូខាហារសម្រាប់

ចំពុលខួរក្បាល ។

ដោយខួរក្បាលយើងតែងត្រូវការមនោសញ្ចេតនាហារ

ព្រោះយើងមិនចង់បានឈ្មោះថាសត្វ នៅគ្រប់វ័យ នឹងគ្រប់

កាលៈទេសៈ យើងត្រូវចេះជ្រើសរើសអាហារណាដែល

អាចផ្តល់នូវសុខភាពដល់ខួរក្បាលយើង គឺយើងត្រូវអាន

សៀវភៅល្អ, ស្តាប់ចម្រៀងល្អ, មើលភាពយន្តល្អ.. ។

ប៉ុន្តែ, ដើម្បីឲ្យបានមនោសញ្ចេតនាហារល្អ យើងត្រូវ

រួមសាមគ្គីកំចាត់វប្បធម៌ពុករលួយ សូយគគ្រុករបស់ពួកចក្រ

ពត្តិនិយមចេញ ។ យើងត្រូវកសាងវប្បធម៌ជាតិយើងឲ្យមាន

លក្ខណៈស្របនឹងព្រះចិន្តាស្នេហាសន្តិភាព របស់សម្តេចព្រះ

ប្រមុខរដ្ឋរបស់យើង ។

## បទទស្សនាវប្បធម៌

ខ្មែរយើងមានវប្បធម៌មួយ – សម្រាប់ជាតិយើង ។

ពួកក៏មានវប្បធម៌មួយសម្រាប់ជាតិពួកដែរ ។ មនុស្សគ្រប់

សាសន៍ , ប្រទេសគ្រប់សណ្ឋាន (ធំតូច) សុទ្ធតែមានវប្បធម៌ទាំងអស់; តែប៉ុន្តែវប្បធម៌របស់ជាតិនីមួយ ៗ ក្នុងលោកនេះ មានលក្ខណៈមិនដូចគ្នាទេ ។ ជាតិខ្លះមានវប្បធម៌អន់ថយ ។ ជាតិខ្លះមានវប្បធម៌ចំរើនគ្រាន់បើ ។ ជាតិខ្លះទៀតមានវប្បធម៌ជឿនលឿនជាងគេ ។

សព្វថ្ងៃនេះ នៅគ្រប់ប្រទេសក្នុងសកលលោក , ប្រជាជាតិនីមួយៗ បានខំកសាងវប្បធម៌របស់ខ្លួនឲ្យមានលក្ខណៈប្រពៃឡើង . គឺខំពង្រីកការសិក្សា, ពង្រីកអក្សរសាស្ត្រ, សិល្បៈ, វិទ្យាសាស្ត្រ, - វិជ្ជាបច្ចេកទេស, វេជ្ជវិជ្ជានឹងអនាម័យ ។ កាលបើសាខាទាំងអស់ នៃវប្បធម៌ បានបោះជំហានទៅមុខ ព្រមគ្នាហើយ, គួរវប្បធម៌ទាំងមូល របស់ជាតិគេនឹងមានលក្ខណៈល្អប្រពៃ ដែលជាហេតុធ្វើឲ្យជីវភាព នៃប្រជាជាតិគេ បានឡើងដល់កំរិតខ្ពង់ខ្ពស់នឹងថ្លៃថ្នូរ សមតាមបំណងរបស់មនុស្សជាតិ ។

យើងត្រូវយល់ថា: កាលបើមនុស្សជាតិ ពុំទាន់មានជីវ

ភាពរុងរឿងទឹងថ្លៃថ្នូរនៅឡើយទេ ទោះវប្បធម៌នៅមានលក្ខណៈ អូទថយថ្ម ពុករលួយខ្លាំងណាស់ ៗ សៀវភៅកកកុញក្នុង បណ្ណាគារ ពុំទាន់បានន័យគ្រប់គ្រាន់ជាអក្សរសាស្ត្រចំរើនទេ ៗ ប្រទេសដែលមានវិសាលភាពដ៏ធំ ទឹងមានប្រជាជនច្រើន ពុំទាន់បានឈ្មោះថាមហាអំណាចដែរ ៗ ទ្វីបលោកដែលមាន វិមានខ្ពស់កប់ពពក តែបី-បួនខ្នង, សង់នៅកណ្ដាលចំណោម ខ្ទមស្លឹកច្រើនលានខ្នង ទ្វីបលោកនោះ បានឈ្មោះថា អនារ្យទ្វីប គឺទ្វីបដែលមានវប្បធម៌ពុករលួយជាទីបំផុត ៗ

ផ្ទុយពីនេះទៅវិញ, សៀវភៅតែពីរ-បីក្នុងបណ្ណាគារ ក៏អាចបង្ហាញនូវវឌ្ឍនភាព នៃអក្សរសាស្ត្ររបស់ប្រជាជាតិនីមួយ ៗបាន ៗ រដ្ឋតូច, ប្រជាជនតិចអាចទៅជាអារ្យប្រទេស ក្នុងលោកបាន ៗ

ពាក្យថា: «ចំរើន» ក្នុងវប្បធម៌មិនមែនស្ថិតនៅលើបរិមាណ (quantité) ទេ, គឺស្ថិតលើគុណសម្បត្តិ (qualité) របស់ សៀវភៅ, របស់ ចម្រៀង, របស់ ការអប់រំ ៗលៗ

ហេតុនេះប្រសិនជាគោលបំណងដឹកនាំប្រជាជាតិ ឲ្យមាន-វិញ្ញូនភាពខាងប្រាជ្ញាស្មារតី និងសម្ភារៈ, អ្នកអប់រំ, អ្នកចម្រៀង, អ្នកកវី, អ្នកនិពន្ធត្រូវតែប្រុងប្រយ័ត្ន ក្នុងការយកវណ្ណកម្មរបស់ខ្លួនទៅ សាបព្រោះលើសមុទ្រមនុស្ស ។ យើងត្រូវយល់ថា: វប្បធម៌អាក្រក់អាចសម្លាប់មនុស្សបានដោយស្ងាត់ៗ ។ ភាសិតមួយរបស់ជាតិអាក៉ប់បានថែងថា: គ្មានចោរពីណាអាក្រក់ឃោរឃៅជាងសៀវភៅពុករលួយឡើយ ។

## ជីវភាពមនុស្ស វិវត្តតាមដំណើរវប្បធម៌

វប្បធម៌មានឥទ្ធិពលខ្លាំងណាស់ ។ បទភ្លេង ឆា! ឆា! ឆា! បានកន្ត្រាក់សរសៃទិស្សិត មិនឲ្យអង្គុយទន្ទេញមេសូត្រដោយស្រួលដូចដើមបាន ។ នារីស្រគត់ស្រគំ ក្លាយខ្លួនទៅជានារីរវើរវាយហួសដល់ទៅដណ្តាំបាយខ្លោច ព្រោះតែចម្រៀងស្នេហាត្រជាក់ល្អក់ ដែលរលកអាកាសនាំមកបំពោសអណ្តែលបេះដូងនាងតាំងយប់ថ្ងៃ ។

ទស្សនាវដ្តីអឺរ៉ុប ដែលផ្សាយរូបភាពគំរូសំលៀកបំពាក់

របស់ស្រី "គាក់ស៊ី" ប្រមុះស្រួច បានចូលមកក្រឡៀសំលៀកបំពាក់សមស្លូតរបស់នារីខ្មែរភាគខ្លះ នៅស្រុកក្រុង ឲ្យទៅជាសំរែះស្មាបញ្ចេញគល់ . . . . អស់ហើយ ៗ

ខ្សែភាពយន្តផ្សេងៗ បានចូលមកបង្ហាត់កុមារ កុមារីខ្មែរយើង ឲ្យចេះប្រើពាក្យ "ណាក៍យ ៗ" សឹងតែគ្រប់គ្នា ព្រមទាំងបានចូលទៅបង្ហាត់សិល្បករនៅរោងល្ខោនខានា ឲ្យចេះកំរៀប "ក្បាលរង្គោះខ្លួនរង្គើ" ដូចជានាងនេរុបាំរយ៉ូ ប៉ុនាងមីនាំកុមារីជេរៗ ខ្សែភាពយន្តបក្រពត្តិនិយមវិញបាននឹងកំពុងតែបង្ហាត់បង្រៀនបណ្តាអ្នកចូលទៅទស្សនា ឲ្យចេះស្លៀកខោចង់ស្រី, ស្លៀកល្អិត, សក់បប៉ូន, ខុបាយកលក្បត់ជាតិ ៗល ៗ

ឧទាហរណ៍យ៉ាងខ្លី ៗ ខាងលើនេះបានបញ្ជាក់ជូនបងប្អូនរួមជាតិឲ្យជ្រាបថា: វប្បធម៌មានឥទ្ធិពលខ្លាំងណាស់ ៗ វាមួលកាច់សតិអារម្មណ៍របស់យើងឲ្យវិលទៅតាមចរិតរបស់វា ៗ គៅសិបឆ្នាំនៅក្រោមនឹមអាណានិគមនិយម, ជាតិយើងបានទទួលវប្បធម៌ពុករលួយ(វប្បធម៌អាណានិគមនិយម) ទាំងយប់

ថ្ងៃ ៗ សព្វថ្ងៃនេះ បងប្អូនយើងភាគខ្លះបានជ្រុះបាត់ចរិតជាតិ ចរិតពូជពង្សអង្គរវត្ត យ៉ាងជ្រុះស្រឡះ ៗ គេលែងចេះស្តាប់ចម្រៀងតាប៉ី ចម្រៀងអាយ៉ៃ. ល្ខោនខោល. រាំត្រុដិ-ឬ·បទអណ្តើកស៊ីត្រកួនហើយ គេចេះស្តាប់តែភ្លេងកញ្ជ្រិចៗ នៅរង្គសាល; គេពេញចិត្តតែបទអណ្តើកស៊ីសាច់ស្រស់ ! ...ៗ គេមិនចេះអានកាសែតកម្ពុជាទេ គេចូលចិត្តតែកាសែតបារាំងឬអង់គ្លេស ហើយបើគេនិយាយខ្មែរនឹងខ្មែរគ្នាឯងវិញ ក្នុងពាក្យ១០ម៉ាត់គេប្រើពាក្យបារាំងឬអង់គ្លេស៥ម៉ាត់ឬ៦ម៉ាត់ទៅហើយ ៗ

ដោយយល់ឃើញថា: ជីវិតមនុស្សវិវត្តទៅតាមដំណើរវប្បធម៌យ៉ាងហ្នឹង បានជាពួកអាណានិគមនិយមបានចំបញ្ចូលវប្បធម៌ពុករលួយរបស់ព (មិនមែនវប្បធម៌របស់ប្រជាជនបារាំងទេ) មកក្នុងប្រទេសយើងយ៉ាងសន្ធឹកសន្ធាប់ ៗ វាបង្ហាត់កូនខ្មែរឲ្យស្គាល់ «បៀប៉ោ» តាំងពីនៅរៀនថ្នាក់កុមារដ្ឋានម្លេះ (សូមមើលសៀវភៅថ្នាក់កុមារដ្ឋានផង) ៗ វាបង្ហាត់សិស្ស

ឲ្យចេះប្រៀនថា: „កញ្ចាញ់ចេកអើយលោតទំមែកស្វាយស្រុកយើងសប្បាយដោយសារបាកាំង- . . . ” ។ល។ វាជិះជាន់យើងបានដោយស្រួលក្នុងកំឡុងជិត១០០ឆ្នាំ, ព្រោះតែយើងលិចលង់ក្នុងរណ្ដៅវប្បធម៌រលួយស្អុយរបស់វាហ្នឹងឯង ហើយរហូតដល់ស្ថានការណ៍បានបង្ខំចិត្តវាឲ្យវាតបះជើង ចេញពី-ស្រុកយើងទៅទៀត ក៏នៅតែយើងគាគខ្វះខំជួយទ្រទ្រង់ផលប្រយោជន៍វាដដែល ។

ពេលហ្នឹង, គួរតែយើងតាំងអស់គ្នាចំផ្សាយវប្បធម៌របស់យើងដែលមានលក្ខណៈ ប្រជាជាតិ-ប្រជាជន ឲ្យបានសាយភាយពាសពេញឡើង ដើម្បីសូសទាញបងប្អូនយើងឲ្យរួចចេញពីរណ្ដៅវប្បធម៌រលួយស្អុយរបស់អាណានិគមនិយម និងបក្រ-ពត្តិនិយម ។ យើងកុំឧស្សាហ៍បញ្ចេញតែសំដី យើងត្រូវនិយមការប្រតិបត្តិជាក់ស្ដែងផង ។ បើយើងហាមគេមិនឲ្យញ៉ាំបាយផ្អូម ហើយយើងនៅតែមិនព្រមយកបាយឆ្ងាញ់មកឲ្យគេញ៉ាំផង, . . ម៉្លោះហើយពោះគេឃ្លាន, គេត្រូវតែញ៉ាំបាយផ្អូម

ទៀតហើយ ។ល។ មួយវិញទៀត, យើងទាំងអស់គ្នាដែលមានចិត្តចង់យកបាយឆ្ងាញ់មកជូនបងប្អូនរួមជាតិយើងបរិភោគនោះ យើងត្រូវតែចំរើនដំណាំបាយ, រៀនធ្វើម្ហូបអាហារ ឲ្យបានឆ្អិនមែនទែនផង ដើម្បីកុំឲ្យជនរួមជាតិយើងបរិភោគបាយរបស់យើងទៅៗជាហើមពោះហើមពុង ដូចកាលញុំាបាយផ្អូមរបស់អាណានិគមនិយមទៀត ។

ដើម្បីឲ្យវប្បធម៌ជាតិមានលក្ខណៈល្អ, យើងទាំងអស់គ្នាត្រូវតែជួយទិទៀននឹងសុខចិត្តឲ្យគេធ្វើការទិទៀនដល់ស្នាដៃយើងផង ។

## ទិទៀនវប្បធម៌ ដើម្បីកែប្រែវប្បធម៌

### -ការទិទៀន-

និយាយដល់ការទិទៀន, មិត្តខ្លះមានយោបល់ថា: ត្រូវទុកភារៈនេះជូនទៅអាចារ្យទិសាបាមោក្ខ ឬ ជូនទៅបណ្ឌិតល្បីល្បាញក្នុងលោកវិញ ។ យោបល់បែបហ្នឹង ខ្ញុំមិនបដិសេធទេ

ក៏ប៉ុន្តែខ្ញុំយល់ថា: គួរតែណាស់ពោលខ្លះទៅកុំឲ្យរ៉ាប់ជាផ្អៀត បន្អល់ពេក . . ! ។ ក្នុងលោកនេះ អ្នកណាមួយដែលមិនចេះ ទិះទៀន ? ។ កើតមកជាមនុស្ស មិនថាស្រីមិនថាប្រុស ចាប់តាំងពីអាយុ ២ ឆ្នាំទៅទល់នឹងថ្ងៃស្លាប់ សុទ្ធតែបានធ្វើការ ទិះទៀនទាំងអស់ ។ កុមារតូចៗចេះតម្អូញប្រាប់ម៉ាក់ប៉ាថា: ថ្ងៃនេះក្តៅណាស់ ! ម្ហូបនេះហឹរណាស់ ! កូនញ៉ាំមិនបានទេ ក្តៅណាស់! ហឹរណាស់! ជាមូលដ្ឋានដើមនៃគំនិតទិះទៀន ។ កុមារហ៊ានថា: ថ្ងៃនេះក្តៅណាស់ ! ព្រោះវាបានយកថ្ងៃនេះ ទៅប្រៀបធៀបនឹងថ្ងៃម្សិល ឬថ្ងៃមុនៗ ។ មិត្តស្រីៗ កាល ដែលត្រឡប់មកពីផ្សារវិញបានពោលរអ៊ូរទាំប្រាប់គ្នាថា: ម្ហូប ម្ហាថ្ងៃនេះថ្លៃដ៏ឥតមុខ ! . . ។ កសិករបានថ្ងូរថា: ឆ្នាំនេះគ្មាន ភ្លៀងសោះធ្វើស្រែមិនបាន ។ នៅក្នុងសាលារៀនវិញ សិស្ស ទុសិស្សប្រាប់គ្នាថា: សៀវភៅនេះពន្យល់ពាក្យមិនច្បាស់ សៀវភៅនេះទៀតបង្ហាញតែស្នៀតខ្លប ដូចសៀវភៅបក្រពត្តិ អញ្ចឹង . . ! ។ នេះមិនមែនការទិះទៀនទេឬ ? ។ មនុស្ស

ណាដែលហាមគេមិនឲ្យទិទៀនខ្លួន, មនុស្សនោះក៏កំពុងតែទិទៀនគេដែរ ។ ហាមមិនឲ្យគេទិទៀនយើង បានន័យថា: យើងបានទិទៀនសមត្ថភាពគេរួចស្រេចទៅហើយ ! ។

ខ្ញុំយល់ថា: មនុស្សទាំងអស់ក្នុងលោកនេះ សុទ្ធតែបានធ្វើការទិទៀនគ្រប់ៗគ្នា ។ មិនចេះធ្វើការទិទៀន មានតែមនុស្សដែលដេកសម្ងំក្នុងក្ដារម្ឈូស ។

មហាវិទ្យាល័យខ្លះនៅបស្ចិមប្រទេសបានពន្យល់និស្សិតថា:ត្រូវតែរៀនក្បួនទិទៀន ទើបចេះទិទៀន ។ គេថា: ទិទៀនសិល្បៈជាការលំបាក ព្រោះវាទាមទារសមត្ថភាពយ៉ាងច្រើន ។ ខ្ញុំបានអានច្បាប់មួយ ដែលវិជ្ជាស្ថានវប្បធម៌បារាំងនៅក្រុងប៉ារីសបោះពុម្ពចែកនិស្សិតរបស់គេ ។ ខ្ញុំអានចប់ក្បួននោះ, ខ្ញុំជឿថា: ការទិទៀនសិល្បៈបស្ចិមប្រទេស ជាការលំបាកមែនព្រោះគឺទស្សននិយមរបស់សិល្បករ នៅបស្ចិមប្រទេសនោះមិនដូចទស្សននិយមរបស់សិល្បករបូព៌ាប្រទេសទេ ។ គេយល់ថា: សិល្បៈមានគោលបំណងគ្រាន់តែបង្កើត

សោភណភាព (L'art a pour but la reproduction de la beauté) ហើយគេយល់ថា: សោភ័ណមិនស្ថិតនៅលើការមានប្រយោជន៍ឡើយ (Le beau est également distinct de l'utile) បណ្ឌិតម្នាក់ឈ្មោះ (kant) ដែលមានឈ្មោះល្បីល្បាញថាជាអ្នកចេះធ្វើការទិទៀននោះ បានសរសេរថា: ( Le beau est un plaisir désintéressé) ៗ គេមានទស្សនៈទៅលើសិល្បៈយ៉ាងហ្នឹងខ្ញុំក៏សូមយល់ថា: ការទិទៀនពិបាកមែន, មនុស្សដែលមិនឃ្លាតឆ្ងាយពីការតស៊ូ, មនុស្សដែលមិនញាប់ដេកត្រាំលើគំនរឆ្អឹងនឹងថ្លុកឈាមពលករមិនអាចទិទៀនបានទេ ក្រៅពីហាមាត់បន្ទោសថា: "សិល្បៈដើម្បីសិល្បៈ" ៗ ប៉ុន្តែ, បើគេព្រមយល់ថា, សិល្បៈមានគោលបំណងបំរើប្រជាជនវិញនោះច្បាស់ជាប្រជាជនអាចចេះធ្វើការទិទៀនគ្រប់ៗគ្នា ព្រោះអីសិល្បៈនោះបានស្តែងអំពីសកម្មភាព, អំពីការរស់នៅរបស់ប្រជាជន ៗ បើស្តែងទៅហើយមានការទាស់ខុសឬមិនសមរម្យកន្លែងណាមួយ ប្រជាជនអាចជួយបំពេញឲ្យបាន, ប៉ុន្តែ

បណ្ឌិតដែលមិនធ្លាប់ស្គាល់ជនទប, មិនធ្លាប់ដេកហាលភ្លៀង ហាលខ្យល់មិនអាចជួយបំពេញបានឡើយ ។

សិល្បករយើងបានទទួលលក្ខណៈវប្បធម៌បស្ចិមប្រទេសជាច្រើន ខ្ញុំទំនៀនវប្បធម៌នេះ ពុំមានបំណងអូសបញ្ចូលទៅក្នុងបែបឯណាមួយដែរ ក៏ប៉ុន្តែឲ្យមានប្រយោជន៍ ដល់ប្រជាជន–មហាជន ដល់មនុស្សជាតិ ដែលជាមហាមាគ៌ានយោបាយបច្ចុប្បន្នរបស់ព្រះអគ្គមគ្គុទ្ទេសក៍នៃយើងរាល់គ្នា ។

## ទស្សនៈរួមទៅលើវប្បធម៌បច្ចុប្បន្ន

ជាការធម្មតាទេ ចំពោះមតិយោបាយខ្វែងគ្នា ក្នុងការបញ្ចេញស្នាដៃសិល្បៈ ព្រោះយើងទាំងអស់គ្នា មានការរស់នៅខុសគ្នាស្រេចទៅហើយ ។ សេដ្ឋីពុំអាចបន្ទោសនាយទុនបានទេ ព្រោះបើធ្វើដូច្នេះ វានឹងខាតប្រយោជន៍សួនតួរបស់គាត់ហើយវាមិនខុសអ្វីពីគាត់ដេកផ្កាប់ រួចស្ដោះទឹកមាត់នោះឡើយ ។ ក៏ប៉ុន្តែ, បើយើងពុំព្រមធ្វើឲ្យមានប្រយោជន៍ដល់ប្រជាជន–មហាជនផង នោះហាក់ដូចជាយើងឃ្លាតឆ្ងាយ

ពីនយោបាយស្រោចស្រង់ក្រុត្រីក្រ ។

ខ្ញុំសូមអភ័យទោស, ពុំបានយកស្នាដៃសិល្បៈមួយៗមក រិះគន់ទៀតទេ ។ ខ្ញុំចូលចិត្តជឿថា: ឆ្នាំចាស់ៗទាំងឡាយដែល កន្លងទៅហើយនោះ ច្បាស់ជាបាននាំយកគំនិតចាស់គំរិល របស់យើងទៅជាមួយផង ហើយឆ្នាំថ្មីនេះ យើងទាំងឡាយទឹង កើតមានទស្សនៈថ្មីពិតប្រាកដ ព្រោះយើងទាំងឡាយគាន់តែ មានវ័យចាស់បន្តិចហើយ ។ ពេលនេះខ្ញុំគ្រាន់តែសុំមានយោ-បល់ថា: ស្នាដៃចាស់របស់យើងភាគច្រើននោះ ពុំសូវស្រប តាមកាលនិយមឡើយ ។

សិល្បៈដែលស្តែងអំពីសុជីវធម៌ក្នុងការគាន់ស្វាមព្រោះ, គាន់សម, កាន់កាំបិត, ញុំបំស្បែក; ក្នុងការកាច់ពង់ស្ពា នៅលើផ្ទះចំខ្ទស់ត្រដឹមកប់ពពក ឬនៅក្នុងរថយន្តកន្ទុយវែង ពិតជាពុំមានខ្លឹមសារទេ ព្រោះវាខុសទីដ៏ជីវភាពដ៏ពិតប្រាកដ នៃប្រជាជនយើង ។

មួយវិញទៀត, ក្នុងពេលដែលយើងត្រូវត្រូតដៃគ្នាលើក

ដំកើងជីវភាពនៃយើងតាមផែនការណ៍ប្រាំឆ្នាំ, ក្នុងពេលដែលយើងត្រូវចងសាមគ្គីភាព ឲ្យភ្ជាប់ខ្លួនជុំវិញអង្គសម្តេចដើម្បីអព្យាក្រឹតភាព នោះគួរតែសិល្បករច្នៃតែងអធិប្បាយ វែកញែកឲ្យឃើញច្បាស់នូវតម្លៃនៃការហត្ថកម្ម, ឲ្យឃើញច្បាស់នូវសន្តិភាពដែលកើតមានឡើងលើមាគ៌ាអព្យាក្រឹត, ព្រោះយើងជាសិល្បករ ហើយករណីយកិច្ចរបស់សិល្បករ គឺបំរើផលប្រយោជន៍ប្រជាជន-មហាជន ។

# ប្រវត្តិអក្សរសាស្ត្រខ្មែរ

## កំណើតអក្សរសាស្ត្រខ្មែរ

ចាប់តាំងពីមានប្រជាជាតិខ្មែរមកទល់នឹងសតវត្សរ៍ទី ៧ នៃពុទ្ធសករាជ, ខ្មែរយើងគ្រាន់តែមានភាសានិយាយ ពុំទាន់មានអក្សរសរសេរនៅឡើយទេ ។

ភាសារបស់ខ្មែរយើង ជាអម្បូរភាសាមន-ខ្មែរ, មានរូបសិទ្ធិផ្សេង មាននិរុត្តិសាស្ត្រផ្សេងពីភាសាអម្បូរឥណ្ឌូអឺរ៉ុប ។

មុនពុទ្ធសតវត្សរ៍ទី ៧ នេះ, យើងមិនទាន់មានអក្សរជាតិមែន តែយើងបានយកអក្សរឥណ្ឌៀសុទ្ធសាធមកប្រើ. ហើយ ពីព្រោះកាលពុទ្ធសតវត្សរ៍ទី ៤ ជនជាតិឥណ្ឌៀ បានធ្វើវិត្ថារកម្មមកដល់ប្រទេសខ្មែរយើង បាននាំវប្បធម៌សំស្ក្រឹតមកសាបព្រួសនៅប្រទេសយើងហើយ ។ ឯវប្បធម៌សំស្ក្រឹតនោះ សរសេរជាអក្សរឥណ្ឌៀ ។ ហេតុនេះបានជាខ្មែរបុរាណយកអក្សរឥណ្ឌៀសុទ្ធសាធមកសរសេរ ។ យើងហ៊ានពោលថាខ្មែរយើងយកអក្សរឥណ្ឌៀ សុទ្ធសាធមកប្រើ

ព្រោះមានសិលាចារឹកនៅវ៉ូកាញ់(១) (ពុទ្ធសតវត្សរ៍ទី ៧) ជាសក្ខីភាព ។

លុះដល់ពុទ្ធសករាជ៧០៧ ទើបព្រះមហាក្សត្រខ្មែរយើង, ព្រះបាទភវវរ្ម័ន ទី ១, ទ្រង់បានកសាងអក្សរជាតិលើកដំបូង តាមបែបផែនអក្សរព្រាហ្មណ៍នៅឥណ្ឌៀភាគខាង-ត្បូង ។ ដូច្នេះអក្សរសាស្ត្រខ្មែរយើងមានរូបភាពជាក់ស្តែង (Matérialisation de la littérature) នៅដើមសតវត្សទី ៨ នៃពុទ្ធសករាជ ឬនៅសតវត្សទី ២នៃគ្រិស្តសករាជ (E.C.164)។

អក្សរសាស្ត្រខ្មែរយើងបានប្រែប្រួល ចរិតតាមការវិវត្តន៍នៃសង្គមខ្មែរ តាំងពីពេលនោះរហូតមកដល់សព្វថ្ងៃ ។

## ភាពជាសម្ភារៈនៃអក្សរសាស្ត្រខ្មែរ

អក្សរសាស្ត្រខ្មែរយើង, ដោយមានតួអក្សរខ្មែរសុទ្ធ-

---

(១) វ៉ូកាញ់ — គឺជាឈ្មោះភូមិមួយនៅក្នុងខេត្តញ៉ាត្រាំង (Nhatrang) វៀតណាមខាងត្បូងសព្វថ្ងៃនេះ ។ ភូមិភាគវ៉ូកាញ់នេះកាលដំនាន់ដើមជាសមន្តភាគប្រទេសខ្មែរសម័យនគរភ្នំ (ហ្វូណន) ។

សាធជាឧបករណ៍ផងនោះ, បានផ្តិតជាប់នៅលើសម្ភារៈប្រាំ-បែប – (La littérature cambodgienne s'est matérialisée sous cinq formes ៗ

១- ការសរសេរដោយដៃនៅលើស្បែកសត្វ ( des manuscritts sur de speaux)

២- ចារឹកនៅលើថ្ម-សិលាចារឹក (Des inscriptions épigraphiques) ៗ

៣- ចារនៅលើស្លឹករឹត ស្ត្រាស្លឹករឹត (Des olles)

៤- ការសរសេរជាក្រាំង (Des Krangs)

៥- ការបោះពុម្ពជាសៀវភៅ (Des livres)

## អក្សរសាស្ត្រនិងសម្ភារៈមួយបែបៗ

១- អក្សរសាស្ត្រ ដែលផ្តិតជាប់នៅលើស្បែកសត្វ បានរលាយបាត់រូបភាពយ៉ាងដាច់ហ័ស ពីព្រោះគំនូសដីស បំពង់ដែលសរសេរនៅលើស្បែកសត្វនោះ មិនអាចធន់បាន នឹងកម្លាំងធម្មជាតិ មានភ្លៀង, ខ្យល់ ឬនឹងអំពើបំផ្លិចបំផ្លាញ

របស់សត្វល្អិតៗបានឡើយ ។

២– ដោយយល់ឃើញថា អក្សរសាស្ត្រដែលផ្តិតជាប់នៅលើស្បែកសត្វ មិនអាចគង់វង្សបានយូរ, បុព្វបុរសរបស់យើង បានរិះរកមធ្យោបាយមួយថ្មី ដើម្បីរក្សាអក្សរសាស្ត្រទាំងនោះ ។ មធ្យោបាយនោះគឺ ការឆ្លាក់ទៅលើថ្មហៅថា សិលាចារឹក ។ សិលាចារឹកនេះ អាចរក្សាអក្សរសាស្ត្រឲ្យគង់វង្សបាន ប៉ុន្តែមានគុណវិបត្តិក្នុងការផ្សាយ ព្រោះគេមិនអាច លើកយកសិលាចារឹកទាំងផ្ទាំងៗ ទៅផ្សាយពាសពេញនគរបានទេ ។

៣– ដោយហេតុនេះហើយ, បានជាពេលក្រោយមកដូនតាយើង រិះរកមធ្យោបាយចារអក្សរសាស្ត្រនៅលើស្លឹក-រឹត ។ វិធីនេះអាចឲ្យដូនតាយើង យកអក្សរសាស្ត្រទៅផ្សាយបានគ្រប់ទីកន្លែង ពិសេសគឺនៅតែគ្រប់វត្តអារ៉ាម ។

ប៉ុន្តែការដែលយកអក្សរសាស្ត្រមកផ្តិតជាប់នៅលើស្លឹករឹតនេះ ដូនតាយើងត្រូវប្រើពេលយ៉ាងយូរណាស់ ព្រោះ

ទម្រាំតាបានអក្សរមួយ ៗ លោកត្រូវប្រើពេលមិនតិចជាង ពីពីរម៉ឺនុតទេ ៗ

៤– ក្រោយមក ក៏មានមធ្យោបាយមួយថ្មីទៀត គឺយកអក្សរសាស្ត្រទៅផ្ដិតឲ្យជាប់នៅលើក្រដាសស្នែ ហៅជាគ្រាំង ៗ ការសរសេរជាគ្រាំង ដូចតាយើងមិនខាតពេលច្រើនដូចកាលតារនៅលើស្លឹករឹតទេ ៗ

៥ – លុះមកដល់សម័យវិទ្យាសាស្ត្រនេះ, អក្សរសាស្ត្រខ្មែរយើង ត្រូវបានផ្ដិតជាប់ទៅលើសៀវភៅដូចជាអក្សរសាស្ត្ររបស់បរទេសទាំងឡាយដែរ ៗ ការបោះពុម្ពជាសៀវភៅ អាចឲ្យយើងចំណេញពេលច្រើនហើយការផ្សាយអក្សរសាស្ត្រទៀត ក៏បានប្រព្រឹត្តទៅយ៉ាងឆាប់រហ័សក្រៃលែង ៗ

## របៀបសម្ពន្ធរបស់អក្សរសាស្ត្រខ្មែរ

អក្សរសាស្ត្រខ្មែរយើងចែកចេញជា ៣ ផ្នែកធំ ៗ គឺ:

១– អក្សរសាស្ត្រសាសនា (la littérature religieuse)

២- អក្សរសាស្ត្រនីតិវិធី (la littérature juridique)

៣- អក្សរសាស្ត្របច្ចេកទេស (la littérature technique)

អក្សរសាស្ត្រសាសនា- អក្សរសាស្ត្រសាសនា ពោលអំពីឋាននរក, ឋានសួគ៌, ឋាននិព្វាន ដឹកនាំមនុស្ស ឲ្យបេះធ្វើបុណ្យឲ្យបាន ឲ្យមានចិត្តបំណងប្រាថ្នាទៅចាប់ កំណើតជាទេវតា នៅលើឋានសួគ៌ ។ ផ្នែកអក្សរសាស្ត្រសាសនានេះ ខ្មែរយើងមានរឿងព្រះវេស្សន្តរជាសំខាន់ជាងគេ ។

ក្នុងផ្ទៃនៃអក្សរសាស្ត្រសាសនាច្រើនតែពោលអំពី៖

១- ព្រះវិន័យ (la Discipline)

២- ព្រះសូត្រ (les Formules a réciter )

៣- ព្រះអភិធម៌ (la Métaphysique)

អក្សរសាស្ត្រសាសនា មានពីរផ្នែកទៀតគឺ: អក្សរសាស្ត្រ

សាសនាមហាយាន នឹងអក្សរសាស្ត្រសាសនាហីនយាន ។

អក្សរសាស្ត្រនីតិវិធី. អក្សរសាស្ត្រនីតិវិធីពោលអំពីក្បួនច្បាប់សម្រាប់បំពុតចរិយាមនុស្ស ដឹកនាំមនុស្សឲ្យមានគំនិតថ្មី ក្នុងការប្រកបរបរការជីវៈ ។ ផ្នែកអក្សរសាស្ត្រនី-តិវិធីនេះ, ខ្មែរយើងមានច្បាប់ក្រម - ច្បាប់កេរ្តិ៍កាល - ច្បាប់ប្រុស - ច្បាប់ស្រី - ច្បាប់ពាក្យចាស់ - ច្បាប់ទូន្មានខ្លួន - ច្បាប់ទូន្មានកូន - ច្បាប់បណ្តាំឪពុក - ច្បាប់ហៃមហាជន - ច្បាប់ក្រម-ង៉ុយ - ច្បាប់វិធូរបណ្ឌិត - ច្បាប់ព្រះរាជសម្ភារ ។ល។ នឹង ។ល។ ហើយនឹងកាសិតជាច្រើនទៀត ។

អក្សរសាស្ត្របច្ចេកទេស - អក្សរសាស្ត្រផ្នែកនេះខ្មែរយើងមានច្រើនបំពូកណាស់ ។

១– ក្បួនទាយ (la divination) ដូចជាហោរាសាស្ត្រ តម្រាផ្សំគ្រឿងរាសនា ។ល។

២– ល្ខោន (le théâtre) ដូចជារឿងរាមកេរ្តិ៍ (Ramayena) ។

៣- ចម្រៀង (Chanson) ដូចជាចម្រៀងរបស់ម្ចាស់ក្សត្រីស្រ-អ៊ុក, របស់អ្នកម្នាងយ៉ម ។ល។

៤- ប្រលោមលោក (Roman) វរវង្សសូរវង្ស ។

៥. រឿងព្រេងតុលាការ (Contes judiciaires) ដូចជារឿងសុភាទន្សាយ-ច្បាប់កឹងកេរ្តិ៍ ។

៦- រឿងព្រេងកំប្លែង (Contes comiques) ដូចជាអាខ្សៀវកាជ័យប្រាជ្ញ - អាខ្វាក់អាខ្វិន - ពស់កេងកង - រឿងថ្នាំងវែងអន្ទង់វែង ។ល។

## សម័យរបស់អក្សរសាស្ត្រខ្មែរ

អក្សរសាស្ត្រខ្មែរ ចែកចេញជាប្រាំ (៥) សម័យតាមការវិវត្តន៍របស់សង្គមខ្មែរផង តាមការគង់វង្សអក្សរសាស្ត្រក្នុងភាពជាសម្ភារៈផង (Matérialisation de la littérature Khmère) ។

សម័យអក្សរសាស្ត្រទាំងប្រាំគឺ ៖

១- សម័យមុនអង្គរ (Période Pré Angkorienne)

២- សម័យអង្គរ ( Période Angkorienne ) គិតតាំងពី គ.ស ៨០២ ដល់១.៤៣៣ ។

៣- សម័យលង្វែក (Période obscure) គិតតាំងពី គ.ស.១.៤៣៤ ដល់ ១ ៨៦២ ។

៤- សម័យអាណានិគមចាក់ (Période Colonialiste française) គិតតាំងពីគ.ស.១៨៦៣ដល់១៩៥៣ ។

៥- សម័យឯករាជ្យ (Période moderne) គិតតាំងពី គ.ស. ១៩៥៤ រហូតដល់នៅ . . . ។

## ចលនាអក្សរសាស្ត្រខ្មែរ

អក្សរសាស្ត្រខ្មែរចែកចេញជាប្អូនចលនា (Mouvement littéraire)

១- ចលនាព្រហ្មនិយម (Mouvement Bhramaniste )

២ - ចលនាពុទ្ធនិយម (Mouvement Bhoudhi ste)

៣- ចលនាខេមរនិយម (Mouvement khmeriste)

៤- ចលនាលាយឡំ នឹង អក្សរសាស្ត្រ បរទេស (Mouvement sous l'influence étrangère)

## សេចក្តីសង្កេត

១- រឿងណាដែលសំដែងអំពីបុគ្គលផ្តេកផ្តួលខ្លួនទៅលើព្រេងវាសនា បណ្តែតតាមយថាកម្ម, ឬក៏ជាបុគ្គលមានចិត្តអាក្រក់ឃោរឃៅ កាប់សម្លាប់គេឥតត្រាប្រណី; រឿងនោះនៅក្នុងពួក ចលនាអក្សរសាស្ត្រព្រហ្មនិយម ។ ដូចជារឿង ពមកេរ្តិ៍ជាដើម ។

២- រឿងណាដែលសំដែងអំពីបុគ្គល មិនជឿកម្មពៀរ, មិនបណ្តែតខ្លួនតាមយថាកម្ម, ហើយបែរជាយកបញ្ញាមកតស៊ូឲ្យឈ្នះអំពើឃោរឃៅទៅវិញ; ឬក៏បុគ្គលនោះមានឫក-ពាសុភាព, មានសីលធម៌បរិបូណ៌, មានមនុស្សធម៌ក្នុងខ្លួន រឿងនោះនៅក្នុងពួក ចលនាអក្សរសាស្ត្រពុទ្ធនិយម ។ ដូចជារឿងសន្ធិបញ្ញាសជាតកជាដើម ។ល។

៣ – រឿងណាដែលមិនផ្តុកផ្តួល ទៅលើមហិទ្ធិឫទ្ធិព្រះព្រហ្មព្រះពុទ្ធ, តែស្ដែងតែអំពីជីវភាពរបស់ខ្មែរមែនៗ រឿងនោះនៅក្នុងចំពូក ចលជាអក្សរសាស្ត្រខេមរនិយមៗ ដូចជារឿង «ទុំទាវ» រឿង «សូផាត» ជាដើមៗ

៤ – រឿងណាដែលមានតួបុគ្គលក្នុងរឿងបានប្រកាន់យកទំនៀមទម្លាប់ប្រពៃណី ខុសអំពីចរិតរបស់ខ្មែរ . . . ដូចជា «កំដង់ស៊ីញ» ជាដើម: រឿងនោះនៅក្នុងចំពូក ចលជាអក្សរសាស្ត្រលាយឡំ នឹង ឥទ្ធិពលអក្សរសាស្ត្របរទេស (១) ។

---

បំណាំ <១>នឹងមានអធិប្បាយយ៉ាងពិស្ដា ក្នុងសៀវភៅ"អក្សរសាស្ត្រខ្មែរពន្យល់" របស់អ្នកនិពន្ធតឹម-សែតនិងដែល ។

# សង្ខេបរឿងទុំទាវ

ទុំកើតនៅស្រុកបាភ្នំ, ខែត្រព្រៃវែង ។ ដល់មានអាយុគ្រប់រៀន, ម្ដាយយកទៅឲ្យនៅវត្ត ព្រះវិហារធំ ។ ទុំមានប្រាជ្ញាឆ្លាតវៃ រៀនសូត្រចាប់ចេះឆាប់ចាំ ហើយមានសម្ដីពិរោះផង ។ បួសជាសាមណេរ, នេនទុំនិងនេនពេជ្រនៅវត្តជាមួយគ្នា, ស្រឡាញ់រាប់រកគ្នាដូចបងប្អូន ។

ថ្ងៃមួយនោះ, នេនទាំងពីរសុំអនុញ្ញាត ពីលោកគ្រូចៅអធិការបររទេះគោទៅលក់គោកឯស្រុកត្បូងឃ្មុំ ។ លុះទៅដល់ភូមិពោធិជើងខាល, នេនទុំនិងនេនពេជ្រឈប់លក់រទេះគោកឲ្យអ្នកស្រុក ។ នៅទីនោះ នេនទុំបានសូត្រជូនអ្នកស្រុកស្ដាប់ផង ។ ដោយនេននេះ មានរូបសម្បត្តិល្អ ព្រមទាំងមានសម្ដីពិរោះលន្លង់លន្លោច, អ្នកស្រុកទាំងប្រុសទាំងស្រីបាននាំគ្នាពោមពេមស្ដាប់ហើយមានសេចក្ដីសរសើរនិងរាប់អានយ៉ាងខ្លាំង ។

ក្រោយមកទៀត, តាមសេចក្ដីនិមន្តរបស់ជូន ផាន់, នេនទុំបានទៅសូត្រនៅផ្ទះជូន ផាន់ ដែលជាស្រីមេម៉ាយមួយ-

រូប នៅក្នុងស្រុកត្បូងឃុំនោះ ៗ នៅទីនោះ នាងទាវជាកូនស្រីដូនផាន់បានចាប់ចិត្តស្នេហាទៅលើនេនខ្ញុំភ្លាម ៗ នាងបានបូជាផាហ៊ុមជន្លាប់ព្រោះទឹកអប់ខ្ទឹមចន្ទន៍ ឈ្ងុយរំភើយ ផ្ញើឲ្យនេនខ្ញុំដែលនៅជាសង្ឃ ឈប់ចង់ស្លែងកេហ៊ានស្លុតទៀត ៗ

ត្រឡប់ទៅដល់វត្តព្រះវិហារធំវិញ, នេនខ្ញុំ អួលអុំដោយតណ្ហាក៏បបួលនេនពេជ្រលាលោកគ្រូចាកសិក្ខាបទ ៗ លោកគ្រូចៅអធិការបើកឲ្យនេនពេជ្រសឹក, ឯចំណែកនេនខ្ញុំលោកមិនឲ្យសឹកទេ ព្រោះលោកទាយទៅឃើញថា បើសឹកនៅពេលនេះរួចកាលណា ខ្ញុំនឹងត្រូវអន្តរាយធំ ៗ នេនខ្ញុំបានតែទៅពឹងម្ដាយដោយសំដីកុហាក់ ឲ្យមកជួយអង្វរលោកគ្រូទៀត ប៉ុន្តែលោកគ្រូនៅមិនអនុញ្ញាតឲ្យសឹកដដែល ៗ ពោរពេញទៅដោយសេចក្ដីទឹករពុក ដល់នាងក្រមុំទាវ, នេនខ្ញុំតែទៅដោះស្បង់ចីពរចោលក្រោមដើមឈើម្នាក់ឯងទៅ ៗ

សឹករួចកាលណា, ខ្ញុំទៅសូមខ្មាលាទោសលោកគ្រូ, ទៅសូមខ្មាលាទោសម្ដាយ ហើយបបួលពេជ្រទៅស្រុកត្បូង.

យំតាមដើម្បីបានជួបមុខតាវដ៏ជាទីស្រឡាញ់ ។ ទុំនិងតាវបាន រួមគ្រែគ្នាដោយលួចលាក់ ហើយបានតាំងចិត្តប្ដេជ្ញាស្លាប់រស់ ជាមួយគ្នារហូតដល់ទីអវសាន ។

នាងតាវមិនលុះតាមជូនដាន់ជាម្ដាយ ដែលសុខចិត្ត លើកនាងឲ្យទៅម៉ឺនងួន, កូនប្រុសរបស់លោកអរជូន ចៅ-ហ្វាយស្រុកត្បូងឃ្មុំទេ ។ ជូនដាន់បង្ខំចិត្តកូនក្រមុំគាត់ទាំង យប់ទាំងថ្ងៃ !...

នៅសម័យនោះ, ព្រះចៅប្រទេសខ្មែរយើងទ្រង់ព្រះ នាម ព្រះរាមា ។ ព្រះអង្គបានឮឈ្មោះទុំ, តូកែច្រៀង ហើយនិងឈ្មោះពេជ្រ, តូកែផ្លុំខ្លុយ ក៏ទ្រង់ចាត់អាមាត្យទៅ កេណ្ឌយកមកលង្វែក, រាជធានីអាណាចក្រកម្ពុជា ។ ទុំបាន លានាងតាវ ទៅស្រុកបាភ្នំលាលោកគ្រូ, ម្ដាយ ; ញាតិមិត្ត រួចចុះទូកទៅគាល់ស្ដេចជាមួយពេជ្រ ។ ខ្លុយពេជ្រនិងចម្រៀង ទុំបានធ្វើឲ្យព្រះរាមាពេញព្រះទ័យយ៉ាងខ្លាំង ។ ព្រះអង្គបាន លើកទុំជាម៉ឺនឯក, ពេជ្រជាចៅពញា ។ ក្រោយមកទៀត,

ព្រះរាមាបានចាត់នាម៉ឺនមន្ត្រីឲ្យរើសស្រីណាមួយល្អយកមកធ្វើជាស្នំមហេសី ៗ នាងទាវដែលមានរូបឆោមលោមពណ៌ផ្ដាច់គេ, ក៏ត្រូវបានអាមាត្យចាប់យកមកលង្វែក ៗ ម៉ឺនងួន, អរជូននឹងជូន ផាន់ មិនហ៊ានរឹងទទឹងនឹងព្រះបញ្ជាទេ ពិតមែនតែបានលើកខាន់ស្លា ទាំងបង្គំរួចទៅហើយ ៗ ជូនផាន់, នាងទាវនឹងនាងនោះបាននាំគ្នាមកដល់លង្វែក ៗ នាងទាវមិនត្រេកអរនឹងមកធ្វើមហេសីស្ដេចទេ, នាងនឹកទៅទុំជាគូកំសត់ជានិច្ច ៗ ចំណែកជូនផាន់វិញ, គាត់ត្រេកអរនឹងបុណ្យ លង្វែកខ្លាំងណាស់ ៗ គាត់ភ្លេចនឹកនា ដល់ម៉ឺន-ងួនដែលគាត់គាប់ចិត្តពីថ្ងៃមុននោះទៅវិញហើយ ៗ

ឃើញនាងទាវចូលដល់វាំង, ដោយអំណាចសេចក្ដី–ស្នេហា, ទុំភ្លេចចេស្ដាព្រះរាមា, ក៏បានប្រៀងទូលស្ដេចថា: ទាវជាគូសង្សាខ្ញុំ ៗ ព្រះរាមាទ្រង់ខ្ញាល់នឹងនាងទាវដែលហ៊ានស្រឡាញ់ប្រុសដោយចិត្តឯង, តែព្រះអង្គមិនយកទោសពៃរ៍អ្វីទេ បែរជាទ្រង់សួរ ទុំ – ទាវ ឲ្យឆ្លើយប្រាប់តាមត្រ

ទៅវិញ ៗ ខ្ញុំនឹងនាងស្របមាត់គ្នា,ទូលស្តេចថា: ស្រឡាញ់ ស្រឡាញ់គ្នាមែន! . . . ។ ព្រះបាទពាមា ក៏បានរៀបការ ឲ្យជាប្តីប្រពន្ធ ហើយឲ្យនៅគាល់ជាពដបំរើទៀត ។

ដូនជាន់, ដែលពេញចិត្តតែនឹងបុណ្យសក្តិ ហើយនឹង លុយកាក់, ឃើញកូនស្រីបានជាភរិយាខ្ញុំកំសត់វិញ, កើតក្តី ក្តៅក្រហាយណាស់ , ក៏ទូលលាស្តេចត្រឡប់ទៅភូមិដើង ខាល, ទៅនិយាយនឹងអេដូនឲ្យដណ្តឹងនាងម្តងទៀត ៗ ស្រប គំនិតគ្នា, ដូនជាន់ឲ្យគេតែងសំបុត្រមួយច្បាប់ ផ្ញើទៅនាងថា ខ្លួនគាត់ឈឺធ្ងន់ណាស់ ,សូមឲ្យកូនស្រីត្រឡប់ទៅផ្ទះឆាប់ៗ ។

នាងស្មានថាម្តាយឈឺមែន ក៏លាប្តីវិលទៅថែជម្ងឺម្តាយ ជាមួយនឹងនាងនោ ៗ ទៅដល់ភូមិពោធិ៍ដើងខាល, បែរជា ឃើញម្តាយ កំពុងរៀបចំពិធីការឲ្យនាងនឹងម៉ឺនធ្លូនទៅវិញ ។ នាងប្រកែកដាច់អហង្ការ តែដូនជាន់ពុំព្រមស្តាប់ ៗ នាងបាន សរសេរសំបុត្រជូនដំណឹងតាសន្ទនេះទៅខ្ញុំ ។ ខ្ញុំដឹងរឿង ហេតុភ្លាម, ក៏ទូលព្រះបាទពាមា ហើយនាំពេជ្រព្រមទាំងយក

ព្រះរាជសារហាមឃាត់អរជូន ទៅស្រុកត្បូងឃ្មុំជាបន្ទាន់ ។

ខ្ញុំទៅដល់ភូមិដើងខាលឃើញគេកំពុងរៀបការ ។ ខ្ញុំមិនយករាជសារទៅឲ្យអរជូនទេ, បែរជាតែទៅស្និទ្ធស្នាលជាអស្ចារ្យ · ផឹកស្រា, ជាមួយទាវ នៅចំពោះមុខភ្ញៀវទៅវិញ ឃើញដូច្នេះ, ដូនជាន់នឹងលោកអរជូន ប្រើបាវឲ្យចាប់ខ្ញុំយកទៅសម្លាប់ទៅ ។ ទាវដឹងថាខ្ញុំត្រូវគេសម្លាប់ហើយ ក៏បានឲ្យនាងនោជាតិលៀង រកកាំបិតស្នាឲ្យមួយ ហើយនាំគ្នារត់ទៅកាន់ខ្មោចខ្ញុំក្រោមដើមពោធិ ។ នាងក៏បានចាក់កស្លាប់ក្បែរខ្មោចខ្ញុំនោះទៅ ។ ឯនាងនោក៏បានសម្លាប់ខ្លួនទៅជាមួយនឹងគេដែរ ។

ពេជ្រយកដំណឹងមហន្តរាយនេះទៅទូលព្រះរាមានៅលង្វែក ។ ព្រះរាមាទ្រង់ក្រោធ, ក៏បានលើកទាហានមកស្រុកត្បូងឃ្មុំ ហើយបានកាត់ទោសសម្លាប់រាស់ក្បាល លោកអរជូន· ម៉ឺនជួន នឹង ដូនជាន់ ព្រមទាំងដាក់ទណ្ឌកម្មដល់អ្នកស្រុកត្បូងឃ្មុំទាំងមូលជា „ អ្នកងារ ” ។

# បុគ្គលិកលក្ខណៈរបស់តួនីមួយៗ

## បុគ្គលិកលក្ខណៈព្រះរាមា

ព្រះរាមាទ្រង់សព្វព្រះរាជហឫទ័យ នឹងសិល្បៈជាតិខ្លាំងណាស់ ៗ ព្រះអង្គបានលើកតំកើង សិល្បករខ្មែរពីររូប គឺទុំហើយនឹងពេជ្រ ដោយទ្រង់បានប្រទានបុណ្យសក្តិដល់អ្នកទាំងពីរជា មុនឯក នឹងជាចៅពញា ៗ តែអំពើនេះយើង មិនបាត់ទុកជាអំពើប្រសើរណាស់ណាទេ ពីព្រោះព្រះរាមាមិនបានឲ្យសិល្បករពីររូបនេះ ទៅស្ដែងសិល្បៈ ដើម្បីជាប្រយោជន៍ដល់ ប្រជាជនខ្មែរ ខ្លួទៅឡើយ ៗ បំពេញកាមតណ្ហាវិញ ព្រះរាមាបានឲ្យអាមាត្យដើររកក្រមុំរូបល្អ យកមកថ្វាយ ៗ នេះជាអំពើអមនុស្សធម៌ ប៉ុន្តែជាអំពើធម្មតាក្នុងសម័យ សក្តិភូមិៗ តែយើងបានសំគាល់ឃើញថា ព្រះរាមាទ្រង់បានបោះជំហានទៅកាន់ផ្លូវមនុស្សធម៌ខ្លះហើយ ដោយទ្រង់ពុំបានពង្រាត់បង្រាស នាងទាវពីបណ្ឌិតទុំជាគូសង្សារចាស់, ទ្រង់បានរៀបការឲ្យអ្នកទាំងពីរ បានគ្នាជាប្ដីប្រពន្ធពេញលក្ខណៈទៅវិញ ៗ

ពោះបីអំពើនេះ បានកើតឡើងដោយសារសេចក្ដីខ្លាចស្អៀន បំពោះខ្ញុំក៏ដោយ ក៏យើងអាចចាត់បានថា: ជាអំពើថ្លៃថ្នូរហើយ ៗ មួយវិញទៀត, ព្រះករុណាទ្រង់បានចេញព្រះរាជសារ ហាមឃាត់អរជូនជានាម៉ឺនអាក្រក់ កុំឲ្យពង្រាត់បង្រាសនាងទាវពីខ្ញុំផងទៀត ៗ នេះជាអំពើល្អដែរ ពិតមែនតែគុណអំពើនេះមានគោលបំណង រក្សាព្រះរាជអាជ្ញាឲ្យគង់វង្សក៏ដោយ ៗ បំពោះបញ្ហាតុលាការវិញ,ព្រះករុណា មិនបានកាត់ទោស លោកអរជូន ដោយផ្ទាល់ព្រះអង្គទេ, ទ្រង់បានដាក់ការ:នេះទៅឲ្យនាម៉ឺនទាំងឡាយ ៗ ត្រង់នេះសរឲ្យឃើញថាព្រះអង្គមានការវៃឆ្លាតណាស់, ទ្រង់មិនបានកាន់អំណាចផ្ដាច់ការទេ ៗ គួរកត់សំគាល់ថែមទៀតថា: ព្រះករុណាទ្រង់មិនទទួលសំណូក ដែលលោកអរជូនយកមកសូកសោះឡើយៗ

រឿងកាត់ទោសកាត់ក្បាលសម្ងាប់លោកអរជូន ជារឿងធម្មតាទេ, ប៉ុន្តែរឿងដាក់ទណ្ឌកម្ម ដល់អ្នកស្រុកត្បូងឃ្មុំទាំងមូលជា «អ្នកងារ »នោះ ឃើញថាហួសហេតុពេក ៗ

## បុគ្គលិកលក្ខណៈនាងទាវ

នាងទាវជាបុត្រីរបស់ជូនដាន់នៅក្នុងស្រុកត្បូងឃ្មុំ ។ ក្នុងចំណោមតួអង្គទាំងឡាយក្នុងរឿងទុំទាវនេះ មានតែនាងទាវមួយទេដែលមានលក្ខណៈប្រសើរជាងគេ គួរឲ្យយើងកោតសរសើរ ។ ពិតមែនតែនាងបានប្រព្រឹត្តផ្ទុយនឹងចេតនារម្មណ៍នៃព្រះពុទ្ធសាសនា ដោយបានបូជាផាហ៊ុមព្រោះទឹកអប់ខ្ទឹម-ចន្ទន៍ទៅឲ្យសាមណេរទុំ ហើយបានបួងសួងសុំឲ្យបានជួបរួមរក្សនឹងទុំនៅក្នុងជាតិនេះនឹងក្នុងជាតិទៅអនាគតទៀត យើងមិនចាត់ទុកអំពើនេះថាជាអំពើអាក្រក់ណាស់ណាទេ ពីព្រោះសេចក្ដីស្រឡាញ់ជាច្បាប់របស់ធម្មជាតិ ។ យើងមិនរិះគន់នាងទាវ ក្នុងការដែលនាងលួចស្រឡាញ់ព្រះសង្ឃទេ តែយើងមិនពេញចិត្តក្នុងរឿងស្រឡាញ់ដោយឥតបានត្រិះរិះជាមុន ។ មុននឹងស្រឡាញ់នារីណាឬបុរសណា យើងត្រូវសង្កេតមើលកិរិយាមារយាទរបស់នារីនោះឬបុរសនោះឲ្យបានច្បាស់លាស់សិន ។ ប្រញាប់ពេកក្រែងរាំខុស! ។ ចំពោះបញ្ហារួមរក្សគ្នា

ដោយលួចលាក់ជាមួយនឹងទុំ ជារឿងដ៏ស្មោគគ្រោតគ្រៃលែង, តែនាងទាវជានារីមួយ មានស្វាមីភក្តិចំពោះគូស្នេហាតែមួយរបស់នាងដែរ ដែលជាហេតុធ្វើឲ្យអំពើអាក្រក់នេះ បានជាស្អាតស្អំទៅវិញ ។ មានតែទុំមួយទេដែលអាចប៉ះពាល់ដល់រាងកាយនាង ក្នុងមួយជាតិនេះ ។ នាងមិនត្រូវការទេកម្លោះម៉ឺនងួន កូនលោកអរជូន, ចៅហ្វាយស្រុកត្បូងឃ្មុំ ។ នាងមិនត្រូវការទេ អំណាចលង្វែក គឺព្រះបាទរាមា ។ ទាំងនេះសរឲ្យឃើញថា ទាវជានារីល្អ ; ចេះរក្សាកេរ្តិ៍ឈ្មោះរបស់នាងឲ្យបានគ្រប់ នៅក្នុងសង្គមកុំឲ្យធុំស្អុយរលួយ ដូចនាងកាកីកញ្ញាផែតឆាយ កើតចេញពីផ្កាកណិការតាមសេចក្តីស្រមៃរបស់ព្រះបាទអង្គឌួង ។ ទាវជានារីបដិវត្តមួយរូបក្នុងសម័យសក្តិភូមិ ។ នាងបានក្រោកឡើងប្រឆាំងនឹង "អំពើមាតាបង្ខំកូន" នាងប្រឆាំងនឹងទំនៀម "ទំមិនដែលធំជាងនាឡិ" ។ ទាមទារសិទ្ធិរបស់នារីក្នុងការជ្រើសរើសគូស្រករ, ពោលគឺក្នុងការស្វែងរកសុភមង្គលសម្រាប់ខ្លួនទៅអនាគត ។ យើងសូម

សរសើរដល់សេចក្ដីក្លាហានរបស់នាងក្នុងរឿងនេះ ហើយអ្នកផងទាំងពួងក៏មិនអាចត្មះតិះដៀល ថានាងជានារីអកតញ្ញូបានដែរ ។ ការពិត នាងជានារីកតញ្ញូ ។ គ្រាន់តែឮដំណឹងថាម្ដាយឈឺភ្លាម ,នាងប្រញាប់ប្រញាល់ទៅថែរក្សាភ្លាម,ក៏ប៉ុន្តែម្ដាយនាងឈឺទន្ទ្រាយពោះ(យាយផាន់បញ្ឆោតកូនស្រីឲ្យទៅផ្ទះដើម្បីបង្ខំឲ្យរៀបការនឹងមឺនង្គួន) ។ ក្នុងពេលនេះនាងទាវបានបង្ហាញដល់សាធារណជន នូវសេចក្ដីស្វាមីភក្ដិរបស់នាងចំពោះទុំ ជាស្វាមីកំសត់ម្ដងទៀត គឺនាងសរសេរសំបុត្រមកប្រាប់សេចក្ដីពិតដល់ស្វាមី ហើយនៅពេលដែលម្ដាយនាងខឹងលោកចៅហ្វាយស្រុក ឲ្យគេចាប់ស្វាមីនាងយកទៅសម្លាប់នោះ, នាងក៏ដាច់ចិត្តចាក់កស្លាប់ក្បែរសពទុំដែរ ។ នាងសម្លាប់ខ្លួននេះជាភស្តុតាងមួយលាតត្រដាងឡើង នូវសេចក្ដីស្មោះត្រង់របស់នាងចំពោះប្ដី សមដូចពាក្យដែលនាងបានសច្ចា៖ „ស៊ូស្លាប់ស៊ូរស់ជាមួយគ្នាក្នុងជាតិនេះ „ ។ អំពើរបស់នាងទាវនេះ ជារបៀបដោះស្រាយគ្រាប់ផុតនៃបញ្ហា

ស្អុកស្អាញតក់ស្រុះនៅក្នុងសម័យបែបនោះ ៗ

យើងសូមសរសើរដល់នារីទាំងឡាយដែលមានចិត្តភក្តីចំពោះបុរសតែមួយដូចជានាងទាវនេះ តែយើងសូមផ្តាំដល់នារីទាំងឡាយថា : បើនាងជួបប្រទះនឹងវិបត្តិស្នេហាដូចនាងទាវ, សូមនាងកុំសម្លាប់ខ្លួនឯងដូចនាងទាវឲ្យសោះ ព្រោះការប្រហារជីវិតរបស់ឯង មិនមែនជាការដោះស្រាយបញ្ហាតឹងតែងទេ ៗ

បុគ្គលិកលក្ខណៈបណ្ឌិតខ្ញុំ

ខ្ញុំជាបុត្រសម្លាញ់របស់ស្រីមេម៉ាយមួយរូប នៅស្រុកបាភ្នំ, ខេត្តព្រៃវែង ៗ កាលនៅក្នុងកុមារភាព, ខ្ញុំមានប្រាជ្ញាភ្លឺវៃណាស់ ៗ ទៅនៅវត្តព្រះវិហារធំ, ខ្ញុំរៀនសូត្រចាប់ចេះចាប់ចប់ មិនតែប៉ុណ្ណោះ ខ្ញុំមានសម្លេងពីរោះផងៗ ប៉ុន្តែក្រោយមកដោយអាងទៅលើ ទឹកព្រះទ័យមេត្តាករុណារបស់លោកគ្រូចៅអធិការ, ខ្ញុំបានបណ្ដោយខ្លួន ឲ្យសេចក្ដីខ្ជិលចូលមកអូសទាញ បណ្ដើរយកទៅកាន់ភាពស្អាកក្រាក ៗ ស្មៀក

ដណ្ដប់ស្បង់ចីពរលឿង, កោរក្បាល 'កោរកេមចិញ្ចើម, តែសាមណេរខ្ញុំពុំបានកាន់វិន័យ ឲ្យត្រឹមត្រូវតាមពុទ្ធបញ្ញត្តិឡើយ ៗ ខ្ញុំមិនរៀនធម៌អាថ៌ទេ, ខ្ញុំធ្វើតាកលក់ ៗ លក់នៅស្រុកជិត ៗ នេះមិនសប្បាយទេ ត្រូវធ្វើដំណើរទៅស្រុកឆ្ងាយទៀត . . . នេះជាគំនិតមួយផ្ទុយស្រឡះនឹងគំនិតអ្នកបួសតាំងឡាយ ៗ ខ្ញុំនិយាយនឹងពេជជាគួកនថា៖

« បុរាណលោកថាមិនខុសសោះ
ពួកយើងកម្លោះក្នុងលោកិយ
ដេកស៊ីបាយវត្តមិនចេះអី
នៅចុះគួរត្រាច់ដើរស្រុកឆ្ងាយ » ៗ

មិនត្រឹមតែដើរធ្វើដំនួញប៉ុណ្ណោះទេ ខ្ញុំទៅសូត្រ « ខ្ញុំនឹកអូនអើយបងអើយ » នៅក្នុងផ្ទះលោកយាយផាន់ ឯស្រុកត្បូងឃ្មុំទៀត ៗ នេះឬពាក្យថាៈ « បួសដើម្បីដើរប្រាសសត្វ » ? ៗ សម្ដីពាក្យរបស់សាមណេរខ្ញុំ បាននាំមកឲ្យខ្ញុំវិញនូវសេចក្ដីស្នេហាមួយ ដែលបព្វជិតតាំងឡាយ ខ្ពើម

រអើមជាទីបំផុត ៗ យើងដឹងច្បាស់ទៀតថា៖ អាស្រ័យដោយ
ទំនុកច្រៀងបំពេ ស្ងួនបង ៗ យ៉ាងទន់ភ្លន់នេះហើយ ដែល
បណ្ដាលឲ្យព្រះកាមា ស្រេកឃ្លានក្តីកាមតណ្ហាបាត់អា-
មាត្យឲ្យដើររកចាប់កូនក្រមុំប្រជាជន យកមកថ្វាយជាគ្រឿង
សប្បាយ ៗ .. ខ្ញុំទៅលក់គោក , ខ្ញុំបែបដ៏ស្រី ! រឹលត្រឡប់
មកវត្តវិញ ខ្ញុំដេកមមៃផលក្នុងឈាបស្រែកត្សូយំ ៗ ខ្ញុំភ្លេចវិន័យ,
ភ្លេចបាយភ្លេចទឹកនឹកគិតតែម្យ៉ាង គឺស្នេហា ៗ ខ្ញុំដេកឱបផា-
ហ៊ុម រូបខ្ញុំឡើងទៅលាលោកគ្រូសិក្ខ ៗ ខ្ញុំឈប់ គិតផលបាន
ស្ងួត បាននិព្វានទៀតហើយ ៗ លោកគ្រូមិនព្រមឲ្យសិក្ខ
ខ្ញុំរត់ទៅនិយាយបោកក្តតម្ដាយថាខ្លួនឈឺធ្ងន់ នៅបួសទៀតមិន
បានទេ សូមអ្នកម្ដាយទៅជួយសុំសេចក្ដីអនុញ្ញាត អំពីលោក
គ្រូឲ្យផង ៗ ឃើញទេ សាមណេរខ្ញុំ ចេះនិយាយកុហក
ទៀតហើយ ..! ទីបំផុតខ្ញុំក្បត់វិន័យព្រះពុទ្ធសាសនា, ក្បត់
ច្បាប់សីលធម៌ រត់ទៅស្រាតស្បង់ចីពរចោលកណ្ដាលព្រៃ
បន្ទាប់មកអន្ទិតខ្ញុំ រត់ទៅរកនារីយ៉ាងប្រញាប់ ៗ គេបានទៅ

ល្បួងមេគ្រួសារដោយគាថាកំបាំង, ដែលជាអំពើមួយក្បត់នឹងប្រពៃណីរបស់ជាតិខ្មែរយើង ។

ពេលដែលសង្សារទាំងពីរនេះបែកគ្នា ហើយដែលបានជួបគ្នាឡើងវិញនៅចំពោះព្រះភក្ត្រព្រះរាមាជើងព្រៃនោះ, អ្នកខ្លះសរសើរថា: ទុំជាបុរសក្លាហាន ហ៊ានទូលស្តេចតាមត្រង់ ថាទាវជាគូស្នេហ៍របស់ខ្លួន ។ យើងមិនសរសើរទេ ។ បុរសដែលហ៊ានពោលស្តី ហ៊ានធ្វើការអ្វី ៗ ដែលគិតតែរឿងស្នេហា យើងមិនចាត់ទុកថាជាបុរសក្លាហានឡើយ ។ តែយើងទទួលស្គាល់ថា ទុំបានបំពេញករណីយកិច្ចរបស់ខ្លួនចំពោះគូសង្សារដែលបានសន្យាគ្នាថា: « ស៊ូស្លាប់រស់ជាមួយគ្នាក្នុងជាតិនេះ » ។ អាស្រ័យដោយបានគោរពនូវពាក្យសច្ចៈ ម៉ឺនឯក ឬអនុទិតទុំបានជួបវរមិត្តនាងទាវឡើងវិញ ដោយសេចក្តីអនុគ្រោះពីព្រះមហាក្សត្រ ។ ក្រោយពេលដែលអរជូននឹងជូនជាន់ បញ្ឆោតយកបាននាងទាវទៅរៀបការឲ្យ

ម៉ឺនធ្លួន ,  ព្រះរាមាបានចេញព្រះរាជសារមួយឲ្យខ្ញុំយកទៅឃាត់លោកអរជួន ដើម្បីនាំយកទាវមកលាផ្ដែកវិញ ៗ ខ្ញុំក្ដើណាស់ ៗ ពេលមានគ្រោះភ័យដូច្នោះ ខ្ញុំបានប្រកាន់យកសុរាធ្វើជាគារ៉ុតការពារខ្លួន ៗ ដើរទៅដល់ផ្ទះជួនផាន់ , ខ្ញុំមិនយកព្រះរាជសារ ទៅឲ្យលោកអរជួនទេ បែរជាផឹកស្រាស្រវឹងវក់វី  ហើយទៅប្រឡូកប្រឡែងនឹងនាងទាវនៅចំពោះមុខគ្រឿងតាំងឡាយ  ដែលអញ្ជើញមកជាកិត្តិយសក្នុងពិធីអាពាហ៍ពិពាហ៍នោះ ៗ នេះឬ ពាក្យដែលថា : ផឹកស្រា ដើម្បីក្លាហាន ? ផឹកស្រាក្លាសំដី ? . . . . ព្រោះតែស្មារតីខ្ញុំរត់ទៅចូលក្នុងដបស្រានេះហើយ បានជាខ្លួនរបស់ខ្ញុំ ត្រូវបានអ្នកបំរើរបស់លោកអរជួន  ចាប់យកទៅសម្លាប់ចោល  ក្រោមដើមពោធិមួយធំក្នុងភូមិជើងខាល ៗ

## បុគ្គលិកលក្ខណៈជួនផាន់

ជួនផាន់ជាមាតារបស់នាងកញ្ញាទាវ  មានទីលំនៅឯភូមិជើងខាល  ស្រុកត្បូងឃ្មុំ  គាត់ជាអ្នកមានទ្រព្យបង្គួរក្នុងភូមិ

នោះ ៗ អ្នកគានខ្លះមានយោបល់ថា : ជូនផាន់ជាមាតាប្រសើរណាស់ ៗ មែនហើយ! យោបល់នេះក៏មិនខុសដែរ, ពីព្រោះយើងបានពិនិត្យនៅឃើញថា: ជូនផាន់បានខំខ្នះខ្នែងស្វែងរកស្នុកមង្គលឲ្យកូនស្រីគាត់ប្រាកដមែន ៗ គាត់មិនចង់ឲ្យកូនស្រីសេសទៅក្នុងភាពក្រីក្រទេ ៗ គាត់ចង់ឲ្យកូនស្រីមានទ្រព្យបរិបូណ៌, មានមាសពេជ្រ មានលុយកាក់ចាយវាយហ៊ឺហា ៗ គាត់ចង់ឲ្យកូនស្រីបានឡើងឋានៈជាលោកជំទាវ ឬអ្នកម្ចាស់! ៗ ដើមឡើយ, គាត់ស្រឡាញ់សាមណេរទុំ ដែលជាអ្នកប្រាជ្ញខាងពុទ្ធសាសនា ( ? ) មានគេគោរពរាប់អានច្រើន ៗ គាត់ចង់ឲ្យកូនស្រីបានជាប្រពន្ធ « លោកអាចារ្យ » ៗ បន្ទាប់មកគាត់ពេញចិត្តនឹងម៉ឺនង៉ូនវិញ ព្រោះម៉ឺនង៉ូនមានបុណ្យសក្តិខ្ពង់ខ្ពស់ជាងទុំ ហើយជាកូនអ្នកមានសម្បត្តិស្តុកស្តម្ភផង ៗ ក្រោយមកទៀត, គាត់គ្រេកអរនឹងបុណ្យលាភផ្លែក បែរជាស្អប់ម៉ឺនង៉ូនទៅវិញ ព្រោះគាត់ចង់ឲ្យកូនស្រីឡើងឋានៈជាអ្នកម្ចាស់ ហើយខ្លួនគាត់ជាម្តាយក្មេកស្តេចពាមា ៗ ឃើញទេ! ជូនផាន់មាន

ចិត្តលោកលន់ជានិច្ច ៗ គាត់លោភ! ព្រោះគាត់ប្រាថ្នា
ឲ្យកូនស្រីគាត់បានទទួលនូវសុភមង្គល ក្នុងមួយជីវិតនេះ ៗ
មាតាដែលបេះគិតដល់អនាគតរបស់កូន ជាមាតាប្រសើរ
ណាស់: ក៏ប៉ុន្តែ, មាតាទាំងឡាយត្រូវយល់ឲ្យច្បាស់ថា:
របស់អ្វីដែលកូនមិនពេញចិត្ត របស់នោះពុំអាចនាំសុភមង្គល
មកឲ្យកូនបានឡើយ ៗ សុភមង្គលកើតចេញអំពីចិត្តរបស់
មនុស្ស ហើយមនុស្សម្នាក់ៗ មិនអាចយកសុភមង្គលរបស់
ខ្លួន ទៅរំលែកចែកឲ្យអ្នកដទៃបានទេ ៗ ដូនផាន់យល់ឃើញ
ថា: ក្នុងលោកនេះមានតែបុណ្យសក្តិ និងប្រាក់កាសប៉ុណ្ណោះ
ទេ ដែលអាចនាំសុភមង្គលមកឲ្យមនុស្សបាន ៗ នេះហើយ
ជាទស្សនទិយមខុសរបស់គាត់ ៗ គាត់មើលឃើញប្រាក់
កាសមានតម្លៃជាងជីវិតមនុស្សទៅទៀត ៗ គំនិតបែបនេះ
ហើយដែលគេហៅថា: គំនិតមូលធននិយមឬបក្រពត្តិនិយម ៗ
ដូនផាន់បានរាយដំបន្លំកូនស្រីឲ្យស្រឡាញ់ម៉ុនង្លួន ដោយ
សំអាងទៅលើពាក្យចាស់គំរលផ្តាំបន្តថា : "នំមិនដែល

ជាន់នាឡិទេ” ។ តារាបានចំតក៏តាមតារសិទ្ធិរបស់នាង កូនការជ្រើសរើសគូស្រករ តែជូនជាន់ពុំព្រមទទួលស្គាល់សោះ ។ គាត់នៅតែបបេសថា: «ខ្ញុំមិនដែលធំជាន់នាឡិ» ប្រាក់កាសនាំមកនូវស្លុតមន្ទិល ។ ដោយគាត់មានទស្សនទិយមបង្អៀតបង្អល់បែបនេះបានជាកូនស្រីគាត់ត្រូវបាត់បង់ជីវិត; រូបគាត់ក៏ត្រូវវិនាសយ៉ាងដូចតដែរ ។ គំនិតនិងអំពើរបស់គាត់ បានធ្វើឲ្យអ្នកស្រុកត្បូងឃ្មុំតាំងមូលរង់ទុក្ខវេទនាជិត ៣០០ ឆ្នាំ ។

## បុគ្គលិកលក្ខណៈអរជួន

លោកអរជួន មានឋានន្តរស័ក្តិជាចៅហ្វាយស្រុក ។ ត្បូងឃ្មុំនាសម័យលង្វែក ក្នុងរជ្ជកាលព្រះបាទពញាដើងព្រ (១.៥៩៤ ដល់ ១៥៩៦) ។ ក្នុងគ្រួសាររបស់លោក, លោកអរជួន មិនបានកាន់អំណាចផ្ដាច់ការទៅលើភរិយានិងបុត្ររបស់លោកទេ ។ រឿងក៏វ៉ីទិមួយៗ លោកបានពិគ្រោះសួរមតិភរិយារបស់លោកទាំងអស់ មានរឿងអនាគតកូនប្រុសជាតួយ៉ាង ។ គំនិតនេះជាទស្សនៈរបស់សាធារណជនគ្រប់កាល

សម័យ ។ ក៏ប៉ុន្តែ, ប្រជាជនខ្លះតិះដៀលជាទីបំផុតចំពោះអាកប្បកិរិយារបស់លោកអរជូន ដែលបានប្រព្រឹត្តទៅលើប្រជាជនក្នុងស្រុកត្បូងឃ្មុំ ក៏ដូចជាប្រជាជនខ្មែរទាំងសាកល ។ លោកអរជូនឃោរឃៅណាស់ ដូចពាក្យយាយផាន់ប្រាប់ទៅអ្នកបំរើលោកជាអ្នកនាំផ្សំទៅមហាថា:

“ ឧកញ៉ាអរជូនមាំមួនពេក
ធម្មតាក្រោមមេឃពាបផានក្ខំ
មានឫទ្ធិអំណាចឥតដំនុំ
កាប់ចាក់ឲ្យដំពុំប្រណី ” ។

លោកចៅហ្វាយស្រុកបានរំលោភលើសិទ្ធិក្រត្តូចតាប មានបណ្ឌិតធុំជាដើម ។ លោកបានពង្រាត់បង្រាស់គូស្រករគេ បានតាប់បង្ខំប្រពន្ធគេឲ្យរៀបការនឹងកូនប្រុសលោក, ដែលជាអំពើពុករលួយ ស្អុយជាប់ដល់សព្វថ្ងៃ ។

មិនត្រឹមតែបានធ្វើទុក្ខបុកម្នេញប្រជាជនប៉ុណ្ណោះទេ, លោកអរជូនជាមន្ត្រីមួយរូបបានក្បត់នឹងច្បាប់សម្រាប់រដ្ឋផង គឺ

លោកបានរំលោភលើរាជអាជ្ញានៃព្រះមហាក្សត្ររបស់ឯង ៗ ព្រះមហាក្សត្រ ទ្រង់បានសព្វព្រះរាជហឫទ័យរៀបការទុំនឹងទាវឲ្យបានជាគូស្វាមីភរិយាពេញលក្ខណៈ ឯលោកអរជូនខំរកមធ្យោបាយបំបែកបំបាក់គូស្រករថ្មីនេះទៅវិញ ៗ មនុស្សរបៀបអរជូន យើងមិនរាប់ទុកជាមនុស្សឡើយ ៗ គឺជាសត្វតិរច្ឆាន! ព្រោះវាបានជញ្ជក់ឈាមពស្ត្រដូចសត្វឈ្លើងជញ្ជក់ឈាមមនុស្សអញ្ចឹងដែរ ៗ ព្រះរាមាដាក់ទណ្ឌកម្មលោកអរជូនសមហេតុសមផលមែន! . . . . ស្លាប់ទៅចុះ! មនុស្សតិរច្ឆាន . . . គួរកត់សំគាល់ទៀតថា: ក្នុងពេលភ័យអាសន្ន អរជូនបានយកសំណូកទៅថ្វាយ នេះជាអំពើមួយអាក្រក់បំផុត ៗ

## បុគ្គលិកលក្ខណៈម៉ឺនជួន

អ្នកកម្លោះម៉ឺនជួនជាបុត្ររបស់លោកអរជូន ៗ លោកសន្ធរម៉ុកបានប្រាប់យើងថា: ម៉ឺនជួន បានអង្គុយរៀបការទើងនាងទាវដោយចេតនា ៗ នឹកដល់រឿងនេះ, យើងព្រឺក្បាល

ព្រមទាំងខ្ពើមអើយជាពន់ពេកៗ យើងព្រឺក្បាល, ព្រោះបើសិន
ជាយើងវិញ យើងភ័យ, ខ្លាចប្ដីនាងទាវមកកាប់ក្បាលយើងក្នុង
ពេលរៀបការនោះៗ យើងមិនហ៊ានអង្គុយផ្ទឹមនឹងប្រពន្ធគេ
ដូចមុននឹងទេៗ យើងសុខចិត្តបាញ់កូនលោកអរជូនក្នុងរឿង
នេះៗ ថ្វីបើឪពុកយើងមានបុណ្យស័ក្តិ មានអំណាចដូច
ស្ដេចក្រាញ់ក៏ដោយ, អំណាចនេះមិនអាចធ្វើឲ្យខ្ញុំសុខចិត្តបោះ
បង់នាងទាវចោលឡើយៗ សូម្បីតែអំណាចព្រះមហាក្សត្រ
ក៏បណ្ឌិតខ្ញុំ ឥតញញើតដែរ ក្នុងបញ្ហាស្នេហានេះៗ ខ្ញុំហ៊ាន
ប្រៀនខ្លួនស្ដេចដើម្បីផ្ដាច់ព្រះរាជបំណាង ទៅលើរូបនាងទាវ
ឥតកោតក្រែងព្រះបេស្ដាទេៗ យើងអើយ! ព្រោះយើង
យល់ឃើញថា: កម្លោះមុននឹងជាមនុស្សខ្វះការពិចារណា,
មើលឃើញកាលខ្លី, មិនចេះគិតដល់ដំណើរជីវិតរបស់ខ្លួន
ទៅអនាគតៗ មុននឹងខ្វះការពិចារណា, ព្រោះគាត់ហ៊ានរៀប
ការជាមួយនឹងស្រី ដែលមិនស្រឡាញ់គាត់សោះៗ គាត់
មើលឃើញកាលខ្លី, ព្រោះគាត់កាន់ទៅលើអំណាចបិតាគាត់

កូនក្រោនោះ ៗ គាត់មិនចេះគិតដល់ដំណើរជីវិតទៅអនាគត, ព្រោះគាត់មិនចេះរើកញែកឲ្យច្បាស់លាស់ នរណាមួយជាមិត្ត នរណាមួយជាសត្រូវ? ការជាមិត្តកុងមួយជីវិតឬ? មិនមែនទេ!.... ស្រីដែលមិនស្រឡាញ់យើង តែងតែបំផ្លាញសុភមង្គល របស់យើងពិតប្រាកដណាស់ ៗ

ដូច្នេះ, មុឺនងួនជាយុវជនអ្នកថយ, គ្មានការសិក្សាអប់រំចិត្តគំនិតទាល់តែសោះ ៗ

យុវជនរបៀបនេះ ជាទីខ្ពើមរអើម នៃបណ្តាយុវជនខ្មែរទាំងឡាយក្នុងសម័យវិទ្យាសាស្ត្រជឿនលឿននេះ ៗ

---

## បុគ្គលិកលក្ខណៈពេជ្រ

សេពគប់នឹងខ្ញុំដែលជាមិត្តអាក្រក់, លោកនេនពេជ្រលះបង់ធម្មវិន័យ, ខំប្រឹងរៀនផ្លូវយទឹងធ្វើគោកលក់ ៗ តែយើងបានដឹងតាមគន្លងស្នាបបាកការបស់សន្ធរម៉ុកថា: ពេជ្រគ្រាន់បើជាងខ្ញុំ ៗ ពេជ្រចេះឲ្យដំបូន្មានដល់ខ្ញុំ នៅពេលដែលឃើញខ្ញុំ

ត្រូវផ្ញើស្នេហាមកញាំញី ៗ មិនតែប៉ុណ្ណោះ, តែត្រូវចេះឈឺឆ្អាលដល់មិត្តភក្តិគ្រាអាសន្នផង ៗ មនុស្សរបៀបពេជ្រគួរយកធ្វើជាមិត្តបាន ៗ

---

## បុគ្គលិកលក្ខណៈនាងនោ

នាងនោជាបាវស្រីមួយរូប មានសេចក្តីស្វាមីភក្តិចំពោះចៅហ្វាយខ្លាំងណាស់ ៗ នាងបានចំធ្វើការបំរើចៅហ្វាយនាយស្វែងរកសុខមង្គលជូនចៅហ្វាយនាយគ្រប់ពេលវេលា ៗ ដល់ទីបំផុត នាងស៊ូគ្រប់ចិត្តសម្លាប់ខ្លួនទៅតាមចៅហ្វាយនាយរបស់នាងទៀត ៗ អ្នកបំរើរបៀបនេះ ជាទីពេញចិត្តពេញថ្លើមនៃបណ្តានាយទុនទាំងឡាយ ៗ យើងមិនសរសើរទេ, ព្រោះនាងគ្មានមធ្យោបាយដោះស្រាយបញ្ហាជីវិតដោយខ្លួនឯង ៗ

# រឿងទុំទាវក្នុងអក្សរសាស្ត្រខ្មែរ

ក្នុងអក្សរសាស្ត្រខ្មែរ រឿងទុំទាវមានលក្ខណៈពិសេសជាងគេ ៗ ក្រៅអំពីសោភ័ណភាពនៃអក្សរសាស្ត្រ (Beauté littéraire) រឿងទុំទាវបានស្តែងឡើងនូវជីវភាព ពិតប្រាកដរបស់ខ្មែរគ្រប់វណ្ណៈក្នុងសម័យលង្វែក តាំងអំពីជីវភាពព្រះមហាក្សត្រ (ព្រះបាទរាមា) រហូតដល់ជីវភាពខ្ញុំកញ្ជះបាទជើងគេ (នាងនោ) ៗ រឿងទុំទាវពុំបានផ្តេកផ្តួលទៅលើមហិទ្ធិរិទ្ធិព្រះព្រហ្មព្រះពុទ្ធឡើយ ហើយក៏ពុំបានលាយឡំនឹងឥទ្ធិពល អក្សរសាស្ត្របរទេសដែរ ៗ ដូចនេះ, "ទុំទាវ" ជាបលនាអក្សរសាស្ត្រខេមរនិយម ៗ រឿងបែបនេះយើងចាត់ទុកក្នុងចំពួកអក្សរសាស្ត្ររក្សាសេចក្តីពិត (Littérature conservatrice) គឺជារឿងមួយមានប្រយោជន៍ ដល់ការសិក្សាស្រាវជ្រាវរកមើលការប្រព្រឹត្តទៅ នៃ បុព្វបុរសរបស់យើងក្នុងសម័យសក្តិភូមិ ៗ

\+ \+ \+

## ផលប្រយោជន៍នៃរឿងទុំទាវ

ទុំទាវជាកញ្ចក់ទេព្យមួយ, សម្រាប់យើងឆ្លុះមើលឃើញការប្រព្រឹត្តទៅនៃបុព្វបុរសរបស់យើង នាសម័យលង្វែកក្នុងរជ្ជ-កាល ព្រះរាមាជើងព្រៃ (១៥៩៤-១៥៩៦)ៗ យើងមើលឃើញព្រះរាមា ចាត់សេនាមាត្យដើរចាប់កូនក្រមុំរបស់ប្រជាជន យកមកថ្វាយព្រះអង្គ ទុកជាគ្រឿងកំសាន្តៗ យើងមើលឃើញលោកអរជូនជាមន្ត្រីអាក្រក់យង់ឃ្នង, បានរំលោភជិះជាន់ប្រជារាស្ត្រ' មានការពង្រាត់បង្រាស ប្ដីប្រពន្ធទុំទាវ និងប្រើអ្នកបំរើឲ្យចាប់ទុំយកទៅសម្លាប់ឥតជំនុំជាដើម ៗ យើងមើលឃើញជូនដាន់ ដែលជាអ្នកមានទ្រព្យបង្គួរ បានធ្វើបាបអ្នកក្រីក្រ ឥតត្រាប្រណីៗ (ទុំកំសត់ស្លាប់ដោយគំនិតអាក្រក់របស់ជូនដាន់) ៗ យើងមើលឃើញកូនចៅរបស់អស់លោកមន្ត្រី, មានម៉ឺនងឹនកូនលោកអរជូនជាអាទិ, គ្មានពិចារណាគេខុសត្រូវទេ, គិតធ្វើយ៉ាងណាឲ្យតែខ្លួនបានសប្បាយ, បើអ្នកដទៃស្លាប់ក៏ស្លាប់ទៅចុះ ! យើងមើលឃើញស្ត្រីភេទជំនាន់

លង្វែកនេះ ខ្វះការអប់រំខ្លួន, ខ្វះការតស៊ូតនឹងដំណើរជីវិត ។ ជួបប្រទះនឹងឧបសគ្គ ស្រ្តីភេទច្រើនតែដាច់ចិត្ត ប្រហារជីវិតខ្លួនឯងអស់សារបង់ (នាងតាវ · នោ) ។

ដោយសាររឿងទុំទាវនេះទៀត, យើងមើលឃើញទំនៀមទម្លាប់ខ្មែរបុរាណ, មើលឃើញរបបគ្រប់គ្រង មាន-បញ្ហាសេដ្ឋកិច្ច, សង្គមកិច្ចនិងតុលាការ ។ ដូចនេះ, រឿងទុំទាវ ជាកញ្ចក់របស់ជាតិ!!...

\+

\+ +

# សង្ខេបរឿងហង្សយន្ត

ព្រះបាទ អាទិត្យវង្ស សោយរាជ្យនៅនគរគ្រុឌ ទេតាបុរី, មានអគ្គមហេសីព្រះនាម ពិន្ទា, ហើយមានព្រះរាជបុត្រមួយព្រះអង្គព្រះនាម សុវណ្ណកុមារ ។

ពេលដែលព្រះរាជបុត្រពេញកម្លោះ, ព្រះបិតាបានបេញព្រះរាជបញ្ជា ឱ្យស្ដេច ១០១ ប្រទេសដែលជាប្រទេសសមន្តរាជ យករាជបុត្រីមកថ្វាយ ដើម្បី សុវណ្ណកុមាររើសយកនាងណាដែលមានរូបឆោមល្អធ្វើមហេសី ។ ក្នុងបណ្ដាព្រះរាជបុត្រីទាំងនោះ សុវណ្ណកុមារពុំសព្វព្រះហឫទ័យដល់តិចណាសោះ ។

ជាងទន្តពីររូបបានធ្វើហង្សយន្តមាសមួយ ថ្វាយសុវណ្ណកុមារ ។ បានហង្សយន្តកាលណា, ព្រះរាជកុមារនឹកក្នុងស្ងួនរកមហេសីដោយព្រះអង្គឯង ហើយក៏ទ្រង់បានទៅសូមលាព្រះមាតា បិតា កក្បួតថា: យាងទៅរៀនសិល្ប ។ បានព្រះរាជានុញ្ញាតហើយ ព្រះរាជកុមារឡើងគង់លើយន្តហោះទៅកាន់ព្រៃហិពាន្ត រួចបង្ហួសទៅដល់នគរមួយថ្មីទៀតឈ្មោះ

បញ្ចាបុរី, ចូលទៅសូមរៀនសិល្បសាស្ត្រវិទ្យា នឹងតា-ព្រាហ្មណ៍ហោរាម្នាក់ ៗ តាព្រាហ្មណ៍បាន សុំសុវណ្ណកុមារធ្វើជាកូនធម៌ ៗ ថ្ងៃមួយ តាព្រាហ្មណ៍នាំកូនធម៌ទៅ-ក្រាបបង្គំគាល់ព្រះចៅចញ្ចាបុរី តាព្រាហ្មណ៍ហោរាពុំបានទូលថ្វាយព្រះរាជានូវជីវប្រវត្តិពិតប្រាកដរបស់សុណ្ណកុមារឡើយ ៗ គ្រប់ពេលវេលា, សុវណ្ណកុមារតែងឡើងទៅគាល់ស្តេចជំនួសមុខតាព្រាហ្មណ៍ឪពុកចិញ្ចឹម ៗ

ស្តេចនគរចញ្ចាបុរីមាន បុត្រីមួយព្រះអង្គ ព្រះនាមបទុមគោសរ ៗ ទតឃើញរូបសម្បត្តិ សុវណ្ណកុមារកាលណា នាងបទុមកេសរ ក៏គួបព្រះទ័យស្នេហាក្រៃម ៗ ព្រះនាងបានចាត់គិលៀនម្នាក់ ទៅសួររឿងរ៉ាវជីវិតរបស់បុរសប្លែកមុខនេះៗ សុវណ្ណកុមារបានឆ្លើយតបគិលៀនថា: “ឈ្មោះខ្ញុំដូចជាស្ទៀតស័ក” ៗ ចំពោះប្រស្នានេះ, បទុមកេសរដោះស្រាយបានក្នុងថា: “បុរសប្លែកមុខឈ្មោះសុវណ្ណកុមារ”ៗ ព្រះនាងបានស្នើប្រស្នាទៅវិញថា: ពេលយប់, បើព្រះអង្គផ្ទុំ

ម្នាក់ឯងពុំលក់ សូមឲ្យព្រះអង្គយកព្រះពស្ត្រចឹផ្ដាប់ទៅ,,ៗ

សុវណ្ណកុមារយល់ប្រស្នានេះ ក៏យាងទៅគេព្រះនាងបុទុម-កេសរ នៅពេលកត្រីស្ងាត់នោះឯង ៗ ក្រោយដែលមានព្រះសូរសៀងឆ្លើយឆ្លងគ្នា មិមក់អស់មួយសន្ទុះ, ក្សត្រាក្សត្រីក៏ចូលផ្ទុំជាមួយគ្នា យ៉ាងសែនសុខ ៗ

យូរខែក្រោយមក ព្រះចៅនគរបញ្ចាបុរី ទតឃើញបុត្រីទ្រង់គភ៌ ក៏ប្រើគលល្បិច ចាប់សុវណ្ណកុមារបានដូចព្រះបំណង ហើយប្រើពេជ្ឈឃាដឲ្យយកទៅប្រហារជីវិត ៗ សុវណ្ណកុមារប្រើឧបាយកល ដោះព្រះអង្គរួចពីមរណភាព ៗ ស្ដេចឡើងគង់លើហង្សយន្ត ហើយនាំបុទុមកេសរចេញពីនគរបញ្ចាបុរី ធ្វើឲ្យស្ដេចផែនដីជាព្រះមាតា. បិតាក្ដុកក្រួយព្រះទ័យ ទឹងមានសេចក្ដីតក់ស្លុតយ៉ាងខ្លាំង ៗ

ហង្សយន្តហោះបានពាក់កណ្ដាលផ្លូវ, បទុមកេសរឈឺផ្ទៃ ក៏អង្វរស្វាមីឲ្យចុះចតកណ្ដាលព្រៃ ដើម្បីប្រសូត្របុត្រ ៗ លុះប្រសូត្ររួចហើយ, ព្រះនាងទ្រង់អាពាធដោយខ្យល់ផាត

គណនា ៗ ឃើញពន្លឺភ្លើងៗនៅឯនាយ, សុវណ្ណកុមារក៏ជិះ ហង្សយន្តទៅយកភ្លើងនោះមកកំដៅផ្ទុមហោសី ៗ ភ្លើងនោះ ជាចន្ទុះនាយកេត្រា ៗ អណ្តាតភ្លើងបានឆាបឆេះដាច់ខ្សែយន្ត ហង្សយន្តក៏ធ្លាក់ចុះកណ្តាលសមុទ្រ ៗ នាយកេត្រាម្នាក់ បានស្រង់សុវណ្ណកុមារយកទៅចិញ្ចឹម ៗ នាយកេត្រាម្នាក់ទៀត បានរើសបានហង្សយន្ត ដែលអណ្តែតខ្វែងខ្វោងលើក្បាល រលកក្នុងមហាសាគរនោះ ៗ

បទុមកេសរ, បាត់ប្តីយូរពេក, ក៏ផ្តុកបុត្រនៅក្រោមដើម ក្រឹស្នា ហើយលីលាទៅរកប្តី ៗ ពេលនោះព្រះបាទព្រហ្មទត្ត ស្តេចយាងមកឃើញ ទារកអនាថានៅក្រោមដើមក្រឹស្នានោះ ក៏រើសយកទៅ ឧត្តរពារាណសី ហើយឲ្យនាមថា: ចៅ ក្រឹស្នាកុមារ ៗ

បទុមកេសរវិលមករកបុត្រវិញមិនឃើញ ក៏សោយសោក សង្រេង, ដើរត្រាច់ម្នាក់ឯងកណ្តាលព្រៃទៅទៀត ៗ យូរថ្ងៃ ក្រោយមកនាងបានចូលទៅសុំសំណាក់នៅផ្ទះយាយ មាលា

ហើយនាងតែងតែក្រងផ្កា ឲ្យលោកយាយយកទៅថ្វាយស្តេចព្រហ្មទត្ត រាល់ៗថ្ងៃ ។

ចៅស្រីស្នកុមារ ពេញកម្លោះ, មិនគាប់ចិត្តនឹងរាជកញ្ញាមកពីប្រទេសសមុទ្ទរាជទាំង ១០១, បែរជាស្រឡាញ់នាងបទុមកេសរទៅវិញ ។ រៀបពិធីអភិសេករួចទើបដឹងថា "ម្តាយនិងកូន" ។ ដឹងរឿងពិតហើយ, បទុមកេសរនឹង ស្រីស្ន-កុមារ បានរកមធ្យោបាយ ស្វែងរកស្វាមីនិងបិតា ។ គេបានតាក់តែងធ្វើបុណ្យវិវរណ៍មួយ ដែលតាំងសុទ្ធតែរូបភាពហាស្យ-យន្ត និងជីវប្រវត្តិរបស់ សុវណ្ណកុមារ ។ គេចាត់អ្នកបំរើឲ្យចាំលបស្តាប់ពាក្យចរចាររបស់ជនប្រុសស្រីទាំងឡាយ ដែលមកទស្សនាបុណ្យនោះ ។

សុវណ្ណកុមារ និងនាយកេត្រា បានមកមើលបុណ្យវិវរណ៍នោះដែរ ។ គឺក្នុងពេលនោះហើយ ដែលបទុមកេសរបានជួបស្វាមីកសត់ឡើងវិញ ។ ចៅស្រីស្នកុមារ នាំបិតាទៅមើលហាស្យយន្ត ដែលនាយកេត្រារើសបានយកមកថ្វាយ

ព្រះបាទព្រហ្មទត្ត ។ សុវណ្ណកុមារខំជួសជុលហង្សយន្តឲ្យមានលក្ខណៈគ្រប់គ្រាន់ដូចដើម រួចនាំមហេសីនិងព្រះរាជបុត្រគង់លើហង្សយន្ត នោះ ហោះឆ្ពោះទៅកាន់នគរក្រុងទេពបុរី បានជួបជុំព្រះរាជវង្សានុវង្សទាំងអស់ ។

## បុគ្គលិកលក្ខណៈសុវណ្ណកុមារ

កិច្ចការជាស្នាដៃរបស់សុវណ្ណកុមារ បានព្រមានយើងឲ្យដឹងថា: សុវណ្ណកុមារមានបុគ្គលិកលក្ខណៈពុំប្រពៃឡើយ ។ ព្រះអង្គត្រូវការស្វែងរកស្រីរូបល្អ តែព្រះអង្គកុហកមាតា-បិតាថា: សុំលាទៅរៀនសិល្ប ។ ព្រះអង្គទៅលួចរួមរ័ក្សនឹងកូនក្រមុំគេ, ហើយទៅលួចគ្រឿងចន្ទុះរបស់-នាយសំពៅទៀត ។

ព្រះអង្គជារាជកុមារអកតញ្ញូ ។ ព្រះអង្គបាននាំមហេសីនិងបុត្ររត់ចេញពីនគរពារាណសី ដោយពុំបានទៅថ្លែងអំណរគុណចំពោះព្រះបាទព្រហ្មទត្ត និងលោកយាយមាលា ដែលជាអ្នកមានគុណដ៏ធ្ងន់ បានជួយសង្គ្រោះមហេសី និង

បុត្ររបស់ព្រះអង្គក្នុងគ្រាក្រ, គឺក្នុងពេលព្រាត់ប្រាស ។ ក្រៅ-
អំពីបទអកុសលរបស់សុវណ្ណកុមារ, អ្នកសង្កេតការណ៍ទាំង
ឡាយ អាចគិតដៀលបានថា: សុវណ្ណកុមារជាមនុស្សធ្វេស
ប្រហែសក្នុងកិច្ចការនីមួយៗ ។ លើកដំបូង, ព្រោះតែ
ការធ្វេសប្រហែសក្នុងពេលស្នេហា, បានជាព្រះចៅបញ្ចបុរី
ចាប់ខ្លួនបាន ។ លើកក្រោយមកទៀត, ព្រោះតែការធ្វេស
ប្រហែស, បានជាអណ្តាតភ្លើងឆាបឆេះជាប់ខ្សែយន្ត, បណ្តាល
ឲ្យជួបគ្រោះថ្នាក់នៅលើមហាសមុទ្រ ។

ដូចនេះ, តួឯករបស់រឿងហង្សយន្ត គ្មានខ្លឹមសារ,
គ្មានសមត្ថភាពល្មមធ្វើជាម្ចាស់ហង្សយន្ត ដែលជាបក្សី វិទ្យា-
សាស្ត្រសោះឡើយ ។ ប៉ុន្តែ, អ្នកនិពន្ធ បានបញ្ជាក់ប្រាប់
យើងដែរ, លោកថា: ហង្សយន្តនេះជា ស្នាដៃរបស់កម្មករ
គឺជាងទង់ទាំងពីររូប នៅក្នុងនគរក្រុងទេពបុរី ។

+

+ +

## បុគ្គលិកលក្ខណៈបទុមកេសរ

ផ្ទុយពីរូបសម្បត្តិ ដែលគួរឲ្យជញ្ជាបមាត់សរសើរ មិនចេះអស់មិនចេះហើយ, ព្រះនាងបទុមកេសរ មានលក្ខណសម្បត្តិមិនប្រពៃទេ ។ ព្រះនាងបានស្ម័គ្រចិត្តលួចរួមរ័ក្ស នឹងសុវណ្ណកុមារជាសង្សារ ដែលនាំឲ្យត្រកូលរបស់ព្រះនាងមានកេរ្តិ៍ឈ្មោះមិនល្អ ។ នេះជាគំរូអាក្រក់មួយ គប្បីនារីទាំងឡាយ កុំនឹកនាដល់ឲ្យសោះ ។

បទុមកេសរបានផ្ដកបុត្រពេលក្រោមដើមឈើ រួចត្រាច់ដើរទៅតែប្ដី ។ នេះជាកញ្ចក់មួយ បញ្ចាំងឲ្យយើងឃើញទុរាចារ ខ្វះព្រហ្មវិហារធម៌ ចំពោះបុត្រធីតា ។ អំពើនេះផ្ទុយស្រឡះ អំពីគំនិតមាតាបិតាជាច្រើនរូប ហើយដែលសុទ្ធតែជាស្ត្រីសាមញ្ញផង ។ បទុមកេសរជានារីអកតញ្ញូ ។ ព្រះនាងឡើងគង់លើហង្សយន្ត, ទៅតាមប្ដី, មិនខ្វល់ប្រាប់យាយ មាលា មួយម៉ាត់ណាសោះ កុំថាឡើយដល់ទៅសូមថ្លែងអំណរគុណ ។ កិរិយាបែបស្មោកគ្រោកនេះ គួរយុវជនយុវនារីចាត់ចោលឲ្យផុតស្រឡះ ។

យើងសង្កេតឃើញថា: បទុមកេសរមានរូបល្អ តែចរិយា អាក្រក់ក្រៃលែង ៗ ស្រីបែបនេះ មិនជាទីសរសើររបស់អ្នកប្រាជ្ញបណ្ឌិតឡើយ ៗ

\+ + +

## បុគ្គលិកលក្ខណៈយាយមាលា

លោកយាយមាលា ជាស្ត្រីមេម៉ាយ មានខ្ទមជកជាទីជម្រក, នៅក្នុងឧត្តរពារាណសី ៗ មុខរបររបស់គាត់ គឺធ្វើកម្រងផ្កាថ្វាយស្តេច ៗ ដូច្នេះ, យាយមាលាជាសិប្ប-ការី មួយរូបដែរ ៗ គាត់រស់នៅដោយសារសិល្បៈ ៗ ថ្ងៃណាក្រងផ្កាបានល្អ, ព្រះបាទព្រហ្មទត្តសព្វព្រះរាជហឫទ័យ, ក៏ប្រទានរង្វាន់ច្រើនមកឲ្យ ៗ ថ្ងៃណាក្រងផ្កាមិនបានល្អ គាត់ក៏ត្រូវទទួលរង្វាន់តិចតួច ឬ ក៏អត់សោះតាមនោះដែរ ៗ ឃើញថាជីវិតសិល្បករនិងសិល្បការីក្នុងជំនាន់សក្តិភូមិ ក៏ដូចជាសម័យមូលធននិយម, សម័យប្រជាធិបតេយ្យអភិជន, គ្មានការធានាអះអាងទេ ៗ

នៅក្នុងរឿង ហង្សយន្ត, ក្រៅអំពីក្រងផ្កាថ្វាយស្ដេច, លោកយាយ មាលា បានធ្វើការកុសលមួយដ៏វិសេសគួរសរសើរ គឺគាត់បានចិញ្ចឹមថែរក្សាព្រះនាងបទុមកេសរ ដែលបានព្រាត់ប្រាស់ស្វាមីនិងបុត្រសម្លាញ់ អស់រយៈពេលជិតម្ភៃឆ្នាំ ៗ ថ្វីបើគាត់ក្រយ៉ាងហ្នឹងក៏ដោយ, លោកយាយមិនធុញទ្រាន់, មិនខ្វចបង់ខាតបាយទឹកក្នុងការជួយរំដោះទុក្ខអ្នកមានគ្រោះថ្នាក់ឡើយ ។ នេះហើយ! ទឹកចិត្តអ្នកក្រ! ៗ ពពួកមូលធនិក ច្រើនតែដើរឃោសនាដោយមាត់ទទេ, ឬដោយសរសេរបោះពុម្ពផ្សាយជាសៀវភៅថា: មានតែអ្នកមានទេ ដែលជាអ្នកជួយសង្គ្រោះអ្នកក្រ ៗ នេះជាការឃោសនាមួយប្រាសចាកការពិត ៗ គឺគ្រាន់ជាគំនិតប្រមូលផ្ដុំអ្នកក្រឲ្យមកនៅបំរើក្រោមបាទជើងរបស់ពួកអភិជនតែប៉ុណ្ណោះ ៗ ប្រវត្តិសង្គមមនុស្សបានបំភ្លឺយើងឲ្យមើលឃើញការរំលោភជិះជាន់ របស់អ្នកមានទៅលើខ្នងអ្នកក្រជាហូរហែច្រើនសតវត្សណាស់មកហើយ ៗ មានតែអ្នកក្រទេ ដែលចេះជួយឈឺឆ្អាល ដល់អ្នកក្រផងគ្នា ៗ

ប៉ុន្តែរឿងនេះពុំមានអ្នកណាមួយ សរសេរគត់ត្រាទុកក្នុងប្រវត្តិសាស្ត្រឡើយព្រោះសម័យតាំងឆ្ងាយដែលគន្លងផុតទៅ សុទ្ធសឹងជាសម័យរបស់អភិជនទាំងអស់ ។ អ្នកនិពន្ធណាដែលមានគំនិត "ប្រជាជននិយម" ក៏លួចកត់ត្រារឿងនេះបានបន្តិចបន្តួចដោយប្រយោល, ដោយដាក់បញ្ចូលទៅក្នុងរឿងឯណាមួយ, ឥតហ៊ានបញ្ចេញមតិច្បាស់លាស់ទេ ។ ...

លោកយាយ មាលា បានចិញ្ចឹមនាងបទុមកេសរដោយសេចក្តីព្រួយលំបាកបំផុត ៗ គាត់ព្រួយ! ព្រោះគាត់ខ្លាចព្រះបាទព្រហ្មទត្តទ្រង់ជ្រាបរឿងនេះ, ព្រះអង្គនឹងយាងមកដណ្តើមយកនាងទៅធ្វើជាស្រីស្នំ ៗ បើករណីយនេះផុះកើតឡើង, ព្រះនាងបទុមកេសរ នឹងមានសេចក្តីសៅហ្មងយ៉ាងអស្ចារ្យ ។ ហេតុនេះហើយបានជាលោកយាយទូលព្រះពជាថា: "ចៅខ្ញុំជាមនុស្សពិការ, ក្រៃផងក្រងង់, អាក្រក់មើលខ្លាំងណាស់" ។

តើលោកយាយកំព្រាបានទទួលផលអ្វីខ្លះ ក្នុងពេលដែលគាត់ទទួលបីបាច់រក្សាកូនស្រីរបស់ស្តេចនគរបញ្ចាបុរីនេះ? –

គ្មានទេ! ... លោកយាយធ្វើគុណបានទទួលតែកេរ្តិ៍ឈ្មោះអាក្រក់ទៅវិញ ៗ ព្រះបាទព្រហ្មទត្ត កាលបើទ្រង់បានជ្រាបរឿងពិតហើយ, ព្រះអង្គបានហៅលោកយាយមាលាទៅសុំបន្ទោសឲ្យឥតគណនា ៗ ចំណែកនាងបទុមកេសរវិញ, ពេលដែលបានជួបស្វាមី ក៏ឡើងជិះហង្សយន្តទៅតាមស្វាមី មិនវិលមកដំរាបលាលោកយាយមាលាមួយម៉ាត់ផង ៗ ត្រង់នេះហើយ, សឲ្យឃើញថា: អ្នកក្រជួយសង្គ្រោះអ្នកមាន ឥតបានន័យជាអ្វីឡើយ ព្រោះអ្នកមានមិនព្រមទទួលស្គាល់កិច្ចការល្អ ៗ របស់អ្នកក្រមួយណាសោះ ៗ

+

+ +

## បុត្តលិកាលក្ខណៈព្រះបាទអាទិត្យវង្ស

ព្រះបាទអាទិត្យវង្សជាក្សត្រមួយព្រះអង្គ ដែលខំប្រឹងខ្វាយខ្វល់រកបុត្រ ដើម្បីស្នងរាជសម្បត្តិជំនួសព្រះអង្គ, បើសិនជាព្រះអង្គអស់ព្រះជន្មទៅ ៗ ព្រះអង្គទៅពឹងពាក់អារក្ស-អ្នកតា

ក្ពំដុំថ្ទុ ដែលជារឿងកុតនិយម ឲ្យជួយគេបុត្រធីតាឲ្យព្រះអង្គ ។ ត្រង់នេះបាត់ជាអំពើមិនសមហេតុផល ព្រោះការសុគោយតាំងនោះពុំអាចសាងបុត្រធីតាប្តូរសេចក្តីសុខឲ្យមនុស្សបានឡើយ ។ គ្មានលក្ខណៈវិទ្យាសាស្ត្របន្តិចសោះក្នុងរឿងហ្នឹង ។

ពេលដែលមានកផបុត្រពេញកម្លោះហើយ, ដើម្បីគេមហេសីឲ្យបុត្រ, ព្រះបាទអាទិត្យវង្សបានប្រើអំណាចយ៉ាងទូលាយ គឺបង្គាប់ឲ្យស្ត្រីទាំងឡាយដែលជាខតរបំណុះ នាំយកបុត្ររបស់ខ្លួនមកថ្វាយព្រះពជបុត្រដល់ទីកន្លែង (បើមិន-ពេញព្រះទ័យ គេឲ្យវិលត្រឡប់ទៅវិញ) ។ នេះគឺជាអំណាចផ្តាច់ការអាណានិគមដែរ ។ ហើយរឿងនេះបង្ហាញឲ្យយើងឃើញច្បាស់ក្រៃឡែងថា: ជំនាន់ដើម, ស្ត្រីគ្រាន់តែជាតួល្បែងរបស់បុរសតែប៉ុណ្ណោះ ។

## បុគ្គលិកលក្ខណៈព្រះបាទព្រហ្មទត្ត

ព្រះបាទព្រហ្មទត្ត មានបុគ្គលិកលក្ខណៈល្អណាស់ ។ យើងមិនអាចរិះគន់ព្រះអង្គបានទេ, ប៉ុន្តែប្រហែលជាព្រះអង្គ

ពេញព្រះទ័យនឹងការប្រព្រឹត្តិល្បែង តាមតណ្ហាខ្លាំងណាស់ ដែរ បានជាយាយមាលាមិនហ៊ានទូលព្រះអង្គ ថាគាត់មានចៅស្រីមួយស្អាត (បទុមកេសរ) ។ ឯលក្ខណៈសម្បត្តិដ៏ល្អរបស់ព្រះអង្គគឺ:

ក-) បេះអាណិតអាសូរដល់ចារកំសត់

ខ-) ជួយស្រោចស្រង់ជីវិតកុមារកំសត់

គ-) បីបាច់ចិញ្ចឹមកុមារកំសត់

ឃ-) គិតដល់អនាគតកុមារកំសត់ ដែលមិនមែនកូនរបស់ព្រះអង្គ ។

បុគ្គលិកលក្ខណៈនាយគេត្រា

នាយគេត្រាទាំងពីររូបក្នុងរឿងហង្សយន្តនេះ មានបុគ្គលិកលក្ខណៈប្រសើរណាស់ ។ នាយគេត្រាទី១ បានយកសុវណ្ណកុមារចិញ្ចឹម ជាហេតុនាំឲ្យសាធារណជនសរសើរថាគាត់ជាអ្នកមានមនុស្សធម៌បរិបូណ៌ក្នុងខ្លួន ។ នាយគេត្រាទី២ រើសបានហង្សយន្តយកទៅថ្វាយស្តេច ។ នេះជាលក្ខណៈ

ប្រសើរក្រៃពេក ។ ព្រោះថាបើយើងរើសបានវត្ថុទីមួយៗ យើងត្រូវតែយកទៅប្តឹងដល់អ្នកខាងការរដ្ឋបាល ដើម្បីជៀសឲ្យផុតបទទោសថា «លួចគេ» ហើយនឹងដើម្បីឲ្យរាជការផ្សាយដំណឹងនេះទៅដល់ម្ចាស់របស់ផង ។ ច្បាប់បច្ចុប្បន្ននេះក៏មានន័យបែបនេះដែរ ។

### បុគ្គលិកលក្ខណៈជាងទង

ជាងទងទាំងពីររូបបានប្រកួតប្រណាំងគ្នា ក្នុងការធ្វើហង្សយឲ្យបានសម្រេច ។ អំពើនេះល្អប្រសើរណាស់ ព្រោះនាំឲ្យកិច្ចការបានល្អ នឹងបានឆាប់រហ័សផង ។ គេប្រកួតប្រណាំងគ្នាដោយវែកកាយ មិនមែនគេចាស់តែងឈ្លោះប្រកែកគ្នាទេ ។ កាលបើម្នាក់ៗរកឃើញល្បិចល្អៗហើយ, គេបែរជាយកមកផ្គុំសិល្បៈគ្នា ដើម្បីធ្វើការរួមគ្នាឲ្យបានផលប្រពៃ ។ អំពើនេះល្អណាស់ ។

លក្ខណៈរបស់ជាងទងទាំងឡាយគួរជាទីស្ងើចសរសើរនៃសាធារណជនទូទៅ ព្រោះអ្នកទាំងពីរគ្មានការស៊ីមិនដាក់

គ្នា ។ កម្មករ ពីរូបនេះមិនគិតឃើញបង្អៀតបង្អល់តែខ្លួនម្នាក់ៗ ប៉ុណ្ណោះទេ គេធ្វើការរួម, បានផលចែកគ្នា ៗ កម្មករ នេះជា គំរូ ដល់យើងកល់គ្នាឲ្យស្គាល់ផលប្រយោជន៍រួម, គេធ្វើការ ស្មើគ្នា មិនមានអ្នកណាម្នាក់ខ្ជិល ប្រើល្បិចកលនៅស្ងៀម ហើយបានផលច្រើននោះទេ ។ សូម្បីតែដំរេះវិជ្ជាគាត់យ៉ាង ជើតប៉ុណ្ណឹងហើយ គាត់ក៏មិនទាន់បានទទួលផលល្អប៉ុន្មានដែរ ព្រោះតែរបបសក្តិភូមិ សង្កត់ ៗ គាត់ទាំងពីរនាក់ឥតបាន បំរើមហាជនទេ ត្រូវ សក្តិភូមិ យកទៅប្រើផ្តាច់មុខ ។ ប៉ុន្តែយើងដឹងហើយចំណេះវិជ្ជា ដែលកើតមាននៅក្នុងសម័យ នោះមិនបានគេលើកដំកើងឲ្យបានផលដល់មហាជនទេ ព្រោះ តែការខ្វះសិទ្ធិសេរីភាពម្យ៉ាង ៗ ជាងទងទាំងពីរប្រសើរអស្ចារ្យ ទៅទៀត ព្រោះគាត់ចេះធ្វើគ្រឿងយន្តឲ្យកើតឡើងនៅ បំ

សម័យដែលមនុស្សនៅមានជំនឿខុសពីការហោះហើរដើរលើ អាកាស ។ នេះជាការមួយ ដែលប្រសើរលើសលែងអ្វីទាំង អស់ ។ គាត់ចេះស្រាវជ្រាវរកវត្ថុដំពិសេសដើម្បីបញ្ជាក់

ទៅលើកម្លាំងមនុស្សដែលអាចធ្វើអ្វីបានគ្រប់យ៉ាង , ឲ្យឡើង

មួយគំនិតខ្ពស់បំផុត ។

# សង្ខេបរឿង «កុលាបប៉ៃលិន»

— ចៅចិត្រ ជាកូនប្រុសរបស់ តាចឹម ។ គ្រួសារកសិករនេះមានតែពីរនាក់ ឪពុក កូន ហើយមានទីលំនៅ ។ ស្រុកបវែល ( ខេត្តបាត់ដំបង ) ។

ចៅចិត្របានរៀនសិក្សាវិជ្ជាផ្សេង ៗ នៅឯសាលារហូតដល់បានប្រឡងនឹងគេដែរ, តែការសិក្សារបស់អ្នកត្រូវបញ្ចប់ត្រឹមពេលដែលតាចឹមជាឪពុកឈឺធ្ងន់ ៗ លោកគ្រូពេទ្យ ស្អាតបានមកជួយព្យាបាលជម្ងឺតាចឹមដែរ ប៉ុន្តែជម្ងឺនោះកាន់តែជាធ្ងន់ឡើង ៗ រៀងរាល់ថ្ងៃ ៗ ដល់ទីបំផុត, តាចឹមក៏ធ្វើមរណកាល ចោលចៅចិត្រឲ្យរស់នៅត្រមោចម្នាក់ឯង ។

ដោយមាន លោកគ្រូពេទ្យស្អាត ជួយជ្រោមជ្រែងផង, ចៅចិត្រក៏ត្រូវបានទៅធ្វើជា កម្មករ ជីកត្បូងនៅផ្ទះ លោកហ្មង់រតនសម្បត្តិ ឯស្រុកប៉ៃលិន ។ នៅទីនោះ នាង ធារី ជាកូនក្រមុំរបស់ហ្មង់រតនសម្បត្តិ បាននិយាយ

បង្អាប់បន្ទុះចៅចិត្រយ៉ាងខ្លាំង ចៅចិត្រក៏បានធ្វើយដោះស្រាយវិញដោយពាក្យសំដីគ្រោះគ្រាយ ឥតគោតញញើតឡើយ ។

ពេលមួយនោះ, ក្រោយដែលបាននិយាយគមាត់គ្នាអស់មួយសន្ទុះ, ចៅចិត្របបួលនារីទៅអង្គុយលេងក្នុងសួនច្បារ ។ នារីព្រមទទួលឥតប្រកែក ។ ចៅចិត្រដំណាលរឿងកំសត់របស់ខ្លួន ជូនទៅហ្វាយក្រមុំស្តាប់ ។ លុះវិលទៅលំនៅវិញ ម្នាក់ៗ មានការមមៃរៀងៗខ្លួន ៗ ។ ព្រលឹមឡើងចៅចិត្របវព្យានជូនលោកហ្វាំងតេនសម្បត្តិ នឹងនាងនារីទៅទួលលោក ចានឡាឌុនៅស្រុកសង្កែ ។ ពេលដែលហ្វាំងតេនសម្បត្តិទៅដល់បន្ទាយបាទ្បាត់ស្រុក, នាងនារីប្រើចៅចិត្រឲ្យឃ្លាកន្រ្ទកដើរតាមក្រោយនាងទៅផ្សារ ។ ក្នុងពេលដើរទិញអីវ៉ាន់នាងបានធ្វើឲ្យចៅចិត្រអៀនខ្មាសអ្នកនៅជុំវិញខ្លួនយ៉ាងខ្លាំង ។

ពេលវិលត្រឡប់មកស្រុកប៉ៃលិនវិញ , រថយន្តខូចកណ្ដាលផ្លូវ ហើយក្នុងបរិវេណព្រៃដាច់ស្រយាលពីភូមិអ្នកស្រុកផង ។ ក្នុងយប់នោះ ចោរព្រៃបានបាញ់ត្រូវចៅចិត្រមួយគ្រាប់ ក្នុងពេលដែលនាងនារីបានធ្វើឲ្យចៅចិត្រយល់ដល់ដួងចិត្តរបស់នាង ។

តាស៊ុន ដែលជាអ្នកបរឡាន (ពិតប្រាកដ) របស់ហ្វូងគេនសម្បត្តិបានខ្ចីឡានចិកម៉ុងថោងយ៉ុង បរទៅតាមចៅហ្វាយ ។ លុះឃើញចោរក័យកើតឡើងដូច្នោះ តាស៊ុនស្រែកបន្អើលចោររត់អស់ទៅ ហើយក៏បាននាំយកចៅចិត្រមកព្យាបាលជម្ងឺ ក្នុងបន្ទប់មួយយ៉ាងស្អាតនាគេហដ្ឋានហ្វូងគេនសម្បត្តិ ។ ដោយបាននាងនារីថែទាំដោយផ្ទាល់ដៃ ចៅចិត្រកម្លោះ ក៏បានសះស្បើយយ៉ាងឆាប់រហ័ស ។ ឥឡូវនេះចៅចិត្រឈប់ធ្វើជាកម្មកររ៉ែត្បូងសាធហើយ គេបានសេចក្ដីអនុគ្រោះពីនាយចៅហ្វាយឲ្យឡើងបានងារជាអ្នកត្រួតត្រាលើកម្មករទាំងអស់វិញ ។

ដោយបានដំណែងថ្មី និងដោយបានយុវនារី ជាគូសង្សារផង ចៅចិត្រភ្លេចទេសភាពស្រុកសង្កែតែម្តង ។ អាស្រ័យដោយបញ្ញានិងគំនិតវាងវៃរបស់ចៅចិត្រ ការជីកត្បូងរបស់ហ្វុងរតនសម្បត្តិ មានការវិវត្តន៍ខ្ពស់ឡើងជាច្រើនកំរិត ។

ថ្ងៃមួយនោះ លោកបាឡាត់ស្រុកសង្កែ បាននាំចៅកែដាន់ មកទិញត្បូងរបស់ហ្វុងរតនសម្បត្តិ ។ ពេលដែលចៅចិត្រ នាំចៅកែដាន់ទៅមើលអណ្តូងរ៉ែ, លោកបាឡាត់បានចាប់កំហែងយុវនារី ដើម្បីបំពេញកាមតណ្ហារបស់ខ្លួន ក៏ប៉ុន្តែអំពើដ៏លាមកនេះ ត្រូវបរាជ័យទៅវិញ ដោយចៅចិត្រនឹងហ្វុងរតនសម្បត្តិ អញ្ជើញមកទាន់, ឃើញជាក់ស្តែង ។

ពោរពេញទៅដោយកំហឹង ; ក្នុងវេលារាត្រីនោះឯង លោកបាឡាត់នឹងចៅកែដាន់ នាំគ្នាមកប្លន់ផ្ទះហ្វុងរតនសម្បត្តិ ។ គោលបំណងរបស់លោកបាឡាត់ គឺដណ្តើម

នាងយុទនារី , ឯគោលបំណងរបស់ថៅកែផាន់ គឺយកត្បូងទឹមពេជ្រ ដែលខ្លួនបានមើលឃើញពីថ្ងៃ ។ កម្មករជីកត្បូងបានព្រួតដៃសាមគ្គីគ្នាប្រយុទ្ធ នឹងក្រុមចោរយ៉ាងក្លាហានអង់អាច , ដល់ទីបំផុត លោកបាឡាត់នឹងថៅកែផាន់ ត្រូវទៅចំគ្រាប់សម្លាប់ស្លាប់ទៅ ។

ដោយបានសំគាល់ឃើញថា: ចៅចិត្រជាបុរសកំសត់មែន ប៉ុន្តែមានលក្ខណៈប្រពៃ ប្រកបដោយធម៌ទាំងបីគឺ: សច្ចៈ , ខន្តី , កតញ្ញូ , ហ្វូងរតនសម្បត្តិ ក៏បានលើកកូនក្រមុំរបស់លោកឲ្យទៅចៅចិត្រកំព្រា ដោយសេចក្តីរីករាយបំផុត ។

★

## បុគ្គលិកលក្ខណៈរបស់តាចឹម

រឿង « កុឡាបប៉ៃលិន » ចាប់ផ្តើមឡើងនៅពេលដែលតាចឹមកំពុងត្រូវពេតជកមកញ៉ាំញី ។ សកម្មភាពទាំងឡាយរបស់តួអង្គគន់ រឿងកុឡាបប៉ៃលិន សុទ្ធតែបាន

ប្រព្រឹត្តក្រោយពេលដែលតាចឹមផុតដង្ហើមទៅហើយ ។ ដូច្នេះ, សិក្សារឿងក្ខូឡាបប៉ៃលិន, យើងមិនគាបគេឃើញគុណសម្បត្តិឬគុណវិបត្តិរបស់តាចឹមឡើយ ។ បណ្តាំរបស់គាត់ទៅកាន់ចៅចិត្រជាកូនគ្រាន់តែបំភ្លឺយើងឲ្យឃើញថា: គាត់ជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន, មានសន្តានចិត្តល្អ, មានប្រាជ្ញា ឲ្យកូនបានជាមនុស្សប្រកបដោយលក្ខណធម៌ទៅអនាគត ។ គាត់មិនព្រមទទួលពានឱសថ ព្រោះគាត់ដឹងថា: គាត់ត្រូវតែស្លាប់ក្នុងពេលឆាប់ ៗ នោះ ; មិនបាច់យកឱសថអ្វីទេ នាំឲ្យបង់ខាតប្រាក់កាស, នាំឲ្យលំបាកកូនទៅអនាគត ព្រោះកូនគាត់ទំងត្រូវរស់នៅតែលតោលក្នុងភាពក្រីក្រហើយ ។ នេះជាគំនិតមួយដ៏ធម្មតារបស់មាតា-បិតា ដែលដឹងខ្លួនថាស្លាប់មុនពេលស្លាប់ ។ ចំពោះពាក្យសំដីដ៏ផ្អូញផ្អែរបស់តាចឹម ទៅកាន់លោកគ្រូពេទ្យស្អាត ក៏សុទ្ធសឹងជាទ្រឹស្តីនៃទឹកចិត្តរបស់គាត់ដែលប្រកបដោយធម៌មេត្តាករុណាចំពោះបុត្រតែប៉ុណ្ណោះ ។

## បុគ្គលិកលក្ខណៈចៅចិត្រ

ចៅចិត្រជាបុត្រមួយរូប ដែលប្រកបដោយកតញ្ញូធម៌ ព្រមទាំងប្រតិបត្តិតាមដំបូន្មានរបស់ឪពុក ។ កាលដែលតាចឹមជាឪពុកឈឺធ្ងន់ , គេបានទៅថែរក្សាយ៉ាងម៉ឺងម៉ាត់ឥតធ្វេសប្រហែស ។ លុះឪពុកអនិច្ចកម្មទៅ ចៅចិត្រត្រូវនៅកំព្រាតែម្នាក់ឯង , ឥតបងប្អូនព្រមទាំងគ្មានទ្រព្យសម្បត្តិល្មមគ្រប់គ្រាន់ នឹងប្រកបការចិញ្ចឹមជីវិតឲ្យថ្លៃថ្នូរបាន . មានតែពាក្យទូន្មាន នឹងបណ្តាំចុងក្រោយបំផុតរបស់ឪពុក គឺអត្តា ហិ អត្តនោ នាថោ ពាក្យបណ្តាំប៉ុណ្ណោះនេះ បានចារឹកជាប់ក្នុងខួរក្បាលរបស់គេ ។ ដោយមានគ្រូពេទ្យស្អាតជួយជ្រោមជ្រែងផង , គេក៏បានសម្រេចចិត្តស្ម័គ្រធ្វើកម្មករជីកត្បូង នៅផ្ទះហ្វាំងរតនសម្បត្តិឯស្រុកបៃលិន ។ គឺនៅទីនោះហើយ , លក្ខណៈសម្បត្តិចៅចិត្របានលេចឡើងឲ្យយើងឃើញយ៉ាងច្បាស់លាស់ ។ គេជាយុវជនយ៉ាងអង់អាច និយាយត្រង់ទៅត្រង់មក មិន

ភាយស្របយកតែរូបខ្លួន ដូចជាយើងបានឃើញគេតសំដី យ៉ាងប៉ុនប្រសប់ចំពោះយុវនារី នៅពេលដែលគេទើបនឹងទៅដល់ ៗ ថ្វីបើគេជាអតីតសិស្សសាលា ដែលញាប់តែកាន់ប៉ាក្កាសរសេរ ប៉ុន្តែចំពោះការហត្ថកម្ម គេក៏អាចធ្វើបាន ដូចជាកម្មករឯទៀតដែរ ៗ គេបានប្រឹងប្រែងបំពេញមុខការរបស់គេដោយឥតសំចៃកម្លាំង ដោយគេបានយល់ច្បាស់នូវបណ្តាំឪពុកដ៏ជាទីគោរពរបស់គេ គឺ „ខ្លួនជាទីពឹងរបស់ខ្លួន” គឺគេត្រូវទីពឹងលើកម្លាំងបញ្ញា និងកម្លាំងកាយរបស់គេ ដើម្បីនឹងដឹកនាំខ្លួនរបស់គេទៅរកសុភមង្គល ៗ ដូច្នេះ, យើងអាចចាត់ទុកថា ចៅចិត្តជាយុវជនមួយរូបដែលស្គាល់តម្លៃរបស់ការហត្ថកម្ម ៗ ម្យ៉ាងទៀត, ចៅចិត្រជាយុវជនមួយរូប ដែលមានមនុស្សជមិត្តខ្លួន, គេលួចស្រឡាញ់ យុវនារី ជាចៅហ្វាយក្រុមរបស់គេ ប៉ុន្តែគេមិនបានប្រើបទរំលោភទៅលើនារី ដោយអំពើជាកតាមដូចជាលោកបា ឡាត់ឡើយ ៗ នៅពេលដែលរថយន្ត

ត្រូវៈចារប្អូន គេបានចេញតស៊ូប្រយុទ្ធយ៉ាងអង់អាចជាមួយ
ពួកចោរដោយឥតស្ដាយជីវិត ដើម្បីការពារអ្នករួមដំណើរ
ជាមួយគេ ពិសេសគឺហ្វូងគេនសម្បត្តិទាំងនាងយុវនារី ។
អំពើនេះស្ដែងឲ្យឃើញថា: ជាយុវជនក្លាហានអង់អាចប្រ
យុទ្ធចំពោះសត្រូវ ហើយជាយុវជនដែលមានសេចក្ដីស្មោះ
ទៀតផង ។ គឺដោយសារលក្ខណសម្បត្តិ គួរឲ្យសរសើរ
ខាងលើនេះហើយ ដែលហ្វូងគេនសម្បត្តិក៏មានសេចក្ដី
ពេញចិត្តចំពោះចៅចិត្រហួសដល់រៀបការធីតារបស់លោកឲ្យ
ជាភរិយា, ចុះបើចៅចិត្រជាមនុស្សកំព្រាតោកយ៉ាកក៏
ដោយ ។ បើពោលដោយរួមមក ក្នុងរឿងកុលាប
ប៉ៃលិន, ចៅចិត្រជាយុវជនមួយរូប ដែលមាន
លក្ខណៈ ពិសេសជាងគេ គឺជាបុត្រកតញ្ញូ, ជាយុវជនស្គាល់
តម្លៃការហត្ថកម្ម, ជាមនុស្សមានសេចក្ដីអត់ធ្មត់ ចំពោះការ
ចិញ្ចឹមជីវិត, ជាមនុស្សមានស្មាមីភក្ដិស្មោះត្រង់ ព្រមទាំង

ក្លាហានអង់អាចក្នុងការប្រយុទ្ធនឹងសត្រូវ ៗ មនុស្សរបៀបនេះមិនចេះបោកពាបឡើយ; ទៅដល់ទីណា តែងតែមានគេសរសើរពេចអាននៅទីនោះ ៗ

## បុគ្គលិកលក្ខណៈហ៊ានរកធនសម្បត្តិ

តាំងពីអតីតកាលមក, ប្រវត្តិសាស្ត្រនៃសង្គមមនុស្សបានបង្ហាញឲ្យយើងឃើញថា: គ្រប់តែនាយទុនសុទ្ធសឹងប្រកបដោយអត្តទត្តភាពទាំងអស់ ៗ នាយទុនគឺជាមនុស្សធ្លាប់ដេកត្រាំលើគំនរឆ្អឹង ទឹងថុកឈាមរបស់ពួកកម្មករអ្នកក្រីក្រទាំងឡាយ ៗ នាយទុនធ្លាប់តែយកទឹមដែកបំពាក់កជនតូចតាចដោយអាងទៅលើភោគសម្បត្តិរបស់ខ្លួន ៗ ប៉ុន្តែក្នុងរឿង «កុលាបប៉ៃលិន» លោក ញ៉ុក-ថែម បាននាំយើងឲ្យស្គាល់នាយទុនមួយរូបមានអាកប្បកិរិយាផ្ទុយអំពីនាយទុនទាំងឡាយដែលយើងធ្លាប់បានឃើញដោយផ្ទាល់ភ្នែក និងធ្លាប់បានឮពួកកម្មករតំណាលប្រាប់គ្នគ្នាជាហូរហែ ៗ នាយទុនដែលលោក

ញ៉ុក-ថែម បង្ហាញឃើងនោះ គឺហ្លួងរតនសម្បត្តិ, ជា
កែពេជ្រ នៅក្នុងស្រុកប៉ៃលិន ។ ហ្លួងរតនសម្បត្តិជា
អ្នកចិត្តសាស្ត្រមួយរូប ពោរពេញ ទៅដោយការពិសោធន៍
មានគំនិតប្លែកពីនាយទុនដទៃ ដែលចូលចិត្ត តែដើរដំណើរ
ប្រតិកិរិយាប្រវញ្ចន៍ជនក្រីក្រ ដើម្បីសាងសុភមង្គលឲ្យសង្គម
ជំនួបរបស់ខ្លួន ។ ការប្រព្រឹត្តិរបស់ហ្លួងរតនសម្បត្តិក្នុងរឿង
កុលាបប៉ៃលិន បាននាំឲ្យយើងដឹងថា: គាត់ជាបុគ្គលមួយ
រូបមានសេចក្តីប្រាថ្នាតិច, មាស ពេជ្រ . កែវ . កង . គ្រែពូក
ខ្នល់ខ្នើយ មិនមែនជាទីជម្រកដ៏សុខសាន្តទេ កាលបើរបស់
នោះ បានមកដោយអធម៌, នេះហើយជាគោលគំនិតរបស់
គាត់ ។ នៅក្រោមម្លប់ដ៏ត្រជាក់របស់គាត់ កម្មករទាំង.
ឡាយ សឹងបានទទួលនូវមនុញ្ញផលនឹងមេត្តាធម៌ដែលគាត់
សាបព្រោះដោយសុទ្ធចិត្តជានិច្ច ។ គាត់យល់ឃើញថា
ទ្រព្យធនទាំងឡាយ ដែលនឹងបានគង់វង់ ហើយនឹងមានការ
វិវត្តន៍ពីតិចទៅច្រើន លុះត្រាតែអ្នករក្សាជាមនុស្សមានគំនិត

ល្អ, ផ្ទុយទៅវិញទ្រព្យធនបរិបូណ៌យ៉ាងណាក៏ដោយតែង តែរលាយជាពុំខាន បើអ្នករក្សាទ្រព្យនោះ ជាមនុស្សឥត មារយាទ ។ ដោយគាត់យល់ឃើញដូច្នេះហើយ បានជាគាត់ ស្ម័គ្រចិត្តរៀបការកូនស្រី របស់គាត់ឲ្យទៅចៅចិត្រកំព្រា ដោយរើកពយ ។ គាត់រើសកូនប្រសារបៀបនេះល្អណាស់ ។ ល្អទី ១ គឺគាត់មិនបំបិទសិទ្ធិនិងសេរីភាពរបស់កូនស្រីគាត់ ដែលគាត់បានដឹងថា: កូនគាត់ពេញចិត្តនឹងកម្មកររបស់ឯង ។ បើផ្ដាច់គោលបំណងរបស់កូនឃើញថា: កូននឹងពុំបានសប្បាយ ចិត្ត, សុភមង្គលទៅអនាគតក៏គ្មានដែរ ។ ល្អទី២គឺគាត់ បានធ្វើគំរូដ៏ល្អទុកឲ្យនាយទុនដទៃ ដែលធ្លាប់តែប្រកាន់វណ្ណៈ ក្នុងការរើសគូគ្រងឲ្យបុត្រធីតា ។ ល្អទី ៣ គឺគាត់គោរពតាម ភាសិតដ៏មានខ្លឹមសារមួយថា: "ក្រ ៗ បុះឲ្យតែមាន" ។ ពាក្យថាមាននេះសំដៅត្រង់មានគំនិតមារយាទនេះឯង ។

## បុគ្គលិកលក្ខណៈ នាងឃុននារី

ឃុននារី ជាបុត្រីបណ្ដាលចិត្តរបស់លោក ហ្លួងគេនសម្បត្តិ, ចៅក្រែពេជ្រ នៅស្រុកប៉ៃលិន ។ នាងជាតួឯកស្រីក្នុងរឿងគុលាបប៉ៃលិនរបស់លោក ញ៉ុក-ថែម ។ អ្នកនិពន្ធ បានក៏យកច់អំពីដំណើរការណ៍របស់នាងក្រមុំនេះដោយក្បោះក្បាយ ជាហេតុធ្វើឲ្យលេចឡើងនូវបុគ្គលិកលក្ខណៈមួយដែលយើងយកមកលាតត្រដាងនៅទីនេះ ។

តាមទំនៀមទម្លាប់ខ្មែរ និងច្បាប់សម្រាប់លោក, យើងក៏យល់បានដោយល្អិតល្អន់ថា: មនុស្សរួមសង្គម, សញ្ជាតិជាមួយគ្នាឬផ្សេងគ្នាក្ដី ត្រូវតែចេះគួរសមរវាងគ្នានិងគ្នា ។ សង្គមមនុស្សប្លែកអំពីសង្គមសត្វតិរច្ឆាន ។ ទោះបីច្បាប់វិទ្យាសាស្ត្រធម្មជាតិ និងច្បាប់ព្រះពុទ្ធសាសនាបានចាត់យើងបញ្ចូលទៅក្នុងពួកសត្វក៏ដោយ យើងត្រូវតែគោរពតាមច្បាប់សីលធម៌និងមនុស្សធម៌ឲ្យសមរម្យតាមឋានៈខ្លួន ។ ចុះឃុននារីវិញ. យើងចាត់ទៅក្នុងជំពូកណា, តាមច្បាប់ចរិយា

សាស្ត្រ ? ៗ នាងគ្រាន់តែឃើញទៅចិត្រក្លាម បញ្ចេញបុកពា ច្រើនថ្ងៃជាក់ក្លាក្លាម ៗ មើល ន៍! ទៅចិត្រទំលើកប្រណម្យ ធ្វើការកិច្ចទៅរកនាង គួរណាស់តែនាងលើកដៃសំពះវិញ , ផ្ទុយស្រឡះនាងគ្រាន់តែងក់ក្បាលទទួល ៗ មិនគ្រាន់តែ ប្រើបុកពាច្រើនថ្ងៃជាក់គ្នានោះទេ ថែមទាំងស្តីបន្ទុះបង្អាប់គ្នា យ៉ាងខ្លាំង ៗ គួរឬ ? . កាយវិកាទឹងសំដីឥតសប្បុរសរបស់ស្រី ថែបនេះ! ៗ បើនាងយល់ថា: ចិត្រជាកម្មកររបស់នាង ក៏គួរ យល់ថាគ្នាទើបនឹងមកថ្មី ដែលចាត់ថាជាក្មៀវបាន ៗ គួរ ណាស់តែនាងបញ្ចេញបំយកពាទៅរកគ្នា ដើម្បីឲ្យកម្មករថ្មី នេះមានសង្ឃឹមនឹងធ្វើជីពជន្មទៅលើចៅហ្វាយ ហើយឲ្យ មានសេចក្តីក្លាហាន នឹងបំពេញករណីយកិច្ចទៅមុខ ៗ ត្រង់នេះជាកញ្ចក់មួយចុះឲ្យយើងឃើញប្រត្យក្ស នូវគំនិតគំ អែលអាណានិគមនឹងមូលធននិយម ដែលធ្លាប់តែជិះជាន់ នឹងមើលងាយមនុស្សផងគ្នាយ៉ាងនេះ ៗ នាងនារីប្រើបុកពា ឥរិយាបថមិនស្របទៅតាមធម្មៈ នៃសង្គមមនុស្សដែលលើកគំ

កើនតម្លៃវិទ្យាសាស្ត្រ- ជីវិតមនុស្សមានតម្លៃជាងមាសប្រាក់ទៅទៀត ។ នាងប្រើកិរិយាព្រៃផ្សៃយ៉ាងនេះ បញ្ជាំងឲ្យយើងឃើញថានាងខ្វះបារីយភាពនឹងការវិភាគ ជាងនាងក្រមុំទាវក្នុងរឿង « ទុំទាវ » ។ យើងមិនសប្បាយចិត្តនឹងអាកប្បកិរិយារបស់នាងសោះ តែយើងមិនបន្ទោសឲ្យនាងតែម្នាក់ឯងដែរ ព្រោះយើងដឹងថា នាងគ្មានម្ដាយ ដើម្បីជួយអប់រំតាំងពីតូចមកម្ល៉េះ ។ មួយវិញទៀតសកម្មភាពរបស់សង្គមមូលធននិយមព្រមទាំងទ្រព្យសម្បត្តិរបស់នាង បានធ្វើឲ្យនាងមានគំនិតមិនល្អ, គំនិតមើលងាយដល់អ្នកក្រីក្រ ។ ចំពោះកិរិយាឆ្លើងឆ្លៃរបស់នាងវិញ ក៏យើងមិនសរសើរដែរ ថ្វីបើយើងដឹងថា: កិរិយាឆ្លើងឆ្លៃនឹងភាគារៈអៀនប្រៀនរបស់ស្រីក្រមុំ ជាហេតុមួយក្នុងបណ្ដាហេតុទាំងឡាយ ដែលនាំឲ្យស្រីក្រមុំមានសម្រស់ល្អ ។ យើងបាននិយាយពីខាងដើមរួចមកហើយ, នាងជានារីមួយមានអាកប្បកិរិយាស្មោកគ្រោកណាស់ក្នុងការទាក់ទងជាមួយនឹងសង្គម ។ ក៏

ប៉ុន្តែក្នុងរឿងជ្រើសរើសគូស្នេហាវិញ, នាងមានដំណើរការ ប្រសើរជាងនាងតាវ ៗ នាងបានប្រើពេលជាងប្រាំមួយខែ ដើម្បីសង្កេតមើលកិរិយាមារយាទរបស់ចៅចិត្រ មុននឹងសម្រេចចិត្តថាយកចៅចិត្រជាគូស្នេហា ៗ . . . . នាងបានយកចិត្តទុកដាក់ចំពោះចៅចិត្រ តាំងពីដើមដំបូងម៉្លេះ ព្រោះកម្មករនេះមានឫកពាពេបារប្លែកអំពីកម្មករនានា ៗ បើទុកជានាងនិយាយប្ដដែកអ៊ូមិនឈ្នះក៏ដោយចុះ នាងនៅតែមិនស្អប់ខ្ពើមសំដីរបស់ចៅចិត្រដែរ ព្រោះសំដីចៅចិត្រចេញទៅតាំងប៉ុន្មាន សុទ្ធតែមានប្រយោជន៍ទាំងអស់ហើយគួរឲ្យចង់ស្ដាប់ ៗ ទោះប្រៀនឬហួចក៏ដោយ ពោរពេញទៅដោយសិល្បៈបរិយាកាសយ៉ាងរីករាយ ដែលធ្វើឲ្យនាងអត់ទ្រាំពុំបាន នៅស្ដាប់ទាំងកព្រើ ៗ ពេលនោះពន្លកសេចក្ដីស្នេហា បានដុះឡើងក្នុងបេះដូងរបស់នាង ៗ មិនតែប៉ុណ្ណោះចិត្រជាបុរសមួយមានចំណេះវិជ្ជាខាងទ្រឹស្ដី នឹងបច្ចេកទេសក្នុងការប្រកបអាជីវកម្ម ហើយមិនចេះប្រកាន់ខ្លួន

ទៀតផង ៗ នោះធ្វើឲ្យយុវនារីរឹតតែពេញចិត្តឡើង ៗ ពិសេសទៅទៀត នាងឃើញទឹកចិត្តដ៏ស្មោះស្ម័គ្ររបស់មិត្រ , ក្លាហាន យកជីវិតខ្លួនទៅប្តូរប្រយុទ្ធនឹងពួកចោរទាំងពីរលើក ដើម្បីការពារជីវិតបិតារបស់នាងឲ្យផុតពីអន្តរាយ , ត្រង់នេះហើយដែលធ្វើឲ្យនាងសុខចិត្តព្រមរៀបការនឹងចៅមិត្រ ជាកម្មកររបស់ឯង ដោយស្មោះត្រង់នឹងរីកកពយបំផុត ៗ យើងសូមសរសើរយុវនារី ក្នុងបញ្ហាជ្រើសរើសគូស្នេហានេះ ៗ

★ ★

★

## បុគ្គលិកលក្ខណៈរបស់

## លោកបាឡាត់

លោកញ៉ុក-ថែម មិនបានប្រាប់ឈ្មោះ លោកបាឡាត់ ដែលជាតួអង្គក្នុងរឿងកុលាបប៉ៃលិនទេ ។ ដូចនេះ, ក្នុងការវិនិច្ឆ័យរបស់យើង ពាក្យដែលថា «បាឡាត់ៗ» នេះ, សូមអស់លោកបាឡាត់ទាំងឡាយ កុំម៉ែថាយើងរិះគន់ឲ្យអស់លោកនោះ, ពុំមែនទេ ។ យើងសូមទិទៀនចំពោះតែលោកបាឡាត់ក្នុងរឿងប្រលោមលោក របស់លោកញ៉ុក-ថែមតែប៉ុណ្ណោះ ។ លោកបាឡាត់ជាមន្ត្រី ១ រូបមានលក្ខណៈមិនល្អសោះ ។ ក្នុងមុខតំណែងដ៏ខ្ពង់ខ្ពស់នេះ គួរណាស់តែលោកជាមេដឹកនាំមួយដ៏ចំណាន សម្រាប់ឲ្យប្រជាជនដើរតាម ដើម្បីទៅរកសេចក្ដីថ្លៃថ្នូរនៅក្នុងសង្គម ។ ផ្ទុយទៅវិញ, លោកបាឡាត់ជាមនុស្សខ្វះសេចក្ដីក្លាហាន, គ្មានសុជីវធម៌ ហើយល្ងង់ខ្លៅជាទីបំផុត ។ លោកបាឡាត់ខ្វះសេចក្ដីក្លាហាន

ព្រោះលោកបានរត់ចូលទៅពួនក្រោមឡាន ក្នុងពេលដែលចោរកម្មបានកើតឡើង ហើយក្នុងពេលដែលចៅចិត្រជាកម្មករ, ចេញមុខតទល់នឹងពួកចោរព្រៃ ។ តតទៅ, ចៅចិត្រជាកម្មករសោះ ប៉ុន្តែចៅចិត្រមានសេចក្តីក្លាហានជាងលោកបាឡាត់ ដែលភារៈរបស់លោក ត្រូវចេញមុខការពារគ្រោះភ័យឲ្យប្រជារាស្ត្រនោះទៅទៀត ។ លោកបាឡាត់គ្មានសុជីវធម៌ ព្រោះលោកបានចាប់បង្ខំនាងយុវនារីឲ្យស្រឡាញ់លោក ព្រមទាំងបាននាំពួកចោរឲ្យមកប្លន់ផ្ទះហ្វូងរតនសម្បត្តិទៀត ។ យើងថាលោកបាឡាត់ជាមនុស្សល្ងង់ ព្រោះលោកចេះស្រឡាញ់យុវនារី តែលោកមិនចេះប្រើមធ្យោបាយល្អ ដើម្បីឲ្យហ្វូងរតនសម្បត្តិពេញចិត្តនឹងលោក ដែលជាហេតុមួយនាំឲ្យនាងនារីគាប់ចិត្តនឹងលោកដែរ ។

សរុបសេចក្តីមក, លោកបាឡាត់ជាមន្ត្រី ១ រូប មានទស្សនិយមស្មោកគ្រោកណាស់ ។

★

## បុគ្គលិកលក្ខណៈរបស់ចៅកែផាន់

ចៅកែផាន់, ជាអ្នកជំនួញទុច្ចរិតឬជាចោរតែម្ដង ៗ ក្នុងរឿងកុលាបប៉ៃលិន, លោកញ៉ុក-ថែមពុំបានប្រាប់យើងថាចៅកែផាន់ជាចោរទេ, គឺជាអ្នកជំនួញ ៗ ដូចនេះ, ក្នុងរឿងដែលចៅកែផាន់ទៅប្លន់ផ្ទះហ្លួងរតនសម្បត្តិ, គឺចៅកែនេះបានសម-គំនិតនឹងលោកបាឡាត់ ដែលជាអ្នកប្រាថ្នាធ្វើការសងសឹកនឹងហ្លួងរតនសម្បត្តិ ៗ តាមផ្លូវច្បាប់, អ្នកសមគំនិតបែបនេះត្រូវតែទទួលទោសយ៉ាងធ្ងន់ដែរ ៗ បើតាមការយល់របស់យើង, ចៅកែផាន់មិនមែនជាអ្នកសមគំនិតទេ, គឺពិតជាអ្នកដើមគំនិតទៅវិញ ៗ ព្រោះយើងយល់ថា: រឿងចាប់បង្ខំកូនក្រមុំគេនឹងរឿងទៅប្លន់ទ្រព្យគេនេះ ពិតជាចៅកែផាន់នឹងលោកបាឡាត់បានធ្វើគម្រោងការទុកជាមុនរួចស្រេចហើយ ៗ បើយ៉ាងនេះ, ចៅកែផាន់ជាចៅកែក្លែងខ្លួន, ការពិតរបស់គាត់ជាមេចោរទៅវិញទេ ៗ

មនុស្សដែលប្រព្រឹត្តទុច្ចរិតបែបនេះ ជាមនុស្សគំរក់បំផុត ៗ

## បុគ្គលិកលក្ខណៈតាសុខ

តាសុខជាអ្នកបរឡានមួយរូប មានសេចក្ដីស្មោះត្រង់ចំពោះថៅហ្វាយ, បេះដូងទុក្ខធុរៈ ការពារថៅហ្វាយនៅពេលមានអាសន្ន ៗ មនុស្សបែបនេះ ជាទីសរសើរនៃជនទូទៅ ៗ

★

## បុគ្គលិកលក្ខណៈម៉ុង-ថោង-យ៉ុក

ម៉ុង-ថោង-យ៉ុកជាអ្នកនៅជិតខាងហ្វូនតេនសម្បត្តិ ៗ គាត់បានឲ្យតាសុខយកឡានរបស់គាត់ ទៅតាមហ្វូនតេន-សម្បត្តិ ៗ អំពើនេះល្អណាស់ ៗ អ្នកនៅជិតខាងគ្នា ត្រូវតែចេះសង្គ្រោះគ្នា, ត្រូវតែកាន់ចិត្តធម៌រាប់រកគ្នាដូចនេះឯង ៗ

## បុគ្គលិកលក្ខណៈរបស់កម្មករ

ដោយបានថៅហ្វាយនាយមានចិត្តល្អចំពោះខ្លួន, ពួកកម្ម-ករទាំងឡាយខំធ្វើការដោយក្លាហាន ៗ នេះហើយការតស៊ូរបស់កម្មករ ៗ កម្មករខំធ្វើការណាស់បើថៅហ្វាយនាយជាមនុស្សមានចិត្តល្អដូចហ្វូនតេនសម្បត្តិនេះ ៗ គួរកត់សំគាល់ថា:

ជ័យជំនះរបស់ហ្វង់រគេនសម្បត្តិទៅលើពួកចោរ ពិតជាកើតឡើងអំពីការសាមគ្គីរបស់កម្មករទាំងអស់គ្នា ។ ដូចនេះ, ចូរនាយទុនទាំងឡាយកុំមើលងាយកម្មករ, កុំធ្វើបាបកម្មករឲ្យសោះ; ព្រោះកម្មករនេះហើយ ដែលជាអ្នកកសាងអ្វីៗទាំងពួងនៅក្នុងលោកនេះ ។

* * *

# រឿងរាមកេរ្តិ៍

## សេចក្ដីអធិប្បាយ

រឿង «រាមកេរ្តិ៍» ជារឿងបុរាណរបស់ឥណ្ឌៀ ៗ បណ្ឌិតវាល្មិគិ បានតែងរឿងនេះឡើងក្នុងសតវត្សដ៏លិចលង់យូរណាស់មកហើយ ៗ លោកបានដាក់ចំណងជើងថា: រាមា-យណៈ (Ramayana) . . . ៗ ខ្មែរយើងពុំបានបកប្រែដោយសុទ្ធសាធទេ, ក៏ប៉ុន្តែរៀបរឿងតាមលំនាំនោះ, មានផ្ទៃរឿងដូចគ្នា, មានលក្ខណៈជាខ្មែរ ៗ នៅជញ្ជាំងប្រាសាទអង្គរវត្ត, សិល្បករខ្មែរសម័យកសាង, ក៏បានយករឿងរាមកេរ្តិ៍ទៅឆ្លាក់ជាប់ ទុកជាស្នាដៃដ៏ខ្ពង់ខ្ពស់រហូតដល់សព្វថ្ងៃ ៗ រាមកេរ្តិ៍ជារឿងមួយវែងក្រៃណាវែង ; ជារឿងដែលដូនតាខ្មែរយើងនិយមរាប់អាន រហូតដល់យករឿងនេះមកធ្វើជាក្បួនទាយ ជោគជតារាសីទៀតផង ៗ នៅក្នុងសាលារៀន បែកខាងមធ្យមសិក្សា, កម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរក៏ពុំបានភ្លេចនឹកគិតដល់រឿងរាមកេរ្តិ៍ដែរ ៗ សិស្សានុសិស្ស

នៅថ្នាក់ទី៣ទំនើប បានសក្ក្រារឿងរាមកេរ្តិ៍ ក្នុងខ្សែបី ៗ ផ្ទៃរឿងក្នុងខ្សែបីនេះ ខាងសេចក្ដីសង្ខេបដូចតទៅ៖

— នាយពិរាធបានឆក់យកបាននាងសិតា អំពីព្រះហស្តព្រះរាមនិងព្រះលក្ស្មណ៍ដែលកំពុងបំពេញផ្នួស ប្រព្រឹត្តសីលឥសីគិនេស្រ្កមនៅកណ្ដាលព្រៃ ៗ នាងសិតាបានសោយសោកសង្រេងយ៉ាងខ្លាំង ៗ ព្រះរាមដែលជាអគ្គស្វាមីហើយនិងព្រះលក្ស្មណ៍ ដែលជាព្រះអនុជថ្លៃរបស់ព្រះនាងបានធ្វើសង្គ្រាមយ៉ាងអង់អាចតទល់នឹងក្រុម យក្សពិរាធគ្រាតែបានជ័យជំនះ យកព្រះនាងបានមកវិញ ៗ កាលបើសង្គ្រាមបានសាន្តត្រាណហើយ, ព្រះលក្ស្មណ៍សូមលាព្រះរាមជាបងទៅបំពេញផ្នួសឯទីដទៃវិញ ៗ ព្រះរាមមិនអនុញ្ញាត, សេចក្ដីប៉ងក៏ត្រូវខកខាន ៗ ទាំងបីព្រះអង្គនៅជួបជុំគ្នាដូចដើម ៗ

យក្ខិនីស្រីកញ្ញាមួយរូបឈ្មោះសូរបនខា, ជាប្អូនរបស់ទសកណ្ឋ, ចាប់ចិត្តស្នេហាទៅលើព្រះរាម ក៏ដើរត្រាច់ក្នុងព្រៃម្នាក់ឯងទៅសុំសេចក្ដីស្នេហាអំពីព្រះរាមនិងព្រះលក្ស្មណ៍ ៗ

នាងសូរបនខានេះមានរូបឆោមឆើតឆាយណាស់ ៗ ព្រះរាម មិនព្រមស្រឡាញ់នាងសោះ ៗ នាងវិលទៅសូមស្នេហា ព្រះលក្សណ៍ ៗ ក៏មិនមើលមុខនាងទៀត ៗ នាងបេះតែ លើកដៃសំពះអង្វរករ ដោយយំយែកហូរទឹកភ្នែករហាម រហូត ដល់របូតសំពត់នៅអាក្រាត់ខ្លួនទទេ ៗ ព្រះលក្សណ៍ក្រេវក្រោធ ខ្លាំង ក៏ចាប់ព្រះខាន់កាប់នាងកញ្ញាវិប ! ៗ ត្រូវរបួសហើយ, ស្រស់ស្រីតែបណ្ដើរ, ស្រែកដង្ហោយហៅទសកណ្ឋជាបងឲ្យ មកជួយបណ្ដើរ ៗ . . . . វិបត្តិផ្ទួរចិត្តក្នុងរឿងរាគៈរបស់ស្រី ក្រមុំនេះ បានបង្កើតជាសង្គ្រាមមួយថ្មីទៀត ៗ ពួកយក្ស ដែលជាបងប្អូនរបស់នាងសូរបនខាត្រូវព្រះរាមនិងព្រះលក្សណ៍ សម្លាប់ពេលអស់រលីង នៅតែឆ្អឹងរលួយស្អុយគគ្រុកកណ្ដាល ព្រៃ ៗ ក្នុងបណ្ដាយក្សដែលស្លាប់នោះ យើងស្គាល់ឈ្មោះ ខុនទូសណ៍, ត្រីមុខនិងក្រុង ១ ៗ

នាងសូរបនខា ចង់គំនុំនិងព្រះរាមយ៉ាងខ្លាំង ៗ នាង បានទៅទូលក្រុងរាពណ៍នៅឯនគរលង្កា ថាព្រះរាមមានមហេ-

សីល្អផ្កាប់, ហើយព្រះរាមបានសម្លាប់ពួកយក្សអស់ច្រើនឥតគណនា ។ ក្តៅដូចអគ្គី, ក្រុងរាពណ៍ប្រុងប្រៀបទៅសម្លាប់ព្រះរាមនឹងព្រះលក្ស្មណ៍ ហើយចាប់យកនាងសិតាមកធ្វើ អគ្គ-មហេសី ។ ក្រុងរាពណ៍បានបញ្ជាឲ្យអាមាត្យម្នាក់ ឈ្មោះមហារីត, ប្រែក្រឡាខ្លួនជាសត្វប្រើសមាស ១ ដើរវង្វេងផ្លូវកណ្តាលព្រៃចូលទៅដល់អាស្រម្មណ៍របស់ព្រះរាម ។ នាងសិតា ក្រឡេកឃើញប្រើសមាសចំឡែកក៏ប្រាថ្នាចង់បាន ។ នាងអង្វរព្រះរាមឲ្យដេញបាញ់ប្រើសមាសនោះ ។ ព្រះរាមដេញតាមប្រើស, ទុកឲ្យព្រះលក្ស្មណ៍នៅរក្សានាងសិតា ។ សត្វប្រើសបោលទៅមុខឥតបង្អង់, ព្រះរាមដឹងជាយក្សក្លែងខ្លួន ក៏យឹតធ្នូបាញ់សម្លាប់ប្រើសនោះស្លាប់ទៅ ។ វិញ្ញាណរបស់សត្វប្រើស បានស្រែកបន្លំថា: “ព្រះលក្ស្មណ៍អើយមកជួយបងផង, យក្សវាសម្លាប់បងក្ស័យជីវិតឥឡូវហើយ!” ឮសំឡេងបន្លំបែបនេះ, នាងសិតាស្មានថាជាសម្រែករបស់ព្រះរាមជាស្វាមីក៏ចេញបញ្ជាឲ្យព្រះលក្ស្មណ៍រត់ទៅជួយភ្លាម ៗ

ព្រះលក្ស្មណ៍ស្រែកផ្ដាំទេវតាឲ្យជួយរក្សានាងសីតារួចក៏រត់ទៅកាន់សមរភូមិ ។ ពេលដែលព្រះលក្ស្មណ៍ចេញផុត, ក្រុងកពណ៌បានឱកាសក៏ក្លែងខ្លួនជាតាបស មានឫកពាររមទំ ដើរចូលមកកាន់អាស្រមរបស់នាងសីតា ។ ក្នុងឱកាសដ៏ល្អនេះ ក្រុងកពណ៌បានឆក់បាននាងសីតា ហោះចេញទៅ ។ „

ខ្សែបីរបស់រឿងរាមកេរ្តិ៍ មានសេចក្ដីសង្ខេបតែត្រឹមណោះ ប៉ុន្តែរឿងរាមកេរ្តិ៍ មិនទាន់ចប់នៅឡើយទេ ។

ខ្សែបីនៃរឿងរាមកេរ្តិ៍ បានបង្ហាញយើងនូវសេចក្ដីកំសត់ព្រាត់ប្រាស នឹងសង្គ្រាមបង្ហូរឈាមយ៉ាងសម្បើម ។ សង្គ្រាមនឹងសេចក្ដីព្រាត់ប្រាស សុទ្ធតែកើតមកអំពីសេចក្ដីស្នេហាទាំងអស់ ។ កាមរាគបាននាំនាង សូរ្បនខា ត្រូវរបួសជាទម្ងន់! កាមរាគបានធ្វើឲ្យព្រះរាមព្រាត់នាង សីតា! កាមរាគដដែលនេះបានឲ្យពលយក្ស ស្លាប់នេលពាសពេញព្រៃ ។

ខ្សែបីនៃរឿងរាមកេរ្តិ៍ បានបញ្ចូនឲ្យយើងឃើញរូប

ភាពជាក់ស្តែង របស់ព្រះពុទ្ធវាទ ១ បទថា តណ្ហាជាហេតុនៃសេចក្តីទុក្ខ » ។ ប៉ុន្តែតួអង្គនៃរឿងកាមក្តៅបានបញ្ជាក់ឃើញថា: រឿងកាមក្តៅនេះគ្របដណ្តប់ដោយឥទ្ធិពលព្រហ្មញ្ញសាសនា ព្រោះតួអង្គទាំងឡាយសឹងពោរពេញដោយចិត្តឃោរឃៅខ្លាំងណាស់ ។

យក្ខនីស្រីកញ្ញាសូរបនខា បានទៅសូមសេចក្ដីស្នេហាអំពីព្រះលក្ខណ៍ដែលកំពុងប្រព្រឹត្តសីលធម៌ភិនេស្ក្រមបំពេញឫទ្ធិតេជះនៅកណ្ដាលព្រៃ ។ បើព្រះលក្ខណ៍មិនស្ម័គ្រស្នេហាក៏ហើយទៅចុះ! ហេតុអ្វីក៏យកព្រះខ័នកាប់នាងសូរបនខាឲ្យមានស្នាកស្នាមទៅវិញ? ព្រះលក្ខណ៍ធ្វើដូច្នេះត្រូវឬទេ? សូមអ្នកវិនិច្ឆ័យ ។

## សេចក្ដីអធិប្បាយ

នាងសូរបនខាជាកញ្ញាមួយរូប មានសម្រស់ស្រស់ស្រិល ។ នាងតែងល្អយ៉ាងឆើតឆាយគួរឲ្យកើតតម្រេកត្រេកត្រអាល ។ បុត្រីរបស់យក្សមែនពិត, តែរូបឆោមលោមពណ៌របស់នាង មិនអន់ជាងបទុមកេសរក្នុងរឿងបាល្យយន្តឡើយ ។ ក្រមុំសូរបនខាចាប់ចិត្តស្នេហាទៅលើព្រះរាម និងព្រះលក្ខណ៍យ៉ាងខ្លាំង ។ បំណងស្នេហានេះកើតឡើងដោយសុទ្ធចិត្ត មិនមែនជាអំពើមាយាក្លែងក្លាយទេ ។ សូរបនខាបានតាំងចិត្តថា: នឹងទៅសុំសេចក្ដីស្នេហាអំពីព្រះរាមឬព្រះ-លក្ខណ៍ឲ្យគ្រាន់តែបាន, ហើយនាងនឹងនៅបំរើព្រះរាមឬព្រះលក្ខណ៍ រហូតដល់ក្ស័យជីពជន្ម ។ តាំងចិត្តដូច្នេះហើយ,

ស្រីស្រស់ស្មៀកពាក់ស្អាតបាតធ្វើដំណើរម្នាក់ឯង កណ្ដែងកណ្ដោបកណ្ដាលព្រៃតម្រង់ទៅរកអាស្រមរបស់ព្រះរាម ។ ព្រះរាមក្រឡេកឃើញសូរបនខាទៅដល់ក៏សួរថា:

-ស្រីមានរូបឆោម អញ្ជើញមកមានការអី ?

នាងក្រមុំលើកដៃប្រណម្យទូលតាមត្រង់ថា:

-ខ្ញុំមកសុំសេចក្ដីស្នេហាអំពីព្រះរាម ! ។

ព្រះរាមបានឆ្លើយតបទៅវិញថា៖

- ខ្ញុំមាននាងសីតាជាមហេសីរួចទៅហើយ ។ សូមស្រីស្រស់ទៅសុំសេចក្ដីស្នេហាអំពីព្រះលក្ស្មណ៍ ជាព្រះអនុជខ្ញុំវិញទៅ ។ ព្រះលក្ស្មណ៍មិនទាន់មានមហេសីទេ គេនឹងទទួលយកនាងជាយើកកាយ ។...

សូរបនខាលើកដៃសំពះលាព្រះរាម រួចដើរតម្រង់ទៅរកព្រះលក្ស្មណ៍ ។ នាងលើកដៃសំពះសុំស្រឡាញ់ព្រះលក្ស្មណ៍ តែព្រះលក្ស្មណ៍មិនព្រមស្រឡាញ់នាងសោះ បែរជាបង្គាប់នាងថា:

–ចូរនាងទៅសុំសេចក្ដីស្នេហាអំពីព្រះរាមវិញទៅ ៗ ព្រះរាមនឹងយកនាងធ្វើជាមហេសីទីពីរ ៗ

ទទួលបង្គាប់ពីព្រះលក្ស្មណ៍, នាងសូរបនខាវិលត្រឡប់មករកព្រះរាមម្ដងទៀត ៗ ព្រះរាមមិនទទួលយក ហើយពន្យល់ណែនាំនាងថា:

ព្រះលក្ស្មណ៍មិនស្ងប់ចិត្តនឹងនាងទេ, បើនាងបេះធ្វើម្ជុលម្ជុំ ជាកាតាមគេ ហើយយំសោកស្ដីររករគេ. នោះ, គេនឹងមិនបោះបង់នាងឡើយ ៗ

នាងក្រមុំកំដរបេញពីអាស្រមទៅរកព្រះលក្ស្មណ៍ ម្ដងទៀត ៗ នាងនឹកចំឡែកក្នុងខ្លួន ចំពោះអាកប្បកិរិយា របស់បុរសពីររូបនេះយ៉ាងខ្លាំង; អ្នកនិពន្ធរឿងរាមកេរ្តិ៍ ក៏សរសេរថា៖

នាងកញ្ញាម្ដងនេះបែបអេះអុះ
បែបអេះអុញតុញតុះទាល់ច្រាញ
មកឯណេះវុញទៅឯណោះណា

មកផេះផ្កាប្រើឲ្យទៅឯប្អូន

មកដល់ប្អូនបង្គាប់ឲ្យទៅបងី

ត្រឡប់សារប្រើនផងបង៉ីនេះសួនឡ

ឥឡូវត្រូវត្រឡប់ទៅរកប្អូន

បញ្ជូនចុះបញ្ជូនឡើងជាច្រើនគ្រា

ប្រុសអស់នេះជាប្រុសចំឡែកពិត

ស្រីមកសុំស្នេហ៍ស្និទ្ធឥតត្រូវការ

តាមធ្លាប់ដឹង, ប្រុសៗកើតស្នេហា

ទៅបរចាប៉ងចង់ថៃបូរស្រី ៗ . . .

ជួនកាលស្រីមិនស្ម័គ្រមិនបើ

ខ្វះខំផ្គាប់ទំពាំបានស្រី ៗ

នេះប្រុសអីស្រីចង់មិនចូលចិត្ត ៗ . . .

ដើរទៅដល់ព្រះលក្ស្មណ៍, សូរបនខាលើកដៃសំពះ អង្វរករសុំនៅបំរើជាមហេសីត្រាតែផុតជីវិត ៗ ព្រះលក្ស្មណ៍ មិនព្រមស្រឡាញ់នាងសោះ, ព្រះអង្គមានបន្ទូលថាៈ

–សូរបេទា, ចូលនាងវិលទៅវិញចុះ! ក្នុងមួយជាតិនេះ យើងមិនចូលចិត្តស្នេហានឹងកញ្ញាណា ទាំងអស់ ។

នាងក្រមុំអង្គុយយំ ហើយនិយាយរអាក់រអួលថា៖

–ទូលព្រះបង្គំមិនវិលទៅវិញទេ! ទូលព្រះបង្គំសូមនៅក្បែរព្រះអង្គជានិច្ច . . ទូលព្រះបង្គំជាប់ចិត្តនឹងព្រះអង្គខ្លាំងណាស់ ។

ទតឃើញនាងសូរបេទា ក្រាញមិនព្រមចេញទៅដូច្នេះ, ព្រះលក្ស្មណ៍ កន្ត្រាក់ព្រះខ័នកាប់វៃ! . . . បណ្ដាលឲ្យនាងមានរបួសជាទម្ងន់ ធ្លាក់ខ្លួនទៅជាស្រីពិការ ។ សូរបេទារត់ចេញពីកាស្រម្ពព្រះលក្ស្មណ៍ ទាំងសម្រែកយំរំពងព្រៃ ។

តើព្រះលក្ស្មណ៍ ធ្វើយ៉ាងនេះត្រូវឬខុស? ប្រស្នានេះ ពិបាកដោះស្រាយមែន! តែ, យើងសូមល្បងធ្វើការវិនិច្ឆ័យដូចតទៅ : រឿងហ្នឹង, យើងត្រូវវិនិច្ឆ័យទៅតាមន័យពីរយ៉ាង ។

១– បើវិនិច្ឆ័យតាមន័យអច្ឆរិយៈ ( au sens merveilleux. )

យើងឃើញថា: ព្រះលក្ខណ៍ បានប្រព្រឹត្តអំពើបាបខ្លាំងណាស់ ៗ ព្រះអង្គមិនត្រូវដាក់ទណ្ឌកម្មធ្ងន់ ទៅលើពងកាយស្រីក្រមុំដែលគ្មានកំហុសអ្វី ក្រៅអំពីមកសុំសេចក្តីស្នេហាពីព្រះអង្គតែប៉ុណ្ណោះ ៗ បើព្រះអង្គជាប់កាមកិលេសហើយ គួរតែទំអប់ស្រីក្រមុំដែលពោរពេញដោយកាមរាគៈនេះ ឲ្យរំលត់សេចក្តីត្រេកត្រអាលចំពោះកាមបទ្តិបត្តន៍ ៗ ផង ៗ បើព្រះអង្គគ្មានសមត្ថភាពនឹងណែនាំស្រីក្រមុំឲ្យលះបង់តណ្ហាបានទេ, ក៏គួរតែព្រះអង្គដើរចេញឲ្យឆ្ងាយទៅ មិនត្រូវធ្វើទុក្ខបុកម្នេញឲ្យគ្នាពិកា ដៃយ៉ាងហ្នឹងទេ ៗ ព្រះអង្គប្រព្រឹត្តសីលគុណត្រៃដើម្បីប្រោសសត្វ មិនមែនដើម្បីសម្លាប់សត្វដូច្នេះឡើយ ៗ អំពើរបស់ព្រះអង្គជាបទឧក្រិដ្ឋមួយជាក់ស្តែងណាស់ ៗ យើងត្នះតិះដៀលដល់អំពើអាក្រក់បែបនេះ ៗ

២- បើយើងវិនិច្ឆ័យអំពើរបស់ព្រះលក្ខណ៍ តាមន័យលោកិយសច្ចៈ (au sens réel) យើងសូមសរសើរព្រះអង្គក្នុងរឿងនេះ ៗ ក្នុងន័យលោកិយសច្ចៈ, នាងក្រមុំគ្រាន់តែជា

សេចក្តីតម្រេកខាងផ្លូវកាម ដែលកើតចេញអំពីចិត្តរបស់ព្រះលក្ស្មណ៍តែប៉ុណ្ណោះ ។ ព្រះលក្ស្មណ៍កាប់នាងក្រមុំ បានន័យថា: ព្រះអង្គខំព្យាយាមរំលត់កាមរាគៈ របស់ព្រះអង្គឲ្យរីងស្ងួតទៅវិញ ព្រោះព្រះអង្គឈ្វេងយល់ថា:

« កាមតណ្ហាជាហេតុនៃសេចក្តីទុក្ខ » ។

ព្រះរាមកើតទុក្ខច្រើនលើកច្រើនគ្រា ព្រោះតែនាងសីតាដែលជាតួអង្គនៃកាមតណ្ហានោះឯង ។

> អ្នកបានអានរឿងរាមកេរ្តិ៍ខ្មែរ ៣ ។ អ្នកឃើញព្រះរាមបានធ្វើការអ្វីខ្លះ? ។ សូមអ្នកអធិប្បាយដោយត្រួស ៗ អំពីការប្រព្រឹត្តិរបស់ព្រះរាម ព្រមទាំងវិនិច្ឆ័យ លើអំពើសកម្មរបស់ព្រះរាមផង ។

## សេចក្តីអធិប្បាយ

ព្រះរាមជាតួអង្គមួយក្នុងរឿងរាមកេរ្តិ៍; ជាព្រះស្វាមីរបស់ព្រះនាងសីតា និងជាព្រះជេដ្ឋារបស់ព្រះលក្ស្មណ៍ ។ ក្សត្រទាំងបីព្រះអង្គនេះមិននៅសោយរាជសម្បត្តិក្នុងនគរទេ, ទ្រង់បាននាំគ្នាទៅប្រព្រឹត្តសីល ឥសីកិនេស្រ្កមកណ្តាលព្រៃព្រឹក្សាលតាវល្លិ

ឆ្ងាយអំពីលំនៅមនុស្ស ។ ក្នុងខ្សែប៉ែនៃរឿងរាមកេរ្តិ៍នេះ, យើងឃើញព្រះរាមបានធ្វើសកម្មភាពដូចតទៅ ៖

– ព្រះអង្គបានធ្វើសង្គ្រាមតទល់នឹងក្រុងពិរាធ ដែលមកដណ្តើមយកនាងសីតាអំពីព្រះអង្គ ។

– ព្រះអង្គមិនសព្វព្រះរាជហឫទ័យ បណ្តាយព្រះលក្ស្មណ៍ជាព្រះអនុជ ទៅនៅឯទីឆ្ងាយតែម្នាក់ឯង ។

– ព្រះអង្គមិនព្រមទទួលសេចក្តីស្នេហាអំពីនាងកញ្ញាសូរបនខា ។

– ព្រះអង្គបានដេញបាញ់ប្រើសមាស ដែលយក្សឈ្មោះមហារីកបានប្រែក្រឡា ។

– ព្រះអង្គបានធ្វើសង្គ្រាមទល់នឹងក្រុងពពណ៍ ដើម្បីដណ្តើមយកនាងសីតាពីនគរលង្កាមកវិញ ។

អំពើសកម្មរបស់ព្រះរាមនេះ បាននាំយើងឲ្យដឹងដល់ទឹកហឫទ័យរបស់ព្រះអង្គ ចំពោះព្រះអនុជនឹងមហេសី ។ យើងសង្ខេបបុគ្គលិកលក្ខណៈ របស់ព្រះអង្គបានដូចតទៅ៖

— ព្រះរាមមានសេចក្ដីស្នេហាចំពោះព្រះអនុជ

— ព្រះរាមមានភក្ដីភាពនឹងប្រកបដោយធម៌ សទារសន្ដោស ចំពោះព្រះអគ្គមហេសី ។

សេចក្ដីស្នេហាចំពោះបងប្អូន ជាទីពេញចិត្តរបស់មាតាបិតាទាំងឡាយ និងជាទីសរសើររបស់មនុស្សជាតិទូទៅ ។ ដូចនេះ, ព្រះរាមនឹងពុំបានទទួល ការរិះគន់អំពីសាធារណជនឡើយ ព្រោះព្រះអង្គមានព្រះទ័យមេត្តា ដល់ព្រះលក្ស្មណ៍ ជាព្រះអនុជខ្លាំងណាស់ ។ ព្រះអង្គមិនព្រមឲ្យអនុជទៅនៅឯទីឆ្ងាយពីព្រះអង្គទេ ព្រះអង្គតែងនឹកបារម្ភដល់គ្រោះកាចជានិច្ច។ ប្រវត្តិរបស់គ្រួសារសាមញ្ញ ច្រើនតែបានលាតត្រដាងនូវហេតុមួយផ្នែក, គឺ: បងប្រុសកាលបើមានប្រពន្ធហើយ ច្រើនតែភ្លេចគិតដល់ប្អូន ៗ របស់ឯង; ឬ, បងស្រី, កាលបើមានប្ដីហើយ, ប្អូន ៗ ពុំសូវហ៊ានចូលទៅជិតគាត់ទេ ។ ហេតុគេទបែបនេះ មានសភាពស្មោកគ្រោកក្រៃលែង ៗ វាដឹកនាំមនុស្សឲ្យយល់ច្រឡំថា: ស្នេហាស្វាមីភរិយាជាកាំបិតកាត់

ផ្តាច់ នូវការទាក់ទង រវាងបងនឹងប្អូនឬរវាងគ្រួសារទាំងមូល។ ព្រះរាមបានឈ្វេង យល់ច្បាស់នូវរឿងក្រខ្វក់ទាំងនេះ ព្រះអង្គហ៊ានបដិវត្តគំនិតបុរាណ ដើម្បីឲ្យមនុស្សបានរស់នៅសុខសាន្តជាមួយនឹងបងប្អូន ។ បើមនុស្សលោកសព្វថ្ងៃ មានប្រាថ្នាចង់ឲ្យអ្នកដទៃសរសើរ គួរកុំភ្លេចក្រឡេកមើលប្រវត្តិរបស់ព្រះរាមក្នុងខ្សែបទរឿងរាមកេរ្តិ៍ ។

ព្រះបាទស្រីធម្មរាជា (ព្រះរាជសម្ភារ) ដែលជាព្រះមហាក្សត្រខ្មែរ នឹងជាកវីឯករបស់ខ្មែរ ក្នុងសតវត្សរ៍ ទី ១៧ បានសរសើរដល់ព្រះរាមយ៉ាងខ្លាំង ក្នុងការដែលព្រះរាមមានភក្តីភាព ចំពោះនាងសិតា នឹងក្នុងការដែលព្រះរាមតស៊ូធ្វើសង្គ្រាមសម្លាប់យក្ស ដើម្បីដណ្តើមយកនាងសិតា ជាទីស្នេហាមកវិញទាល់តែបាន ។ លោកសន្ធរម៉ុក ក៏បានរំឭករឿងស្នេហាព្រះរាមសិតាដែរ នៅក្នុងរឿងទុំទាវដែលលោកបានតែងឡើងក្នុង គ.ស. ១៨៥៩ ។ មែនហើយ ! មនុស្សទាំងឡាយ, ទោះបីនៅក្នុងវណ្ណៈណាក៏ដោយ, សុទ្ធតែ

ពេញចិត្តនឹងព្រះរាមទាំងអស់ ៗ គេឃើញព្រះរាមមានកតញ្ញូ ភាពចំពោះមហេសីតែមួយគត់ ៗ ព្រះរាមមិនព្រមស្រឡាញ់ ស្រីណាដទៃ ក្រៅអំពីនាងសិតាឡើយ ៗ នាងកញ្ញាសូរបនខា មកសំពះអង្វរគេព្រះអង្គ សូមថ្វាយខ្លួនធ្វើជាមហេសីទីពីរ, ព្រះអង្គមិនព្រមទទួលសោះ ព្រោះព្រះអង្គយល់ថា: "បុរស ណាដែលទៅយកប្រពន្ធចុង មិនខុសអ្វីពីឈោងដៃទៅយក កាំបិតមកចាក់ដើមទ្រូងប្រពន្ធដើមឡើយ" ៗ គំនិតរបស់ព្រះអង្គល្អប្រសើរណាស់ ៗ គំនិតនេះផ្ទុយនឹងគំនិតលាមករបស់ បុរសភាគច្រើនដែលនិយមស្នេហ៍គេប្រពន្ធ, មួយហើយមួយ ទៀត, តាំងពីនៅក្មេងរហូតដល់សក់ស្កូវ មិនចេះចប់ ៗ

ព្រះរាមបានធ្វើសង្គ្រាមឥតរួញរាឥតញញើតដៃ,តទល់ នឹងក្រុមយក្សនៅក្រុងលង្កា, គ្រាតែបានជ័យជំនះ ៗ នេះក៏ ព្រោះតែព្រះអង្គ មានស្នេហាភាពនឹងកតញ្ញូភាពចំពោះមហេសី របស់ព្រះអង្គ ៗ ព្រះបាទស្រីធម្មរាជា, ក្នុងច្បាប់ត្រីនេត្ររបស់ ព្រះអង្គ, ព្រះអង្គសរសើរដល់រឿងហ្នឹងដែរ ៗ

អ្នកខ្លះពោលជំទាស់ថា: មិនត្រូវសរសើរទេ! ស្ដាប់រស់ព្រោះស្នេហាជាអំពើថោកទាប ។ អ្នកដែលមានគំនិតបែបនេះ សុទ្ធតែជាមនុស្សខ្វះការពិចារណា ។ អុញ! យើងនិយាយត្រង់នេះ ហាក់ដូចជាយើងពុករលួយពេក ។ ប៉ុន្តែ មិនឲ្យយើងនិយាយឯណាបាន, បើយើងមិនឃើញបុរសណាមួយសុខចិត្តឈរទេបដៃ សំឡឹងមើលប្រពន្ធរបស់ខ្លួនដែលត្រូវអ្នកដទៃមកចាប់បង្ខំរួមស្នេហាដល់មុខសោះ ។

យើងសរសើរព្រះរាម តែយើងមិនសរសើរកម្លោះណាដែលបណ្ដោយឲ្យស្នេហាដឹកនាំ ។

យក្សឈ្មោះ មហារីក កាលដើមឡើយ, បានទទួលស្គាល់ថា:ព្រះរាមជាក្សត្រមានព្រះហឫទ័យល្អ គួរគោរពរាប់អាន; តែ, ដល់ក្រោយមក! មហារីកបានបង្កគំនុំធ្វើការសងសឹកនឹងព្រះរាមទៅវិញ ។ ហេតុអ្វីក៏យក្សមហារីកមានគំនិតពីរផ្ទុយគ្នាបែបនេះ; ។ ចូរអ្នកយករឿងរបស់មហារីក មកបញ្ចាំងមើលគំនិតមនុស្សក្នុងសង្គមសព្វថ្ងៃនេះ ។

## សេចក្ដីអធិប្បាយ

ក្រោយពេលដែលបានស្ដាប់សេចក្ដីទូលថ្វាយរបស់នាងកញ្ញា សូវថនា, ក្រុងរាពណ៍យក្ស បានត្រាស់ហៅអាមាត្យមួយរូបឈ្មោះមហារឹក មកបញ្ជាថា៖

– នែ! មហារឹក, ចូរអ្នកក្លែងខ្លួនជាប្រើសមាស, បោលចូលទៅជិតអាស្រម្មរបស់ព្រះរាម ដើម្បីបោកបញ្ឆោតព្រះរាមឲ្យដេញតាមអ្នក, ហើយក្នុងឱកាសនោះ យើងនឹងចូលទៅឆក់យកព្រះនាងសីតា មកកាន់នគររបស់យើង ។

មហារឹក, កាលបើបានឮសេចក្ដីបញ្ជារបស់ក្រុងរាពណ៍ដូច្នេះ ក៏គិតភ័យញ័រខ្លួនបំប្រប ។ នាយបានដឹងច្បាស់ថា: ព្រះរាមមានឫទ្ធិពូកែអស្ចារ្យណាស់; ព្រះរាមបានសម្លាប់ពពួកយក្សយង់ឃ្នងជាច្រើនរូប មានយក្សទូសកណ្ឋ, ក្រុងខ និងត្រីមុខជាដើម ។ មួយវិញទៀត នាយមហារឹកបានទទួលស្គាល់ថា: ព្រះរាមជាក្សត្រល្អប្រកបនូវបុកពាគួរស្រឡាញ់, គួរគោរព, មិនគួរខ្លួនទទួលបង្គាប់ក្រុងរាពណ៍ទៅធ្វើបាបព្រះរាមទេ ។ គិត

ដូច្នេះហើយ, នាយមហារីកលើកដៃទូលថ្វាយក្រុងកពណ៌ថា៖

–បពិត្រព្រះអង្គ ខ្ញុំមិនហ៊ានធ្វើតាមបញ្ជាការរបស់ព្រះអង្គទេ ព្រោះខ្ញុំខ្លាចស្លាប់ណាស់, ខ្ញុំដឹងច្បាស់ថា: ព្រះពមមានឫទ្ធិបេស្ដាជាងក្សត្រនានាក្នុងភពលោកនេះ ។

ក្រុងភពណ៌ខឹងនឹងមហារីក គឺស្រែកដេរថា:

– យី ! អាឯងហ៊ានសរសើរព្រះពមទៅវិញ! អញជាម្ចាស់លើក្បាលអាឯង, ម៉េចក៏អាឯងមិនសរសើរ ? ឯងត្រូវតែធ្វើតាមបង្គាប់អញទើបបានសេចក្ដីសុខ ។

មហារីកដឹងច្បាស់ថា: ខ្លួនត្រូវតែស្លាប់; បើមិនស្លាប់ដោយដៃព្រះពម ក៏ត្រូវស្លាប់ដោយព្រះខាន់របស់ក្រុងភពណ៌ដែរ ។ ដូច្នេះ, មហារីកក៏ទទួលធ្វើតាមសេចក្ដីបញ្ជារបស់ក្រុងភពណ៌ទៅ ។ នាយបានទៅសុំលាប្រពន្ធកូន មុននឹងចេញទៅបំពេញបេសកកម្មនេះ ។ នាយនឹកអាណិតដល់ព្រះពមខ្លាំងណាស់, នាយគ្មានចិត្តនឹងធ្វើឲ្យបាយគលដ៏ណាមកនេះសោះ ។ ប៉ុន្តែដល់ពងកាយរបស់នាយត្រូវផ្ទុះធ្លាយដោយស្វាបព្រួញរបស់ព្រះពម,

ទាយក៏បង់គំហឹងនឹងព្រះរាមក្សាម, ក៏ប្រើកលឧបាយល្បិចហុច ឧកាសឲ្យក្រុងរាពណ៍ មកឆក់នាងសិតាទាល់តែបាន ៗ ត្រង់ ហ្នឹងហើយដែលមានបញ្ហាចោទឡើងថា „ហេតុអ្វីក៏យក្ស មហារីកមានគំនិតពីរផ្ទុយគ្នាបែបនេះ? ” យើងមិនបាច់ឆ្ងល់ទេ រឿងរាមកេរ្តិ៍នេះបានបញ្ជាក់យើងរួចហើយ ៗ មហារីកបង់ គំហឹងនឹងព្រះរាមវិញ ព្រោះព្រះរាមបានបាញ់សម្លាប់មហា រីក ៗ បើព្រះរាមមិនបានឲ្យទុក្ខដល់មហារីកទេ មហារីកនៅតែ សម្រក់ទឹកភ្នែកអាណិតអាសូរព្រះរាម ក្នុងការដែលយក្សប៉ង យាយីព្រះរាមនេះតែដដែល ៗ មនុស្សយើងមិនអាចបង គំនុំ នឹងអ្នកដទៃបានទេ បើគេទាំងនោះឥតបានធ្វើទុក្ខបុក ម្នេញ ដល់យើងម្ដងណាសោះ ៗ ប៉ុន្តែ, បើអ្នកធំ ដែល យើងធ្លាប់គោរពនោះ, បែរជាមកជិះជាន់យើងវិញ, សេចក្ដី គោរពដែលធ្លាប់មានមក ក៏ត្រូវតែរលាយ ហើយសេចក្ដីប៉ង ព្យាបាទគ្នាក៏ចាំបាច់ត្រូវតែកើតមានឡើងក្នុងពេលនោះ ៗ

រឿងព្រះរាមនឹងមហារីកជារឿងចាស់ ៗ រឿងនេះបាន

លេចផុតទៅហើយ ៗ ប៉ុន្តែ, រឿងរបស់មនុស្សសព្វថ្ងៃ ជារឿងថ្មី, រឿងថ្មីនេះរឹតតែមានការបងគំនុំគុំគួនគ្នា ជាងរឿងចាស់ទៅទៀត ៗ គួរតែយើងកល់គ្នា ខំបន្សាបកឲ្យផុតស្រឡះចេញ ៗ ធ្វើឲ្យមនុស្សឈប់បងគំនុំគ្នា គឺធ្វើឲ្យមនុស្សមានគំនិតជីវភាពស្មើគ្នា, មានសិទ្ធិនិងសេរីភាពដូចគ្នាទាំងអស់ៗ

*

* *

# ស្រីហិតោបទេស

## ប្រភពនៃរឿង –

នៅស្រុកឥណ្ឌា មានគម្ពីរមួយឈ្មោះថា: "បញ្ចតន្ត្រ:" ប្រែថា: ច្បាប់ប្រាំប្រការ ។ នាពយណាបណ្ឌិត (ជាតិឥណ្ឌា) បានយករឿងបញ្ចតន្ត្រ:នេះ មកធ្វើឲ្យកើតទៅជារឿងមួយថ្មីទៀតឲ្យឈ្មោះថា „ស្រីហិតោបទេស„ ។ ដោយបានយករឿងទាំងពីរនេះមកប្រៀបធៀបគ្នា, ព្រះវិរិយ:បណ្ឌិតោភិក្ខុ, ប៉ាង-ខាត់ បានឲ្យការថា៖ ហិតោបទេសនេះ គឺបញ្ចតន្ត្រ: តែម្តង ដោយគ្រាន់តែបំព្រួញមកនៅត្រឹមតែ៤ភាគ

- ភាគ១ - មិត្រលាភ (ការគប់មិត្ត)
- ភាគ២ សុហ្ឫទ្ភេទ (ការបំបែកមិត្ត)
- ភាគ៣ – វិគ្រហ: (សង្គ្រាម)
- ភាគ៤ - សន្ធិ (សន្ធិភាព) ។

## អត្ថន័យនៃរឿង –

ហិតោបទេស ប្រែថា: ការប្រៀនប្រដៅ, ពន្យល់ប្តូរដឹក-

នាំជនានុជន ឲ្យបានប្រយោជន៍នៅនាលោកិយនេះ ។

និច្ចាភាវនៃរឿង.-

បណ្ឌិត ប៉េន.ហៃ អ្នកប្រាជ្ញជាតិអង់គ្លេសបានពោលថា:ហិតោបទេសនេះ អាស្រ័យគោលពុទ្ធសាសនាផ្សេងដែរៗ ក៏ប៉ុន្តែ,តាមការសង្កេតរបស់យើង, យើងឃើញថា:ហិតោបទេសគ្រប់ដណ្ដប់ដោយឥទ្ធិពលព្រហ្មញ្ញសាសនា ព្រោះអ្នកនិពន្ធបានសរសេរដឹកនាំជនានុជន ឲ្យជឿរឿងគុតនិយមផ្សេងៗ ដែលឃ្លាតឆ្ងាយពីទ្រឹស្ដីនៃព្រះពុទ្ធសាសនាយ៉ាងដាច់ស្រឡះ ។ ក៏ប៉ុន្តែ, នៅក្នុងរឿងហិតោបទេសដដែលនេះ អ្នកនិពន្ធក៏បានបញ្ចេញនូវគំនិតប្រាកដនិយមរបស់ខ្លួនដែរ ដូចជាលោកបានសរសេរថា:

“អ្នកនេះជាពួកយើង, អ្នកនោះជាពួកគេ, នេះជាសំដីនៃអ្នកមានចិត្តគំនិតស្រាលទេ ឯអ្នកដែលមានការសិក្សាច្រើន មានចិត្តគំនិតល្អ តែងនិយាយថា អ្នកនៅលើផែនពសុធាសុទ្ធតែជាផៅពង្សនឹងគ្នាទាំងអស់” ។

## ស្រីហិតោបទេសរបស់ភិក្ខុប៉ាង់-ខាត់.-

ស្រីហិតោបទេសជាភាសាខ្មែរនេះ ព្រះវិរិយៈបណ្ឌិតោ ភិក្ខុ ប៉ាង់-ខាត់ បានប្រែត្រង់តាមច្បាប់ដើមជាភាសាសំស្រ្កឹតរបស់នាឮយណបណ្ឌិត ។

## ការដកស្រង់កាសិតខ្លះ ពៅក្នុងស្រីហិតោ-បទេស.-

៤-(គន្ថារម្ភបទ)- រូបគំនូរដែលគេគូរទុកញ្ច័ភាជនៈថ្មី មិនឃ្លាតក្លាយទៅជាប្រការដទៃយ៉ាងណា នីតិវិជ្ជាដែលគេបង្ហឹកបង្ហាត់ដល់កូនក្មេងទាំងឡាយ ដោយកថាជាគ្រឿងប្រៀប-ធៀប ក៏ជាប់នៅយ៉ាងនោះ ។

៣៦- ការទាំងឡាយតែងសម្រេចដោយសេចក្តីព្យាយាមប្រឹងប្រែងដោយពិត មិនមែនដោយមនោរថទេ ដូចម្រឹគទាំងឡាយ មិនមែនបោលចូលមាត់សីហៈ ដែលដេកលក់ឡើយ ។

៤៥– ដង្កូវ ឡើងទៅទំនៅលើក្បាលសាធុជនទាំងឡាយបាន ព្រោះដង្កូវនោះនៅលាយឡំជាមួយកម្រងផ្កា, ដូចដែលអ្នកធំលើកតម្កើងហើយ ក៏ក្លាយទៅជាភាពទេវតាតូកែសក្តិសិទ្ធ ។

* *

*

## ភាសិតក្នុងសាច់រឿង

១២– ជីវិតរបស់ខ្លួន ជាទីស្រឡាញ់ពេញចិត្តយ៉ាងណា ជីវិតរបស់ជនដទៃក៏យ៉ាងនោះដែរ, លោកសប្បុរសទាំងឡាយតែងធ្វើសេចក្តីមេត្តា ករុណា ព្រោះលោកយកខ្លួនរបស់លោកជាគ្រឿងឧបមា ។

២៣– សេចក្តីក្រោធ ដើមកំណើតមកពីលោភៈ កាមរាគកើតមកពីលោភៈ មោហៈ និង សេចក្តីវិនាសក៏កើតមកពីលោភៈដែរ ព្រោះហេតុនោះ លោភៈជាប្រភពនៃសេចក្តីអាក្រក់គ្រប់ប្រការ ។

២៨– ដោយពិត, ប្រើសមាសមិនដែលកើតមានទេ បើទុកជាដូច្នេះ ព្រះរាមក៏ទ្រង់នៅតែជាប់ព្រះទ័យ ចង់បានប្រើសមាស; រីឯសេចក្ដីអន្តរាយក្នុងកាលវិបត្តិមកដល់ សូម្បីប្រាជ្ញានៃបុរសជាតិ ក៏ត្រឡប់ជាងងឹតងងល់គិតមិនយល់បានៗ

៣៨–ការវេញចងបាច់តែអ្វីមួយ សូម្បីតូចឆ្មារឲ្យរួបរួមគ្នា ក៏អាចញ៉ាំងការងារឲ្យសម្រេចប្រយោជន៍បាន ដូចគេប្រមូលស្មៅវេញជាទន្ទីង យកទៅភ្ជីងដំរីបុះព្រៃ ឲ្យជាប់ពោលទៅណាមិនរួច ។

៤៩– សរីរៈ នឹង កិត្តិគុណ មានចន្លោះតាំងទៅឆ្ងាយពីគ្នាលន្ទង់លន្ទោចណាស់, សរីរៈនេះ រលត់រលាយទៅក្នុងមួយខណៈ ឯកិត្តិគុណស្ថិតនៅរហូតកល្បាវសាន ។

៥៨– ការចងគ្នាជាមិត្ត រវាងអ្នកស៊ី នឹងអ្នកត្រូវគេស៊ី លោកពោលថាជា ហេតុនាំឲ្យវិបត្តិមិត្តភាព ដូចជារឿងប្រើសជាប់អន្ទាក់ ព្រោះចចកបានក្អែកជួយស្រោចស្រង់ ។

៧០– អ្នកនេះជាពួកយើង អ្នកនោះជាពួកគេ នេះជា

សំដីអ្នកមានចិត្តគំនិតស្រាលទេ   ឯអ្នកដែលមានការសិក្សា ច្រើនមានចិត្តគំនិតល្អតែងនិយាយថា អ្នកនៅលើផែនពសុធា សុទ្ធតែជាផៅពង្សនឹងគ្នាទាំងអស់" ។

៩៣– ជាតិលោហធាតុទាំងអស់ រលាយចូលគ្នាបាន ព្រោះដែកមានការរលាយជាលក្ខណៈ ម្រឹគបក្សីទាំងឡាយ រួបរួមចូលជាហ្វូងបាន ព្រោះមានរូបពង្សណ្ឋានជាលក្ខណៈ មនុស្សល្ងង់ រួបរួមគ្នាបានព្រោះមានភ័យនឹងលោភជាលក្ខណ ឯសាធុជនមានមហាគុណ រួបរួមចូលគ្នាបាន ដោយទស្សនៈ-ញាណ ( ស្គាល់ហេតុស្គាល់ផល ) ។

៩៩– បុគ្គលគប្បីសង្កេតដឹង នូវភាពនៃបុគ្គលមានចិត្តអាក្រក់នឹងភាពនៃបុគ្គលពោលនូវពាក្យសច្ចៈ ដោយទីកប្រយោគសំដី, បុគ្គលគប្បីមើលឃើញ នូវភាពនៃបុគ្គលមានចិត្តមិននឹងធឹង នឹងភាពនៃបុគ្គលមានចិត្តប៉ុលប៉ូច ដោយឃើញប្របក្សនឹងភ្នែក ។

១០៣– ការគ្រាន់តែប្រដៅនរជនទាំងឡាយដទៃឲ្យគេ

បានជាបណ្ឌិត នរណាក៏ធ្វើបានឆ្ងាយ តែការទូន្មានខ្លួនឯង ឲ្យប្រព្រឹត្តទៅតាមគន្លងធម៌ជាការក្រ ធ្វើបានចំពោះតែបុគ្គល មានមហាត្ម័ន ។

១៦៩– ទីឋានឆ្ងាយចំនួនមួយរយយោជន៍ មិនមែនឆ្ងាយ ណាស់ណាទេ សម្រាប់បុគ្គលជាខ្ញុំតណ្ហា, ឯបុគ្គលមាន ចិត្តសន្តោស សូម្បីទ្រព្យមកដល់ដៃហើយ ក៏មិនរវល់គើ តើប៉ុន្មាន ។

១៧០– សីហៈ សប្បុរសនឹងដំរី តែងលះបង់ទីឋានមិន ល្អ ទៅរកទីឋានល្អ; តែសត្វក្អែក បុរសគម្រក់ នឹងម្រឹគ នៅស្ងាប់នឹងទីកន្លែងខ្លួន ។

២០១– ម្ចាស់ផែនដី ជាទីពឹងពាក់នៃពលរដ្ឋទាំងឡាយ ដូចជាភ្លៀងជាទីពឹងពាក់នៃសត្វទាំងឡាយ បើភ្លៀងរអាក់ រអួល សត្វលោកអាចញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅបាន តែ បើព្រះរាជាមិនប្រកបដោយធម៌ ពលរដ្ឋរស់នៅមិនបានទេ ។

★

# ច្បាប់វិធុរបណ្ឌិត

## និទ្ទេស

ច្បាប់វិធុរបណ្ឌិតជាច្បាប់បុរាណមួយ ដែលអ្នកនិពន្ធមានបំណងទូន្មានដល់ជនានុជនប្រុសស្រីទាំងឡាយ តាំងពីខត្តិយត្រកូល, អនុជនត្រកូល រហូតដល់ត្រកូលកម្មករ ឲ្យកើតមានគំនិតមារយាទត្រឹមត្រូវ ឲ្យចេះអត់ធ្មត់ក្នុងការប្រកបវិជ្ជាជីវៈផ្សេងៗ ។

### ហេតុអ្វីក៏ច្បាប់នេះឈ្មោះវិធុរបណ្ឌិត

វិធុរបណ្ឌិត គឺតួអង្គតថាគតនេះឯង ៗ កាលពីជាតិមុន, តថាគតជាអ្នកប្រាជ្ញមួយរូបឈ្មោះវិធុរបណ្ឌិត នៅគាល់បំរើព្រះបាទធនញ្ជ័យកោរព្យរាជ នៅក្នុងនគរឥន្ទបត្តបុរី ៗ អ្នកតែងបានយកឈ្មោះអ្នកប្រាជ្ញវិធុរបណ្ឌិត មកឲ្យឈ្មោះច្បាប់ដែលជាស្នាដៃរបស់លោក ដើម្បីឲ្យស្នាដៃនេះមានតម្លៃផង ដើម្បីឲ្យជនានុជននិយម រាប់អានផង ៗ

## វិធីបច្ចេកទេសក្នុងការសរសេរ

ច្បាប់វិធូរបណ្ឌិតនេះ សរសេរជាពាក្យកាព្យបទព្រហ្មគីតិ ៗ វិធីប្រើបទនេះសមរម្យមែន ៗ ដើងកាព្យក៏រណ្ដំគ្នាពីរោះណាស់ដែរ ៗ ពាក្យពេចន៍ទាំងឡាយ សុទ្ធតែមានន័យគ្រប់គ្រាន់ មិនដូចច្បាប់ប្រុសនឹងច្បាប់ស្រី ដែលសម្បូរណ៍ ដោយពាក្យបរិកស័ព្ទនោះទេ ៗ

## ខ្លឹមសាររបស់ច្បាប់វិធូរបណ្ឌិត

ច្បាប់នេះសម្បូរណ៍ដោយគតិបណ្ឌិតជាឧបមានវិធី ៗ វិធូរបណ្ឌិតបង្រៀនមនុស្សខាងផ្លូវចិត្តសាស្ត្រ ឲ្យចេះអប់រំខ្លួនឲ្យប្រពៃ, ឲ្យចេះរបៀបធ្វើការទាក់ទងនឹងសង្គម នឹងឲ្យចេះគិតដល់ប្រយោជន៍ខ្លួន, ប្រយោជន៍ជាតិទៅអនាគត ៗ ច្បាប់វិធូរបណ្ឌិតនេះ គ្រប់ដណ្ដប់ដោយឥទ្ធិពលព្រហ្មញ្ញសាសនាផង ឥទ្ធិពលព្រះពុទ្ធសាសនាផង ៗ

# ច្បាប់វិធុរបណ្ឌិត

(បទព្រហ្មគីតិ)

ព្រះខាន់ហើយឥតស្រោម    នាផ្ទៃក្រោមឥតមន្ត្រី
ក្សត្រិយ៍ពុំចេះគម្ពីរ ស្រីឥតតម្លៃក្រឡា(១)ៗ កើតមកជា
បុត្រក្សត្រិយ៍ ពុំប្រយ័ត្នរៀនសាស្ត្រា ពុំរៀនពិចារណា
ពុំដឹងគ្រងទុក្ខរាស្ត្រ ៗ ពុំដំកើងពាក្យពិត បញ្ចវិធសីល(២)
វិនាស យកគណយកបក្ស កុំយកមាសលាយទឹកប្រាក់ ៗ
ប្រើគ្រាប់ឯគ្រាជ្ញ កុំចង់ផ្លូវដោយតម្រាស់ កុំជិះរទេះចាស់
ញាបសាបខ្សាប់កំបុតត្បូង(៣) ៗ ជាក្សត្រិយ៍ពុំរៀនធម៌ ពុំ
ដោះសាជម្ងឺទ្រង់ រាស្ត្រទាសនឹងបំកោន អាក់ចិត្តខឹងសត្វ
ចោមរោម ៗ នឹងកើតក្ដៅក្រហាយ ទុក្ខអន្តពយកតផ្ទៃ
ក្រោម(៤) រាស្ត្រផងនឹងទីងពោម ជ្រោមខ្ចាត់ខ្ចាយទទៃណាៗ

---

១. គតប្ដី ។ ២-សីលទាំង៥។ ៣.ឈ្មោះខ្សល់កំណាចមួយយ៉ាង ។ ៤.ឥតរ។

វិចិត្តសន្ធ្យាស្នេហ៍ កុំបីប្រែកពាក្យថា ស្រឡាញ់នូវសត្យា(១)
កុំបីស្អប់ឲ្យអាមាទ្យ (២) ៗ អ្នកកាចសរពើក្ត(៣) សឹងអប្រិយ
រំដួលប្រាណ តើទោសអាត្មាមាន គំនូរខុសជាអសារ (៤)ៗ
ទោះជួនព្រះអង្គ សាត់អាត្មាកណ្តាលវាល ពារសឹកដេញប្រ-
ហារ រត់ចេញទៅប្រទះខ្លា ៗ ប្រទះតាំងតាកឈើង សឹង
ជាប់ឡើងទាំអាត្មា ចំរូងប្រូងបន្ទា ជាប់ដោយដើងជាន់ដិត
ដី ៗ ខ្មោចរក្សាគ្រឹះស្ថាន ទោសនឹងមានកូមិលំនៅ បិត
ខ្លួនប្រែក្តាត់ក្តៅ សឹងហ្មងសៅស្មើទោសណា ៗ ទាំងនាយ
ពុំរក្សា បៀនបិណ្ឌាត (៥) ពុំឲ្យថ្កើង អស់ញាតិពុំបន្ទើង
សឹងរត់បៀសចេញទៅឆ្ងាយ ៗ ពឹងថ្ពាល ៗ សោកផាក់
ទូក ពំនាក់ក្តុកព្រាត់ព្រាយ ពឹងបុណ្យបាបកំចាយ សាត់
គឃ្លាយដោយខ្យល់នាំ ៗ កុំឲ្យបង្អាប់ក សូវចុះទឹកក្រពើខាំ
អត់ត្បូនៅសាំទាំ ជាទុក្ខនៅស្មុកស្មុក នៅកើតឯហោចហិន

---

១-ទៀងត្រង់-សច្ចះ ៗ ២-អាក្រក់គួរស្អប់ ៗ ៣-គ្រប់បែបយ៉ាង ៗ
៤-ឥតខ្លឹមសារ ៗ ៥-ព្យាបាទ ៗ

ត្រះមាចក្សីណារឹងអាក្រក់ ។ អំពើដ៏លាមក(១) នូវគេតទោស
ជាសាមាន្យ(២) ។ ដូចពាក្យនៃមនុស្សផង ស្រដីគ្គង់គតប្រ
មាណ ពោលពាក្យពារបំពាន កុំរំពឹងឯក្រោយក្លែក ។
ពានរកុំដែលស្ទគ្រ ស្រីសាពស័ក្តិ(៣) កុំដែលស្រែក រឹងមៀម
នឹងក្អែក កុំដែលរួមទ្រនុំគ្នា ។ ពោះអ្នកជាតិព្រេងព្រឹទ្ធ ចារិះ
គិតបុរាណា គួរបង្ខិតស្នេហា សរពើគិតកើស្តសព្វសាន្ត ។
យកខាលផង់សំណា ដោយចិត្តធគិតឲ្យបាន លាយឯខាល
កាណ(៤) សឹងកុំបានបង់ខាលសោត ។ ប្រទះបោះកាំបិត
បង់សុចរិតនៃអ្នកឆោត ចង់ពីរប្រការសោត ត្រូវដំនៀល
លោកនិន្ទា ។ កុំកាន់ពាក្យអស័ត្យ(៥) ប្រុងប្រយ័ត្នអង្គអាត្មា
ង៉លោកបរលោកា បរិបូណ៌បានសុខសួស្តី ។ កុំពោល
ពាក្យមុសា ពទពចាឲ្យមានហ្មង់ ចំពួកសត្រូវផង តែយក
ទោសនៃអាត្មា ។ កុំពោលពាក្យបំពាន តែងទឹងមានដំនៀលជា

---

១–អាក្រក់ណាស់ ។ ២–មិនគប្បី; គួរខ្ពើម ។ ៣–នើលសុទ្ធល្អ ។
៤–ជាទីគាប់ចិត្ត ។ ៥–មិនមានទៀងទាត់

ឲ្យពិសពិតពុំជា នូវខ្លាសមុទ្រឯងសព្វថ្ងៃ ៗ យកខ្មោចគេ
មកយំ មើលផ្សែថ្នាំព្យាធ៍ហិនហៃ ពុំទីរ(១) ពុំប្រពៃ ពុំបាន
ជាប្រយោជន៍អង្គ ៗ ធ្វើគុណកើតជាទោស យកឈ្មើង
ក្រោសកង់អន្ទង់ យកប៉ុយទៅគ្របភ្លើង គុណប្រណុងអម្បោះ
ផ្កាយ ៗ អណ្ដើកអម្ចាស់មាន ហើនឈ្នានពាន(២) យកស្មារ
ងាយ ក្រូបជូរពុំជូរក្លាយ ពុំប្រយ័ត្នគេយកបាន ៗ ហេតុចិត្តពុំ
គិតថ្លៃ អំពើក្រែតាន់ប្រមាណ អ្នកបួស់យសពីព្រាណ ចិត្តពុំ
ក្បាន្តពុំរសាយ ៗ អ្នកខ្ជិលបង់តែស៊ី អ្នកអប្រិយមើលគេងាយ
រកព្រៃច្រើនផាផាយ(៣) ទ្រព្យខ្ចាត់ខ្ចាយរង្គោះឡើង ៗ ដំរីសារ
(៤)ចូលទៅ ក្នុងអំពៅនោះរលើង ចាំងគុម្ពល្អិតដោយជើង នៃ
ដំរីសារចូលហោង អំពៅអំពល់អស់ រលើងឫសចាំងគុម្ពផង
ចាំងស្រែចំការគ្រង់ បានលំនៅឥតអាស្រ័យ ៗ អ្នកខ្លាច

---

១-ពុំឃ្លាត ពុំឆ្ងាយ ។ ២-មើលងាយ-រំលោភ ។ ៣-ខ្ជះខ្ជាយ ។
៤-ដំរីស្ដ-ដំរីមានមាឌធំ ៗ ។

អ្នកអាងហ៊ាន ស្រដីពនព្លួតជើងដៃ កម្លាំងមានស្មើចៃ ទើបបើអ្នកអាងសាធារណ៍ (១) ៗ រីអ្នកជាទាហាន សៀមនៅស្ពានពុំបបោ សន្សឹមរកស៊ីស្វា លុះសឹកដល់បន្ទឹមាត់ ៗ ដូចស្បែកខ្លាទទូរ សឹងសាយគូគង់ពុំបាត់ កាលស្លាប់គេលះលាត់ លាយយល់ស្អិតដូចដែលហោង ៗ ដូចពុតពាលពុំជា កុំផ្គន្ទាទោសទណ្ឌ (២) ផង ចង់តប់ជាល់រ៉ាយចង់ ពុំបេះពាលពុតបាត់បង់ ៗ ដូចខ្មៀនកន្ទុយក្អែ ទោះនៅប្រែពត់ពុំត្រង់ យកប្រេងទ្ធូនរឹតទង់ រោលក្មេងពត់ពុំត្រង់បាន ៗ ដូចពត់ពាលសក់ឡក់ ចិត្តអាក្រក់ឆ្មើលីកលាន (៣) យល់ធម៌ជំបូន្មាន ចិត្តពុំចូលពុំចង់ស្តាប់ ៗ ទឹកហូរចេញចូលណា ដោយច្បាប់ ជាលោកប្រើគ្រាប់ ជាញាតិសន្តានស្រាប់ គួរបើគ្រាប់អំពើពង្ស (៤) ៗ អ្នកតូចឥតមេត្រី ចង់ជាក្តីមែនខ្នាបង់ ទ្រព្យធន

១-ទូលាយ.ទូទៅ ។ ២—ទោសធ្ងន់ ។ ៣—លិបលស្អាក់ស្មើរ ។
៤— តាមដំណើរវង្សត្រកូល

នាយពុំគន់ ចចបំណង (១) ឯងឲ្យបាត់ ៗ ទោះបើយល់
គេខុស កុំប្រទូស្តប្រទះមាត់ យល់ប្លែកប្រើប្រយ័ត្ន គួរលែង
សាង (២) សេចក្ដីធម៌ ៗ ទោះបើជាតិអ្នកចេះ មានចំណេះ
អាងដឹងគាថា ប្រើជូន់ប្រើដោះសា ដោយសណ្ដាប់ព្រះធម៌
ស្រាយ ៗ រីពាក្យពាលកំឡៅ លុះដឹងជ្រៅដោយបរិយាយ
នាំពាក្យទៅនិយាយ ដើរប្រាប់ប្រាយឲ្យអប្រិយ ៗ អម្ចាស់
អ្នកប្រើទៅ វិលវល់នៅពុំខានក្ដី ស្វែងទ្រព្យសរពើអ្វី អង់
អាលស៊ីទ្រព្យសាធារណ៍ ៗ ប្រើទៅជារាជទូត ចិត្តពុំស្លូត
ល្មើក្រៅសារ ចេះនាំនូវអស់គាថា ជារាជទូតទូរាគម(៣) ៗ ជា
រាជបុរោហិត (៤) រាជបណ្ឌិតគ្រូហោរាធំ ពុំមានប្រព្រឹត្តក្រម
លោកក្រៃលែងអ្នកសាមាន្យៗទោះគេស្រឡាញ់ហោងប្រើចេះ
ស្នងស្រឡាញ់ថ្កាន បណ្ដាលហឫទ័យក្សាន្ត សមស្នេហា
មិត្តមេត្រី ៗ ទោះចេះក្ដីកិច្ចកល បើចេះយល់គាថានោះមិញ

---

១– ផ្ចិតបំណង ។ ២-ស្អាតល្អបរិសុទ្ធ ។ ៣-មកពីឆ្ងាយ ។ ៤-ព្រាហ្មណ៍
ដែលបំពេញប្រយោជន៍ឲ្យនគរ ។

អប្រិយប្រើជៀសចេញ ទូវទីឆ្ងាយឲ្យបាត់ដាន ៗ ពុំគួរយក
ខ្លួនគាប់ គួរតែស្អប់ហេតុសាមាន្យ កុំសេពគាស្រូវច្រុះណា(១)
ពាក្យជំនៀលត្រូវឯក្អែក ៗ កុំយកពងមាន់ផ្ញើ ព្វជំលើសំបុក
ក្អែក អ្នកដាំកុំផ្ញើដែក អ្នកប្រមឹកកុំផ្ញើស្រា ៗ កុំបីយកសំរិទ្ធិ
ផ្ញើអ្នកស្មិតនោះពុំជា រីឯអ្នកចំការ កុំយកគ្រាប់ត្រសក់ផ្ញើ ៗ
ពោះស្រូវគោជន់សាលី ទុកកុដ្ឋី(២)នោះឃាត់ប្រើ កុំមាន
ចិត្តសើរើ យកមកផ្ញើនៅផលស័យ ៗ បញ្ញើបួនប្រការ
ពិចារណាឲ្យអស់ក្តី កុំមានពាក្យអប្រិយ ខ្លាចចំណោរជំ
នៀលថា ៗ កាលក្អែកចេញស៊ីលុះ រាត្រីនោះមៀមគោត្តា
មានសឹករកសា(៣)ទៀបគាត្នាកុំឃ្លាតឆ្ងាយ ៗ ទឹកឡើង
ស្រមោចលង់ លុះចំណាន់ត្រីសប្បាយ ស្រមោចក៏អន្តរាយ
លុះចំណោរចំណាប់ល្អ ៗ លុះទឹករីងស្ងួតទៅ ត្រីផង់នៅអាត្មា
មរណ៍ អនេកអនន្តរ លុះចំណោរស្រមោចស្នួន ៗ នេះមាន
ពៀររើក ពីបុកបុកណាហោង សត្វស្ថានពុំគង្វង់ ហេតុចំណង

១-សៅហ្មងផិលខ្លួន ។ ២-នាយទុន កសិកម្ម ។ ៣-រកទីពឹងរកជំនួយ ។

តាំងពីព្រេងព្រឹទ្ធ ៗ បានផុតបទពាំង បានជាក្ដីបទបិត្តឯង ហេតុ
ចិត្តវៀចវង្វេង បង់ទ្រព្យឯងមិនបិត្តស្រាល ៗ រអែកខ្ជិញខ្ជិល
ខ្សោយ កុំបីឲ្យកាន់នូវការ ពាលាអន្ធពាល(១) កុំឲ្យធម៌
ឥតចិត្តបង់ ៗ ទោះបានសត្វបក្សី ប្រក្រតីតិច(២) ស្លាប់
បង់ រក្ដីជនសត្វអគ្គិ ប្រើគិតផ្សងគំនិតច្បាប់ ៗ ប្រើត្រាប់ឯ-
គាំងយូ ក្រឯត្រូតុំគួរត្រាប់ កុំយកមួយកណ្ដាប់ ជាមួយនឹង
កំបង់ដៃ ៗ កុំយល់សសោភា កុំបីថាជាខ្ញៅក្រែ បន្ទិចនេះ
ប្រពៃ គួរត្រាប់កុំបីភ្លេចឡើយ ៗ ទោះបីជីវិតបាត់ លោកប្រើ
ស្កាត់ពាជាត្រើយ តាមនឹងដំរើហើយ កុំបីដើរទឹងដើងណា ៗ
ទោះទូកជាប់សាត់សោះ យកទូកស្ទោះទៅតាមគ្នា នេះ
ពាក្យព្រេងលោកថា ទុកជាច្បាប់ដំពប់គ្រ ៗ រអែកមាន
ប្រាជ្ញា សង្សារ(៣) យល់តុំថេរ(៤) ទុក្ខសោកភ័យចំណោរ
ប្រើផ្ដាច់ផ្ដិលនិពសស្ពាន ៗ ស្រុកមានសឹកកុំបី ទៅជួញខ្ញី
រកធនធាន រំខូនគំព្រាប្រាណ ក្រវក្សានូវមាសប្រាក់ ៗ ទោរ

---

១-កាច ឥតិតឥងលំ ។ ២-ពម្ចា គ្រប់ពេល ។ ៣—ការកើតស្លាប់ ។
៤-ពុំមានគង់វង្ស ។

ឃ្មុំចាំថែប្អូន ឥតដំបន់ណាទីណាក់ ខ្លួនឯងឥតបើជាក់ សរពើទ្រព្យបាត់អស់ឯង ៗ ដំបន់ទីជ្រៅ(១) កុំងូតនៅ ម្នាក់ឯងលេង ទឹកហូររំពងត្រែង កុំបីភាលចុះទូកក្តូង ៗ ក្រពើ ក្រពេញពាំ សាហាវចាំសត្វព្រៃកផង ចាប់ដោយបំណង បីដូច ខ្យល់ទឹងភ្លើងព្រៃ ៗ ដំរីគជសាធំ ឧត្តរដំជាញផល់នៃ ប្រើរត់ ជៀសចេញវៃ កុំយកខ្លួនទៅទប់ទល់ ៗ កម្លាំងតិចពិតអត្ត ឯងជាអ្នកឯណាយល់ ទើបបានខ្លួនអំពល់ លុះទៅដល់អាត្ត មរណ៍(២) ៗ ព្រះធម៌នេះជាច្បាប់ ប្រសើរគាប់ឲ្យអស់នរ អ្នកផងចាំបានបវរ បូរណ៍ដល់ត្រីពិធសួគ៌(៣)ៈឋាន ៗ

ចប់

---

១-ផ្លូវទឹក ព្រែក ទន្លេ ស្ទឹង ។ ២-ដល់ស្លាប់ខ្លួន ។ ៣ ស្ថានសួគ៌៣ជាន់ ។

# ច្បាប់ទូន្មានខ្លួន

## បទព្រហ្មគីតិ

មនុស្សគោចកុំប្រសព្វ កុំទៅគប់នឹងចោរឃ្លើយ គេចាប់ចងទៅ
ក្រោយ វាយបណ្ដើរយល់អប្រិយ(១) ៗ កុំគប់នឹងខ្ញុំគេ កុំ
ប៉ៅខ្សែខ្វល់នឹងស្រី កុំជួញនឹងមន្ត្រី នឹងខាតទុនជនឯង
ហោង ៗ កូនអើយអាត្មាកបា នឹងឧបមាមួយទៀតហោង
ចាស្ដាប់គ្រាប់គ្រងរង ទុកទូន្មានអង្គឥន្ទ្រិយ(២) ៗ គេដើរកុំ
អាលបាញ់ បើស្រឡាញ់កុំឲ្យខ្ពុ សូវឲ្យស្មោះទៅនៃ នៅគង់
ជាក្ដាយើនយូរ(៣) ៗ សូវចូលកុំឲ្យចេញ សូវឲ្យទិញកុំឲ្យដូរ
សាប់ញាតិឲ្យប្រមូល កុំស្រដីពាក្យសល់វល់ ៗ មនុស្សគោចកុំបី
ប្រើការ ក្រធ្វើកុំឲ្យយល់ ថែកទានកុំឲ្យសល់ ពាក្យបញ្ឆោះ
កុំឲ្យមាន ៗ ពាក្យខុសកុំឲ្យស្ដាប់ សេចក្ដីគាប់ឲ្យគិតញាន អំពើ
បាបកុំឲ្យមាន សីលនឹងទានឲ្យរះគិត ៗ សីលសោតគួរគេក្សា ខ
ប្រាថ្នាឲ្យបានជិត ពិណុកឲ្យគន់គិត រកគំនិតគិតឲ្យដល់ ។ ស្អប់

១-មិនជាទីស្រឡាញ់ ។ ២– កាយ ។ ៣- ស្រឡាញ់ទៅយូរយារ ។

គេកុំអាលថា មានគ្រាផ្កាឲ្យបេះសល់ ពាក្យគួរស្តាប់គួរធ្វើ មានគន្លល់កុំអាលថែន(១) ។ ពាក្យក្រកុំអាលប្រាប់ ពាក្យឥតស័ព្ទ(២) កុំអាលថ្លែង ពាក្យពិតកុំឲ្យថែង ពាក្យពិតថ្លែងកុំគួរលាក់ ។ គេប្រាប់កុំអាលគ្រោង គេបញ្ឆោតកុំអាលភ្ញាក់ សឹកដេញកុំអាលបាក់(៣) គ្នាជំពាក់ប្រើដោះសា ។ គេវត់កុំអាលដេញ គេលើកបញ្ចេញកុំអាលថា សឹកដល់កុំអាលផ្ចា(៤) ពួកបាកុំអាលយក ។ គេប្រើកុំអាលទៅ គេឲ្យហៅកុំអាលមក គេឲ្យកុំអាលយក គេសង្ស្រក(៥) កុំអាលថយ ។ ខ្លួនតូចកុំខំពារ ខ្លួនអ្នកជាកុំគិតឆ្ងាយ ឲ្យគិតក្រែងក្រក្រោយ ខ្លួនខ្សត់ខ្សោយឲ្យបាវម្ភ ។ ទំនៀមទំនឹមព្រេង ច្បាប់ថាថ្លៃងដោយក្រិត្យក្រម(៦) ពាក្យនេះជាឧត្តម(៧) ចូរបាខំ ៗ គ្រង់គ្រាប់ ។ សង្វាតរកស៊ីបុក ជួញលក់ទិញតាមច្បាប់ ខ្សត់គ្មានឃ្លានស៊ូស្លាប់ កុំខុសច្បាប់ព្រះធម្មា ។ មានទ្រព្យផ្សិតសំណាង ជាតិមុនសាងទានសីលា ទើបកើត

---

១-កុំអាលនិយាយ ។ ២-ឥតន័យ ។ ៣-ទ័ពយកដល់កុំអាលរត់ ។ ៤-កុំអាលរោភ ។ ៥-ស្រែកសន្ធាប់ឲ្យភ័យ ។ ៦-ច្បាប់មានកំណត់ ។ ៧-ខ្ពង់ខ្ពស់ ។

ជាតិនេះណា មានទ្រព្យធនដ្បិតទានគេ ៗ បើខ្លួនមានសក្តិ
បុណ្យ បានទ្រព្យធនខ្ញុំពលរេហ៍(១) ធ្វើចិត្តឲ្យត្រង់ត្រែ ជាតិ
ទៅមុខទើបបានទៀត ៗ ស៊ីបាន ៗ ទើបខំ លោភល៉យដំគេ
បៀនបៀត បំបាត់ទ្រព្យគេធ្វៀត ខុសច្បាប់ផងមិនទេឡើយ ៗ
ល្អតែទៅលោកិយ លុះក្ស័យជីវិតហើយ ដល់ទុក្ខពុំដែល
ស្បើយ រូបវែងរធកម្មវេទនា ៗ ព្រះទ្រង់ទេសនាមក គួរតែ
យកទុកសិរសា(២) មនុស្សសត្វផងក្តីណា ពុំដែលវៀរ(៣)
ពីក្តីស្លាប់ ៗ គួរតែសាងសីលទាន នោះទើបបានបុណ្យ
លាងបាប រក្សាសីលដរាប នោះប្រសើរពេកកូនអើយ ៗ
អស់ទ្រព្យសម្បត្តិនៅ មិនបានទៅតាមខ្លួនឡើយ មានតែ
សីលទានហើយ ទៅកំដរបរលោក(៤)នាយ ៗ អស់ទាំង
គ្រឿងរបស់ ខ្ញុំស្រីប្រុសផងទាំងឡាយ សឹងខានទោល
នៅអាយ ជារបស់គេរស់នៅ ៗ គួរដឹងរិះគិតច្បានគួរឲ្យ
ទានធ្វើបុណ្យទៅ ទាន់ខ្លួនជីវិតនៅ នោះប្រសើរពេក

១ ពួកពល។ ២ទុកលើក្បាល។ ៣ពុំដែលជៀសផុត។ ៤លោកខាងនាយ ភព។

ណាកូន ៗ បើបានធ្វើតែបាប មិនសុភាពចិត្តកាចលន់ ធ្វើ
បាបមិនធ្វើបុណ្យ លែងជាតិ(១) ទៅនៅនរក ៗ បើបា
បានធ្វើបុណ្យ បានសងគុណម្តាយឪពុក ឲ្យទានចាំសីល
សុខ នោះទឹងបានឋានសួគ៌ា ៗ ខ្លួនធំទំរកស៊ី ចាស់ព្រឹទ្ធ(២)
ត្វរអនិច្ចា(៣) កើតជាមនុស្សនេះណា មានវេរ(៤) ពុំដែលរួច
មួយសោតកុំស្នេហ៍ស្និទ្ធ កុំមានចិត្តគិតកាញ់ក្លួច ភរិយាគេ
កុំលួច នៅលោកិយក្ដីទិន្នា(៥) ៗ ដល់ខ្លួនលែងជាតិនោះ ទឹង
ចូលចុះនរកណា ទឹងឡើងដើមរកា ដែកនោះធំៗខ្ពស់ក្រៃ ៗ
យមបាលរត់ទៅជ្រោម កាន់គ្រឿងពោមបាក់ទំពែ(៦) ក្អែក
ត្មាតទំដើងដៃ បចឹកស៊ីជាអាហារ ៗ មានខ្លួននោះដាចដាច់
អស់ទាំងសាច់ឈឺខ្លោចផ្សា វាត្រូវទឹងបន្ទា សឹងជាដែកមុត
ធ្លាយធ្លុះ ៗ ហើយធ្លាក់ពីបន្ទា ដើមរកាដែកធំនោះ ធ្លាក់
ចុះក្នុងទឹកខ្ទះ ប្រែផ្សាក្ដៅឥតសម្រាន្ត(៧) ៗ ហើយវែលកន្ទ

---

១-ផុតពីជាតិនេះ ។ ២-ចាស់ទុំ ចាស់អាយុច្រើន ។ ៣-មិនទៀង។ ៤ ពៀរ កម្មពៀរ ។ ៥-ពាក្យគេនិយាយដើម ។ ៦-បាក់គ្រប់ ។ ៧-ឥតបានស្រួល ។

ទឹកនោះ ស្ងាប់ហើយលំបាកព្រាណា ពីរពាន់ឆ្នាំទើបបាន រូប
មកកើតជាមនុស្សៗ រូបនោះបានមកកើត យកកំណើតមនុស្ស
នេះណា ហេតុកម្មពៀរវេរកើតជាស្រីប្រាំរយជាតិ ៗ រូបនោះ
ជាខ្ទើយ ក្ដួនចៅអើយកុំប្រមាទ(១) កិរិយាគេមិនឃ្លាត ពីន-
រកនោះឡើយណា ៗ មួយសោតឪពុកម្ដាយ ចូរបាចាំកុំផឹកស្រា
វាំនាំចិត្តពាលា ពារោលលន់ពន់ពេកក្រៃ ៗ ផឹកស្រាជាអ្នកកាច
ពុំក្រែងខ្លាចអ្នកដទៃ វាំនាំបាត់ស្មារតី ទីងទែងស៊ុបាត់ប្រាជ្ញា ៗ
នៅនាលោកិយហោង អស់អ្នកផងគេនិន្ទា លុះខ្លួនជួនមរណា
ទៅនរកនឹងទុក្ខនៅ ៗ នៅតែរងវិបាក(១) ខ្លួនលោកនឹង
ដែកក្ដៅ អស់ថ្លើមប្រមាត់នៅ កង្វពង់ពោះឈឺពន្លឹក ៗ ដែក
ក្ដៅឆេះជាភ្លើង ផ្សែងផ្សប់(៣),ឡើងព្លុគពឹក យមបាល(៤)
សោតបំផឹក ទឹកទង់ដែងឆេះព្រោងព្រាយ ៗ ពាក់កទាញផ្ដេក
ផ្ងល ទីងបង្ដោលដែកតាំងឡាយ មាត់នោរឆេះព្រោងព្រាយ
ហេតុបាបបានផឹកសុរា ៗ ពាក្យនេះមិនថាឯង មានពីព្រេង

១កុំប្រហែស កុំមើលងាយ។ ២ផលអាក្រក់។ ៣ផ្សែងហុំឡើង។ ៤អ្នករក្សានរក។

ព្រះទេសនា អ្នកណាបរទារករ(១) សេពសុរាផ្តូរប្តេះនៃ ៗ
គិតគួរឲ្យចាំ សីលនានាំឲ្យល្អនៃ រៀនធម៌គម្ពីរថ្លៃ បាន
រៀរបាបផងនានា ៗ ហៃអស់កូនចៅអើយ ចាំឲ្យហើយធម៌
ទេសនា អ្នកមិនផឹកសុរា អ្នកនោះបានស្ថានសួគ៌ហោង ៗ
រកស៊ីគិតពិតក្តី គិតលោកិយបរលោកផង ក្រែងខ្លួនជួនមក
ហោង ផលជួយជួនបានសុខា ៗ ច្បាប់នេះព្រះបន្ទូល
គួរតែចូលចិត្តគ្រប់គ្នា ទូលទុកលើសិរសា កុំបីភ្លេចផល
មួយថ្ងៃ ៗ ថ្ងៃសីលគេផ្កាក្រី ទៀនធូបក្តីផ្សំព្រមផង
ថ្វាត់ថ្វាយព្រះរត្នត្រ័យ(២) កុំបីដាច់ថ្ងៃ មួយឡើយ ៗ
អ្នកណាអាចបានស្តាប់ ត្រេកត្រង់ត្រាប់ ធម៌ជាត្រើយ
កុះលែងជាតិទៅហើយ នោះនឹងបានស្ថានសួគ៌ា ៗ ទោះ
បីបានមកកើត យកកំណើតជាតិនេះណា ប្រកបដោយ
ប្រាជ្ញា អង្គកាយាល្អប្រិមប្រិយ ៗ កើតក ទ្រព្យរបស់ ខ្ញុំ
ស្រីប្រុសគោក្របី មាសប្រាក់ឥតខ្វះអ្វី មានខ្ពូកក្តារប្រាក់

១-ការលួចប្រពន្ធអ្នកដទៃ ២-កែវជាទីពឹងទាំងបី គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ

ហោង ៗ មានកេរ្ដិ៍កោះស្រែស្រូវ ចេកអំពៅជូនស្វាផង នោះ

ច្រើនៗ ពេកហោង សឹងលើសលន់ពន់ប្រមាណ ៗ ពាក្យ

នេះស្មើខ្លួនហើយ គួរចៅអើយចូរចាំប្រាណ អស់អាថ៌ឥឡូវ

(១)ពាន ជាស្ងួរេច(២)បណ្ដាំហោងៗ ចូរចាំចូររៀនយក ជា

ពន្លកចិត្តចាំចង ស្មើស្ពានចាំចំឡង ទៅដាក់ដល់ថ្កល់និព្វានៗ

ចប់

---

១ ពាក្យក្រៀនប្រដៅមានន័យក្រាលត្រៅ ។ ២-ជាស្រេច ជាសំរេច ។

# ប្រាប់ពាក្យចាស់

## បទព្រហ្មគីតិ

ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសល់ មើលយល់ប៉ុនផាំងភ្នំ ៗ ចូលព្រៃ
សត្វសាហាវ(១)រកអំពាវ(២)គ្នាមកជុំ ដល់បានសត្វទឹកឃ្មុំ
ពួនសម្ងំស៊ីម្នាក់ឯង ៗ បានហើយចង់បានទៀត ឆ្លៀត
ហើយឆ្លៀតពុំគិតឈ្លង(៣) មើលយល់តែខ្លួនឯង មិនយល់
គេឯទៀតផង ៗ ទឹងស៊ីបង់ពិសា ខ្វល់ចំពោរឲ្យម៉ង្ឈហ្វង
យល់នាមថាជាមង(៤) យល់ឯដងថាជាគួយ ៗ យល់តាថា
ជីដូន យល់ឯកូនថាជាក្មួយ យល់ឯព្រួយថាជាសុខ ៗ
យល់ទោសថាជាគុណ យល់ឯបុណ្យថានរក យល់ល្អថា
អាក្រក់ យល់លាមក(៥)ថាជាផ្កា ៗ ស្លៀកស្បង់មិនគោរសក់
ធុះកញ្ចក់ឈ្លបនេត្រា យល់សេះថាជាលា យល់គជា(៦)ថា

---

១-សត្វកាច ។ ២-រកហៅគ្នីគ្នា ។ ៣-គិតឲ្យយល់វែងឆ្ងាយ ។ ៤-តាមទឹងមង ជាឈ្មោះប្រដាប់នេសាទ ។ ៥-អាចម៍ ។ ៦-ដំរី

កណ្ដុរ ៗ នេះពាក្យលោកពីព្រេង អ្នកណាឈ្លាសប្រាជ្ញា
យល់ ឃើញថ្លុកកុំថាថ្នល់ ក្រែងកំហល់កំហុសមាន ៗ អ្នក
ប្រាជ្ញកាន់ពាក្យទៀង កុំលំអៀងពាក្យបុរាណ កុំដើរផ្លូវបំ-
ពាន ពាក្យអ្នកចាស់លោកដៀលថា ៗ ពាក្យនេះពីព្រេងព្រឹទ្ធ
ត្រូវឲ្យគិតពិចារណា កុំអួតអង្គអាត្មា ជាចំណេះចំណាំមាន ៗ
ដេកយប់កុំដេកយូរ ខ្លាចក្ដីទុជ្ជន(១)ដល់ប្រាណ បើស៊ីកុំតាម
ឃ្លាន គិតប្រមាណគ្រប់គ្នា ៗ លើកដាក់តាមកម្លាំង កុំ
កើបខ្លាំងឈឺដល់ស្មា បើគេប្រើឲ្យត្រា កុំស៊ាំសឹន(២)នរពៅ
ពៅ(៣) ៗ ទោះគិតកុំរួសរាន់ គិតឲ្យគ្រាន់ ទើបដើរទៅកុំឲ្យ
មានអាស្រូវ កើតជំនៀលដល់អាត្មា ៗ កុំយកឆ្អិនជាឆៅ កិច្ច
កុងក្រៅមានតម្រា កុំអាងឯងប្រាជ្ញា ចោលច្បាប់ក្បួនលោក
ព្រេងនាយ ។ ស្រដីឲ្យស្រួលស្រេច គិតសេចក្រេច(៤) កុំ
គិតឆ្ងាយ រំពឹងឲ្យវែងឆ្ងាយ យល់លៃផ្ដុក(៥) ពាក្យលោក
ថា ៗ ពាក្យព្រេងលោកស្រដី ថាកុំបីបីញ៉ូមខ្លា ពាក្យ

១-មនុស្សអាប់ទន ។ ២-សាញស្លាក់ស្ទើរក្នុងចិត្ត ។ ៣-ប្រញាប់រួសរាន់ ។
៤-សេចក្ដីកិច្ចការ ។ ៥-បន្ទោះពេល ។

ព្រេងលោកឧបមា គិតត្រង់ណាធ្វើឲ្យបាន ។ កាន់តពស់ឲ្យ
ខ្ជាប់ ខ្លាចក្រឡាប់ខាំងប្រាណ គួសទូកកុំឲ្យល្អាន(១) ទឹក
ថ្លាសោតកុំឲ្យល្អក់ ។ ស្ទូកឈើឥតកំរើក បើកគ្រើកផ្សិតខ្យល់
បក់ ទឹកថ្លាល្អឹក(២)បើល្អក់ ផ្សិតរលកខ្ទាំងសោះសា(៣) ។
យល់តួបត្រូវខិតខំ គួរសន្សំយកជាគ្នា បានច្រើនកុំចំពារ
សន្សឹមគ្រៀណតិច ៗ ទៅ ។ អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធ
ពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន ។ អ្នក
ខ្ពស់រក្សាទាប ដោយសភាពធម៌បុរាណ អ្នកឆ្អែតរក្សាឃ្លាន នា
អ្នករុងរក្សាធ្លា(៤) ។ រក្សាទៅមករឹង(៥) ឥតកុំដឹង(៦)អស់អម្បាល
(៧) បំណោរចិរកាន់កាល(៨) ដូចរបងស្រាស់បន្ទា ។ កុំ
ឆ្អែតពេកតែឯង មិនគិតក្រែងអស់គ្នីគ្នា គេឃ្លាន ។ ផ្ដុំផ្សា
ឲ្យស៊ីក៏បានឆ្អែតផង ។ កុំមានចិត្តលលើ ពឹងក្រពើឲ្យចម្លង

១-កុំឲ្យមានជាន ។ ២-កាលណា ។ ៣-ខ្ទាំងក្រៃលែង។ ៤-អ្នករុងរឿង។
៥-អ្នកក្រខ្សត់ ។ ៦-ទៅវិញទៅមក ។ ៧-បំណុល ។ ៨-ទាំងអស់
នេះ ទាំងប៉ុន្មាន ។ ៩-គរទៅអស់ពេលដ៏យូរ ។

កុំកាច់ទុសរបង៏ រាំងចំណារឯអាត្មា ៗ មានទុក្ខហើយមាន
ថ្កោល មានបង្គោលមានយុថ្កា ទាំងពួរទាំងប្រាក់ ក្រជីន(១)
ហាប់ដោយនូវគ្រប់ ៗ ប្រយ័ត្នក្រែងព្យុះខ្យល់ បក់បោក
ដល់ទឹងទល់ទប់ ប្រយ័ត្នប្រយោជន៍គ្រប់ ទើបហៅជាតិជាក-
ណើត ៗ ពាក្យព្រេងគិតគួរចាំ ជាបណ្ដាំប្រដៅគ្រប់ ពាក្យ
ព្រេងពាក្យព្រេងព្រឹទ្ធ មុខគួរគិតៗ ឲ្យគ្រាន់(២) ៗ ពាក្យនេះ
ជាសណ្ដាប់ ទុក ជាច្បាប់ទៀងជាក់ស្ពាន់ ពាក្យនេះជាកំ-
ណាន់(៣) កំណត់នៅឥតឃ្លាតឃ្លា ៗ សូមបន្ទូវនិទាន
ពាក្យទូន្មានដោយប្រការ អម្បាលនេះឯងណា ចាំទុកកាយ
គ្រប់គ្រាន់ហោង ៗ

ចប់

---

១— ចែរសំរាប់ចែរចាយក្រោយ ។ ២— គឺឲ្យគ្រប់គ្រាន់ ឲ្យសព្វគ្រប់ ។
៣— ការប្រកាន់ជាប់ក្នុងចិត្ត ។

# ច្បាប់ត្រីនេត្រ

## ជីវប្រវត្តិរបស់អ្នកនិពន្ធ

អ្នកតែងច្បាប់ត្រីនេត្រ គឺព្រះបាទស្រីធម្មរាជា (ព្រះរាជ-សម្ភារ) ឬហៅថាព្រះពញាតូ ។

គ.ស·១៦·០១- ទ្រង់ប្រសូតិ នៅស្រុកល្វាឯម, ខេត្តកណ្ដាល ។ ព្រះមាតាជារាស្ត្រសាមញ្ញ, គឺព្រះនាង «សុខ» ឯព្រះបិតា គឺព្រះបាទជ័យជេដ្ឋាទី ២ ជាក្សត្រគ្រងរាជ្យ ។ កាលនៅកុមារព្រះនាម «តូ» ។

គ.ស. ១.៦២២- ទ្រង់បំពេញព្រះផ្នួស, សំណាក់នៅកុដិរបស់ព្រះសុគន្ធាធិបតី, បានរៀនព្រះត្រៃបិតក បេះចាំយ៉ាងចំណាន ។

គ.ស· ១.៦២៣- ចាកសិក្ខាបទ (សិក្ខមកកាន់ភេទជាគ្រហស្ថវិញ) ។

គ.ស. ១.៦២៩– ទ្រង់ឡើងសោយរាជសម្បត្តិ ហើយ ទ្រង់យាងទៅគង់ឯកោះឃ្លោក ។

គ.ស. ១.៦៣៤– ទ្រង់សោយទីវង្គត ដោយត្រូវ "គ្រាប់មាស" របស់បច្ចាមិត្តគឺព្រះបាទឧទ័យរាជា ដែលដណ្ដើមយកព្រះនាងបុប្ផាវតី ពីព្រះហស្តព្រះអង្គ ។ ព្រះស្រីធម្មរាជា ទ្រង់សព្វព្រះរាជហឫទ័យ នឹងអក្សរសាស្ត្រណាស់ ។ ព្រះអង្គទ្រង់បាននិពន្ធ ក្បួនច្បាប់ជាច្រើន ដូចជា ច្បាប់ក្រីនេត្រ, ច្បាប់ក្រម, ច្បាប់ព្រះរាជសម្ភារ, កំណាព្យសរសើរ ហេមន្តមាស, កំណាព្យពារនៅចុងត្នោត, លិខិតស្នេហា ។

# និវេទន៍

## ស្ថានការណ៍ក្នុងប្រទេស

បន្ទាប់ពីការធ្វើសង្គ្រាមតទល់នឹងកងទ័ពសៀម, គឺក្នុងចន្លោះពេលសម្រាកចំបាំង, ប្រជារាស្ត្រខ្មែរមានទុក្ខវេទនា, មានវិបត្តិខាងផ្លូវគំនិត និងផ្លូវច្បាប់ ៗ ហេតុដូច្នេះហើយបានជាច្បាប់ក្រម និងច្បាប់ត្រីនេត្រ របស់ព្រះស្រីធម្មរាជា ត្រូវបានអ្នកស្រុកកាប់អានយ៉ាងខ្លាំង ៗ គេគោរពច្បាប់ទាំងនេះ, ហើយគេតម្កើងច្បាប់ទាំងនេះថាជារស្មីដឹកនាំរាស្ត្រប្រជា ៗ

## វិធីបច្ចេកទេសក្នុងការសរសេរ

ច្បាប់ត្រីនេត្រនេះ, ព្រះស្រីធម្មរាជាទ្រង់បានសរសេរជាពាក្យកាព្យ-បទកាគតិ (ពាក្យ ៤) ៗ របៀបប្រើបទនេះ ឃើញថាសមរម្យណាស់ ៗ រីឯពាក្យពេចន៍សុទ្ធតែមានន័យជ្រៅជ្រះឥតខ្ចោះ ៗ ចំណែកខាងវិធីចាប់ជួនក្នុងកំណាព្យមានការខុសឆ្គងជាច្រើន ដោយមានព្យាង្គលើស

ទិនពាក្យខ្លះ ហើយជួនកាលបាត់ទាំងឃ្លាៗទៀតផង, តែ។ កំហុសនេះ ប្រហែលជាកើតឡើងអំពីអ្នកចម្លងតៗគ្នាក្រោយមកទៀត (?) ព្រោះ, បើតាមយើងយល់, ព្រះស្រីធម្មរាជា មានថ្វីព្រះហស្តខ្លាំងណាស់ ខាងកំណាព្យកាព្យឃ្លោងក៏ដូចជាខាងភាសាក្នុងពាក្យរាយធម្មតា, ព្រោះព្រះអង្គជាអ្នកប្រាជ្ញខាងពាក្យសំដី និងអក្សរ មានអក្សរសំស្រ្កឹតបាលី ជាដើមៗ

ខ្លឹមសាររបស់ច្បាប់ត្រីនេត្រ

គោលបំណងរបស់ព្រះស្រីធម្មរាជា ក្នុងការសរសេរច្បាប់ត្រីនេត្រនេះ គឺទូន្មានដល់វណ្ណៈខ្ពស់ទាំងឡាយ មានខត្តិយត្រកូល រហូតដល់ក្សត្រសោយរាជ្យ ៗ ខ្លឹមសាររួមគឺ ៖

— បំពត់ចិត្តឲ្យបានល្អ
— អប់រំគ្រួសារឲ្យបានប្រពៃ
— ការពារទឹកដីឲ្យបានគង់វង្ស

ព្រះស្រីធម្មរាជាទ្រង់សរសេរដល់ ព្រះរាមា (ក្នុងរឿងរាម-

គេរ៏ដ ) ដែលបានផ្ដាញ់អសុរទាលវៃតវិនាសអស់ ដើម្បីយកនាងសិតា មកវិញ ។

ត្រង់នេះបញ្ជាក់នូវការឈឺចាប់របស់ព្រះស្រីធម្មរាជា បំពោះព្រះបិតុលា ( ឪពុកមា ) គឺព្រះឧទ័យ ដែលបានដណ្ដើមយកនាងបុប្ផារតីពីព្រះអង្គ, ក៏ប៉ុន្តែក្នុងរឿងដែលនេះក៏មានន័យថា „ គប្បីយើងដណ្ដើមយកឲ្យបានមកវិញនូវអ្វីមួយដែលជារបស់យើង ហើយដែលបរទេសបានដណ្ដើមយកទៅពីមុននោះ ” ។

# ច្បាប់ត្រីនេត្រ

បទកាកគតិ

បពិត្រមហារាជ(១) ទ្រើសទ្រង់អំណាច អញ្ជើញ
ស្ដេចស្ដាប់ ទំនឹមទំនង នេះហោងជាច្បាប់ ទុកជាសណ្ដាប់
នៃនរជនជាតិ ៗ នរអ្នកណា នឹងចូលទៅជា វររាជអមាត្យ
សេនាមន្ត្រី ករី(២) ជាគាថ រៀនច្បាប់ជាខ្នាត តែងទុករៀង
ទៅ ៗ បំរើព្រះបាទ ព្រះបរមនាថ(៣) អធិរាជបមបៅ
ឲ្យសមឲ្យល្មម នឹងក្សត្រានៅ ឲ្យឡើងគាល់ហៅ អ្នកជា
អម្ចាស់ ៗ មួយនោះព្រះអង្គ ក្សត្រាទ្រើសទ្រង់ គ្រង់ផ្ទៃ
ក្រោមគ្រាស់ គួរមាននមនោរម្យ សុខសោមនស្ស រៀនឲ្យ
ច្បាស់លាស់ គ្រង់ច្បាប់នេះណា ៗ អស់មុខមន្ត្រី ដោយ
ព្រះបាលី នាសតិកាជា បើមុខមន្ត្រី ពុំពិចារណា នឹងក្សីណា
ក្សត្រា ពុំថែងឡើយនៃ ៗ ដ្បិតមុខមន្ត្រី សេនាបតី ពុំ
ដោយគន្លង លោភោចង់បាន បំពានក្រស្ដផង ក្រស្ដីក្ដៅ

---

១—ស្ដេច, ស្ដេចធំ ។ ២—អ្នកតែងពាក្យឃ្លោង ។ ៣-ប្រសើរ, សម្រើប ។

ហោង អង្គឥតអាស្រ័យ ៗ ក្សត្រដូចមច្ឆា មន្ត្រីសេនា ដូចគង្គានៃ បើប្រែជាក្តៅ ក្រៃក្រៅវិស័យ ក្សត្រខឹងកើតភ័យ អង្គឥតពុំទាក់(១) ៗ មន្ត្រីយោធា បីដូចព្យគ្ឃ្រា ខឹងពស់ពន្លាក់ អស់អ្នកផង ចូលទៅពឹងពាក់ ក្បែរណាប្រែជាយក្ខ យង់ឥតករុណា ៗ មួយគុបត្ត នាសតិគុលិ៍ បទបន្ទូថា បើមានកូនកាប កំណាចហើយណា សង់វិនាសព្រា កដតី សន្តាន ៗ មួយគុម្ភ៍ នាសតិធំ វិនាសធនធាន នៅភូមិអាក្រក់ នោះទ្រង់កើតមាន ព្យាធិបៀតប្រាណ ពិតពុំប្រពៃ ៗ មួយគុគេហ៍ នាសតិវិដ បន្ទូនេះនៃ នៅផ្ទះអាក្រក់ ទ្រង់កើតហិនហៃ ប្រាជ្ញាញាណព្រៀយ អាប់ឥតមង្គល ៗ កើតកេរ្តិ៍អាប់យស ដោយទូវពាក្យមនុស្ស គេដើរមកយល់ ហើយគេខឹងថា ផ្ទះអាក្រក់សល់ កើតអពមង្គល(២) ដោយពាក្យគេថា ៗ

ឯមុខមន្ត្រី ដោយអាថ៌បាលី វិញ្ញូភាជា បើមុខមន្ត្រី មែនមានប្រាជ្ញា ដឹងអត្ថា-ស្រ័យគ្រប់ប្រការ ៗ តម្រង់មហា

---

១-តឹតទ្រីពឹង ៗ ២-សេចក្តីអាក្រក់, គ្មានសិរីសួស្តី ៗ

ក្សត្រ សោយរាជសម្បត្តិ គ្រមក្រុងគគពគារ អស់ក្រស្ត្រ មណ្ឌល សកលបរិពារ សឹងឥតគ្រោល ដល់តិចឡើយ ហោង ។ ឯសុបុត្តំ វៀរិកុលំ ថាបើកូនផង មែនមានគំនិត ល្អឥតឯងហ្វង សឹងចំរើនបង់ បូនសាច់សន្តាន ។ ឯសុកូម៉ំ វៀរិធនំ ថាគោះកូមហ៊ាន ល្អហើយនោះទឹង ចំរើនធនធាន សារ តើសឹងបាន ដូចចិត្តប្រាថ្នា ។ ឯសុគេហំ វៀរិជំ ថានៅ គ្រឹះហា ល្អហើយនោះទឹង ចំរើនប្រាជ្ញា សារពើប្រាថ្នា ពិតពុំកម្រ ។ ពោះអ្នកផងដើរ គេសឹងសរសើរ ថាផ្ទះនោះ ល្អ ចំរើនសួស្តី អំពីមាតម–នុស្សផង គេសរ-សើរផ្ទះនោះនៃៗ ច្បាប់នេះត្រកាល(១) សូមព្រះភូបាល(២) បរមក្សត្រិយ៍ថ្វៃ ទ្រង់ព្រះដំរិះ ត្រិះដោយញាណញៀយ្យ ទុកក្នុងហឫទ័យ ជាច្បាប់ពោះហោង ។

បពិត្រព្រះបាទ ព្រះបរមនាថ លើលោកកន្ទ្រប់ ជាតិ ជាឥស្សូរ កំពូលក្សត្រផង ព្រះអង្គជាច្បង ឯងឥតផ្ទឹមដល់ៗ

---

១ ល្អណាស់, មានប្រយោជន៍ណាស់ ។ ២-អ្នកគ្រួតត្រាលើគេ, ស្តេច ។

យកព្រះប្រាជ្ញា យកព្រះញាណថ្លា ថ្វាយព្រះយោបល់ គ្រប់
ត្រិះកម្រាប អ្នកបាបកំហល់ ឲ្យនិរព្យសន៍សល់ បានដូច
ប្រាជ្ញា ៗ ទុកភស្ត្រាធំឆ្ងាយ កុំបើព្រាប់ទ្រាយ សព្វព្រះមា-
ត្រា ព្រះឧស្សបណ្ណាំ ទុកលើសិរសា ទម្ងន់អាជ្ញា(៣) លើ-
ពផមន្ត្រី ៗ បពិត្រមហាពជ ស្រីសទ្រង់អំណាច បេស្តារិទ្ធិ
អញ្ជើញស្តេចស្តាប់ ជាច្បាប់គម្ពីរ សព្វព្រះវេណី ថ្កល់ថ្កើង
ចំពោះ ៗ

បីៗអសា បីៗឥតការ បីៗសូន្យសោះ ម្តេចហៅអសា
ឥតការដូច្នោះ ម្តេចហៅសូន្យសោះ ទេទៅឥតត្រើយ ៗ
នាហៅអសា មានទ្រព្យឥតការ ពុំធ្វើបុណ្យឡើយ ពុំសង់
គុណគេ អ្នកឯទៀតឡើយ ញាតិឯងជាត្រើយ ពិតពុំស្រាប-
ស្រង់ ៗ នាហៅឥតការ ចាំសីលាបារ មោះឥតពាក្យត្រង់
ចិត្តបង់បានបុណ្យ ពុំប្រណិបតន៍សង្ឃ បង់យសបានអគ្គ ពិត

---
១—អំណាច ។

ពុំឧស្សាហ៍នាទៅសូទ្យសោះ ព្ធមិតពោះ ពុំស្ដាប់ធម្ម យល់
ក្រិត្យក្រមច្បាប់ ពុំស្ដាប់ក្រិត្រ(១)ជា ទីនព្រះធម្ម ពុំធ្វើបរិសុទ្ធ
បីផ្គន់ស្នេហា បីផ្គន់ភរិយា បីៗផ្គន់បុត្រ ម្ដេចហៅផ្គន់
បុត្រ អស់ន័យនេះផង ៗ នាផ្គន់ស្នេហា វេសគាប់ពិសា កុំភ្លេច
ឡើយហោង សំណោះសំនួរ សាកសួរស្នេហ៍ស្នង ខុតក្បាតនេះ
ហោង ពុំបង់ឡើយនៃៗ នាផ្គន់ភរិយា វេណាបគ្រឹះហា ខ្វាប់ខ្លួន
ប្រពៃពោះទ្រព្យរបស់ អម្រស់ទុកដៃ វក្សាសំចៃ ពុំខ្ជាយឡើយ
ណា ៗ នាហៅផ្គន់បុត្រ ប្រពៃបរិសុទ្ធ ឲ្យរៀនសាស្ត្រាសិល្ប
សរពើគាប់ ជាច្បាប់អាត្មា អវឲ្យភរិយាដូចដោយចិត្តថ្វាត់ ៗ

បីៗហិនលក្ខណ៍ បីៗហិនសក្តិ ហិនសួស្ដីថ្វាត់ ម្ដេច-
ហៅហិនលក្ខណ៍ ហិនសក្តិបង់បាត់ ហិនសូទ្យទៀនផាត់
ន័យនេះសោតហោង ៗ នាហិនលក្ខណា សរសើរអាត្មា
ឯងនេះគន្ធង់ ពោលឥតគេស្ដាប់ សួរសំពុំសារសង់ ចូល
ស្ថានអ្នកផង ឥតគេស្រដី ៗ នាហៅហិនលក្ខណ៍ ស័ព្ទ-

---

១-ច្បាប់, ដំបូន្មាន, ពាក្យប្រៀនប្រដៅ ។

គន់ព្វផាក់ ឥតស័ព្ទគេរី មានមហាក្សត្រា ឥតមានក្សត្រី មាន ភជធានី ហើយគ្មានបន្ទាយ ៗ នាហិនសួស្តី លក្ខណ៍ផ្ទះ អប្រិយ(១) ភូមិពោតរលាយ សក្តិសីល៍ពុំជា យាត្រាទៀប ឆ្ងាយ និមិត្តសុនកាយ អគ្គឲ្យអប្រិយ ៗ

បីៗបាត់ស្និទ្ធ បីៗបាត់មិត្ត បីបាត់ពន្ធី . ម្តេចហៅ បាត់ស្និទ្ធ បាត់មិត្តមេត្រី ពន្ធីរស្មី បាត់បង់នោះណា ៗ នាហៅបាត់ស្និទ្ធ ពោលពាក្យខុសចិត្ត ខ្សឹបខ្សៀវជេរថា ផ្ញើមុខអាក្រក់ កុហកគាសា ហេតុនោះលោកថា បាត់ ស្និទ្ធពុំមាន ៗ រីន័យបាត់មិត្ត ពោលពាក្យពុំគិត សត្យា(២) សន្ធាន នាស្ពានលំនៅ ពុំទៅមកបាន ខ្ចីទ្រព្យបង្ខាន មុខពុំឲ្យយល់ ៗ នាបាត់ពន្ធី ក្តែកពិតពុំភ្លឺ ពុំយល់ បរិបូណ៌ ឥតសាច់ឥតញាតិ ស្លាប់ស័ព្ទស្លាប់សូរ ពិត ពុំបរិបូណ៌ វិញ្ញាណឯងអាប ៗ បីបាត់ខុនណាន៍ បីៗ បាត់ផាន៍ បីៗបាត់ប្រាជ្ញ ម្តេចបាត់ខុនណាន៍ បាត់ផាន៍

---
១-អាក្រក់,មិនជាទីពេញចិត្តនៃអ្នកផង ។ ២-ពាក្យពិត, សច្ចៈ ។

ឯង៏អាច ម្ដេចហៅបាត់ប្រាជ្ញ ចាំង៏បីនេះណា ៗ នាហៅបាត់
ខុទ- ណាង៏នោះជាមុន ស្រីមានលក្ខណា ពុំស្គាប់
អម្ចាស់ យប់ថ្ងៃឡើយណា ខ្ញុនចាស់ត្រឹត្វា ស្រដីឡេះ
ឡោះ ៗ វីបាត់ជាង៏ជាតិ ធ្វើការឥតខ្លាត ពុំស្របការ
នោះ រវៃតង៏ឲ្យឃ្លាត នឹង៏ខ្លាតស្ងួនឲ្យសោះ ពុំត្រូវចំពោះ
នឹង៏ក្បួនច្បាប់ឡើយ ៗ នាបាត់ប្រាជ្ញប្រុស កាលជំនុំនោះ
សៀមស្ងាត់ព្រងើយ ពាក្យពុំស្រដី គិរ្យ៍(១)ឥតត្រើយ
កុំសេពគប់ឡើយ មារយាទអប្រិយ ៗ

បីៗបានរស បីៗសប្បុរស បីៗពន្លឺ ម្ដេចហៅ
មានរស សប្បុរសមេត្រី ពន្លឺរស្មី ចាយបែង៏បរបា ៗ
គោះមានរសកាល សេពសោយអាហារ មានរសពិសា
អ្នកមានសប្បុរស កបរសកំចា មែនមានគរិយា មារយាទ
ប្រពៃ ៗ វីសប្បុរិសា ប្រកបលក្ខណា មានធម៌សោត
នៃ ស្រដីទូរំអាថ៌ ជាធម៌ឈ្លាសវៃ គាប់អម្ចាស់ថ្ងៃ មាន

---

១- បង្រៃ, មិនជឿបុណ្យបាប ។

ពិចារណា ។ រីឯទ្រឹមោះ កាលហូបបាយឈ្លោះ ឡើង ទើបតោក្តា ពោលពាក្យនូវអ្នក មានព្រះប្រាជ្ញា ប្រកប ករិយា ប្រកកិបតន៍សព្វកាល ។

បីៗហិនហោច បីៗគ្រមោច បីៗសាធារណ៍ ម្តេច ហៅហិនហោច គ្រមោចឥតការ ម្តេចហៅសាធារណ៍ ស្រេចស្រាយចេញហោង ។ នាហៅហិនហោច អសារ អសោច៍[១]ខ្លួនខ្ទៅធ្វើធ្ងន់ សេពគប់អ្នកផឹក ប្រមឹកស្រាផង ប្រពន្ធសោតហោង ស្រដីមាយា ។ នាហៅគ្រមោច គ្រមោលកណ្តោច កណ្តៀនកំព្រា ឯកមានរបៀន ឥត របៀនអ្នកណា ឥតបុត្រស្ងួនភ្ញា គ្រមោចសោតសល់ ។ នាហៅសាធារណ៍ មានគ្រឿងឥតការ បំបែកកិច្ចកល ប្រពន្ធបុស្ស[២] អាត្មាទុរពល[៣] រំងីព្រួតបំណុល លើ ខ្លួនទៀតគូរ ។

១-ជំអុយ, អាក្រក់ មិនល្អ ។ ២-អាក្រក់, ចង្រៃ, មិនគ្រប់លក្ខណ៍ ។
៣-ក្រីក្រ ខ្វះខាតខាងសម្ភារៈ ។

បីៗ សាមាន្យ បីអន្តរធាន បីគរុអាស្រូវ ម្ដេចហៅ-សាមាន្យ អន្តរធានក្ដី ម្ដេចហៅគរុអាស្រូវ ពាក្យនេះលោកថា ៗ នាហៅសាមាន្យ សង់ផ្ទះនាស្ថាន ទៀបផ្សារពុំជា គប់នូវអ្នកពាល សាធារណ៍មោហោ ប្រពន្ធនេះណា ច្រើនបំណុលនៅ ៗ រីអន្តរធាន សង់ផ្ទះនាស្ថាន នោះនៅជិតផ្លូវ ខ្លួនរែងអប្រិយ មានក្ដីអាស្រូវ ប្រពន្ធនោះក្ដី ប្រមឹកស្រាផង ៗ នាហៅអាស្រូវ សង់ផ្ទះជិតផ្លូវ ធ្លានោះសោតហោង ម៉ែក្មេកពុំជា មាត់រឹងកន្ធង ប្រពន្ធនោះហោង គេលេងទៀតខ្លី ៗ

បីៗ បរលោក បីៗ ពុំថោក បីៗ លោកិយ ម្ដេចហៅបរលោក ពុំថោកនោះក្ដី ម្ដេចហៅលោកិយ គួរដឹងសោះសា ៗ នាហៅបរលោក(១) រកគ្រូនាលោក ដ៏មានប្រាជ្ញា ខ្លួនសោតពុំខ្ជិល ចាំសីលភាវនា ចិត្តថ្លាសទ្ធា ពុំដែលដាច់ឡើយ ៗ នោះហៅពុំថោក រក្សាប្រាណ

---

១- លោកខាងមុខ, លោកដទៃទៀត ។

លោក ដំណឹងខ្ញុំហើយ អង្គុយខ្ពង់ខ្ពស់ ថ្កើងយសជាត្រើយ ករិយាគាប់ហើយ ត្រកូលថ្លៃផង ៗ នាហៅលោកិយ ពុំយល់ឯងក្តី មានបញ្ញាប់សោតហោង ពាក្យពោលសខ្យា(១)បរបា ឥតហួង ពាក្យពីរោះផង សានសមសាទរ ៗ

បីៗ ព្រាសលោក បីៗថយថោក ព្រាសលោកកុត្តរ ម្តេចហៅព្រាសលោក ថយថោកពុំបរិ-បូណ៌លោកកុត្តរ ឲ្យពិបារណា ៗ នាហៅព្រាសលោក ស្រដីថយថោក ពាក្យនោះពុំជា ខ្ញុំឯងគំអឹង ពាក្យរឹងមហិមា(២) យល់ចាស់ព្រឹទ្ធា ពិតពុំប្រណិបតន៍ ៗ ថោកព្រាណពេកណា ទុរ-យសអសា អង្គុយថយក្តាត់ អាហារថយផ្គន់ បម្រុងពីមាត់ នេះហោងលោកគាត់ ហៅថយថោកហោង ៗ រីព្រាស-លោកកូវ គួរនោះពុំត្រូវ ដោយធម៌ទំនង យល់សង្ស្យឥតចិត្ត ប្រណិបតន៍សង្ស្យផង សីលទានទោះហោង ពុំស្គាល់ឡើយណា ៗ មានតែបំបាត់ ជីវិតសព្វសត្វ ឥតមានមេត្តា

---

១-ពាក្យទៀងទាត់, សប្ទះ ។ ២-ក្រៃពេក។

ហៅព្រោសលោកគប់គួរនៅឯណា មានពន្លឺប្រការ-អកុសលៗ

ព្រះអង្គមហាក្សត្រិយ៍ សោយរាជសម្បត្តិ គ្រង់រាជ
មណ្ឌល(១) រើសរកសេនា ឲ្យជាខុនពល ហើយទឹងដំកល់
ស្នងព្រះនេត្រនៃ ៗ ក្រឡាពាសធំ ជាមេកងជុំ ការសង្គ្រាម
ជ័យ ស្រាល់រកអ្នកណា ចេះអធ្យាស្រ័យ មានប្រាជ្ញាវៃ
ស្គាល់អស់រាជការ ៗ ស្គាល់ទោសស្គាល់គុណ ស្គាល់
ក្រោយស្គាល់មុន ដើមចុងកណ្ដាល ស្គាល់បាបស្គាល់បុណ្យ
ស្គាល់ធ្ងន់ស្គាល់ស្រាល ស្គាល់ប្រាជ្ញស្គាល់ពាល ស្គាល់
ហ៊ានស្គាល់ខ្លាច ៗ ស្គាល់តិចស្គាល់ច្រើន សង្វាតក្រវើន
ស្គាល់អត់ស្គាល់ឃ្លាន ស្គាល់វៀចស្គាល់ត្រង់ ស្គាល់ក្បត
ស្គាល់មែន ស្គាល់ដីស្គាល់ដែន ស្គាល់ព្រៃស្គាល់ត្រាញ់ ៗ
ស្គាល់គាប់ស្គាល់ខុស ស្គាល់ស្លាប់ស្គាល់រស់ ស្គាល់ឈ្នះ
ស្គាល់ចាញ់ ស្គាល់បាញ់ស្គាល់បោះ ស្គាល់ដោះស្គាល់ដេញ
ស្គាល់ចូលស្គាល់ចេញ ស្គាល់បាត់ស្គាល់បង់ ៗ ស្គាល់តឹង

---

១-នៅទីនេះ ប្រែថា នគរ, ប្រទេស។

ស្គាល់ជួរ ស្គាល់ធាប់ស្គាល់យូរ ស្គាល់ហូលស្គាល់ខៀន

ស្គាល់ដើរស្គាល់ដេក ស្គាល់ស្រែកស្គាល់ឃ្លាន ស្គាល់បង់

ស្គាល់បាន ស្គាល់មានស្គាល់ខ្សត់ ។

បើមានកន្លង កលិយុគ(១)មកដល់ គេប្រាប់ប្រាកដ ថាកុំឆោតឆ្លល់ វិលវល់វង្វត់ កុំផ្សព្វយូររត់ ដំអក់ដំអឹង ។ កុំប្រើនរះរ៉ុង ងះងាំងងះងេង មមីមមឹង កុំប្រុនប្រខ្វស្ត រឹងរូសរបឹង កុំខ្ជិលរំពឹង តែដេកនិទ្រា ៗ កុំលោភចង់បាន ទ្រព្យគេបំពាន ពន្លឹកសោះសា កុំរៀនកំណាញ់ ស្វិតស្វាញប៉ុស្សា ពុំស្គាល់គាបជា ពាក្យពេចន៍ទ្រគោះ ៗ កុំលេងជាល្បែង រំពឹងយល់ឈ្មោង ពាក្យពុំពីរោះ ស្រដីឲ្យជាប់ ឲ្យស្របឲ្យសោះ កុំធ្វើឡេះឡោះ សរសោះអន្ទង ៗ កុំធ្វើហេងហាង កុំអួតកុំអាង ខុសក្តីបំណង កុំប្រើនត្រអែស ប្រហែសលេងលង ឲ្យរៀនត្រងរង នូវក្តីអំណត់ ។

អ្នកណាគាប់ស្គាល់ គាបដឹងអស់អាថិ ជាក់ជាប្រាកដ

---

១—គ្រោះភ័យអាសន្ន ។

ធ្វើការសង្គ្រាម ព្យាយាមចំបុត ឮកេរ្តិ៍ប្រាកដ ដូចព្រះរាមៗ
សេចក្ដីផ្ចាញ់អសុរ អស់ឥតសំណល់ ដល់មួយឡើយណា
បើបានសណ្ដាប់ ក្រមច្បាប់សាស្ត្រា ទុកអត្ថអាត្មា[១]
ទីទៃគ្រប់ប្រាណ ។ រីច្បាប់នេះណា បើអ្នកឯណា យក
ទុកឲ្យបាន ក្នុងអត្ថអាត្មា ជាសណ្ដាប់ប្រាណ អ្នកនោះនឹង
បាន ជាអត្ថអ្នកប្រាជ្ញ ។

បើនរអ្នកណា បានមើលអក្ខរ[២] ជាឲ្យស្រួលស្រេច
ជួយជួសសេចក្ដី អស់អាថ៌សេចគ្រេច ឲ្យមានបន្ដិច កុំសើច
ឡើយហោង ។ ជួយកែឲ្យត្រូវ តម្រង់តម្រូវ ដោយនូវគន្លង
ជាច្បាប់បុរាណ ពិតពីព្រេងហោង ឲ្យត្រូវបំណង ព្រេង
ព្រឹទ្ធបុរាណ ។ សេចក្ដីនេះណា និងមានអស់អាថ៌ ចប់បរិបូណ៌
បាន នេះហោងជាច្បាប់ សណ្ដាប់គ្រប់ប្រាណ ឲ្យនរទាន
និដ្ឋិតចប់ហោង ។

ចប់

១-ខេ...
២-មើលអក្សរ-គឺអានច្បាប់នេះ ។

## វេយ្យាករណ៍ទំនើបនិងវិធីសព្ទ

ដើម្បីឆ្លើយតបនឹងកិច្ចការរៀនក្បួនច្បាប់ អក្សរសាស្ត្រខ្មែរ

មិត្តសិស្សានុសិស្ស មិនអាចរកខ្ចីសៀវភៅថ្មីនៃបណ្ណាគារ

ជាដែលនេះ ដែលទើបនឹងចេញផ្សាយក្នុងពេលបន្តបន្ទាប់នេះគឺ

វេយ្យាករណ៍ទំនើបនិងវិធីសព្ទ

ជាស្នាដៃរបស់ គឹម-សែត សរសេរយ៉ាងល្អិតល្អន់ ដើម្បី

សិស្សានុសិស្សទាំងអស់គ្នា ។

**ងាយរៀន-ងាយយល់-ងាយចាំ មិនងាយភ្លេច**

រោងពុម្ពបញ្ញាសីលា

តម្លៃ ២៥ រុ០០